ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# ផែនការយុទ្ធសាស្ត្រជាតិ
# ស្តីពី ការគ្រប់គ្រង
# ហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព

នាយកដ្ឋានការពារសុខភាព

២០២០-២០២៤

# អារម្ភកថា

ផែនការយុទ្ធសាស្ត្រជាតិស្តីពី ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាពឆ្នាំ២០២០ ដល់២០២៤ ផ្តល់នូវគោលដៅសំខាន់ៗ សម្រាប់ការឆ្លើយតបរបស់ក្រសួងសុខាភិបាល ស្របតាមគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា ចំពោះបញ្ហាប្រឈម និងជម្រុញឱ្យកាន់តែប្រសើរឡើងនូវការគ្រប់គ្រងហានិភ័យគ្រោះអាសន្ននៃសុខភាពពីមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ។

កម្ពុជាត្រូវបានចាត់ទុកជាប្រទេសមួយក្នុងចំណោមប្រទេសដែលងាយរងគ្រោះទៅនឹងមុខសញ្ញាគ្រោះថ្នាក់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ទឹកជំនន់គឺជាហានិភ័យមួយក្នុងចំណោមហានិភ័យធំៗដែលប៉ះពាល់នៅកម្ពុជា។ ថ្មីៗកន្លងទៅនេះកម្ពុជាបានក្លាយជាប្រទេសងាយរងគ្រោះនឹងទឹកជំនន់ដែលកើតឡើងសឹងតែរាល់ឆ្នាំ បណ្តាលឱ្យការខូចខាតកាន់តែមានទំហំធំឡើង និងប៉ះពាល់ដល់អាយុជីវិត ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជារាប់ពាន់នាក់។ ជំងឺឆ្លង និងជំងឺដែលមានប្រភពមកពីចំណីអាហារដូចជា ជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវ ជំងឺរាក ការពុលចំណីអាហារ និងជំងឺគ្រុនឈាមរបួសនៅតែជាមូលហេតុចម្បងនៃអត្រាឈឺ និងស្លាប់។

ក្រោមការដឹកនាំដ៏រឹងមាំការរៀបចំ ការសម្របសម្រួលព្រមទាំងការទទួលខុសត្រូវ និងទំនាក់ទំនងច្បាស់លាស់គឺជាគន្លឹះក្នុងការធ្វើឱ្យប្រសើរឡើង នូវសមត្ថភាពជាតិ នៅក្នុងដំណាក់កាលទាំងបួននៃការបង្ការ ការត្រៀមរៀបចំជាស្រេច ការឆ្លើយតប និងការស្តារឡើងវិញដើម្បីគ្រប់គ្រងសុខភាពក្នុងពេលមានគ្រោះអាសន្ននិងគ្រោះមហន្តរាយ។

ក្រសួងសុខាភិបាល សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូបានធ្វើបច្ចុប្បន្នភាព **“ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាពឆ្នាំ២០១៤ដល់២០១៨”** ដើម្បីឱ្យអ្នកពាក់ព័ន្ធទាំងអស់ទទួលយកជាបញ្ហាអន្តរវិស័យក្នុងការកាត់បន្ថយគ្រោះភ័យគ្រោះមហន្តរាយ សម្រាប់សុខភាពក្នុងគោលបំណងពង្រឹងសមត្ថភាពជាតិ ដើម្បីកាត់បន្ថយហានិភ័យសុខភាពដែលបណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ និងមនុស្សនៅគ្រប់លំដាប់នៃប្រព័ន្ធសុខាភិបាល និងសហគមន៍។

ក្រសួងសុខាភិបាលសង្ឃឹមយ៉ាងមុតមាំថានឹងមានការគាំទ្រ និងចូលរួមយ៉ាងសកម្មពីដៃគូពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តការតាមដានត្រួតពិនិត្យផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព ដើម្បីឱ្យផែនការយុទ្ធសាស្ត្រជាតិនេះមានប្រសិទ្ធភាព និងប្រសិទ្ធផល។

ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការរៀបចំឱ្យសម្រេចបាននូវផែនការយុទ្ធសាស្ត្រជាតិដ៏មានសារៈសំខាន់នេះឡើង។

ថ្ងៃ អង្គារ ៨កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ២០២០

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

រដ្ឋលេខាធិការ

សាស្ត្រាចារ្យ អេង_ហួត

# មាតិកា


អារម្ភកថា....................I
មាតិកា....................II
បញ្ជីតារាង និងឧបសម្ព័ន្ធ....................III
អក្សរកាត់ និងពាក្យកាត់....................V
សេចក្តីថ្លែងអំណរគុណ....................VII
សង្ខេប....................VIII
១-សេចក្តីផ្តើម....................១
១.១-សារបានរបស់ប្រទេសកម្ពុជា....................១
១.២-ការប្រែប្រួលអាកាសធាតុគ្រោះធម្មជាតិ និងការប្រឈមទូទៅ....................១
១.៣-ការខាតបង់ជីវិតមនុស្ស និងសេដ្ឋកិច្ចដោយសារគ្រោះមហន្តរាយធម្មជាតិ....................១
១.៤-ការវិវត្តថ្នាក់សកល និងថ្នាក់តំបន់....................២
១.៥-ការវិវត្តនៅថ្នាក់ជាតិ....................៣
ក- វេទិកាឆ្លើយតបមនុស្សធម៌....................៣
ខ- ផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិ....................៤
គ- ការគ្រប់គ្រងគ្រោះមហន្តរាយក្នុងក្រសួងសុខាភិបាល....................៤
ឃ- ការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន....................៤
២-ចក្ខុវិស័យ....................៤
៣-បេសកកម្ម....................៤
៤-គោលបំណងនិងគោលដៅ....................៤
៥-ក្របខ័ណ្ឌយុទ្ធសាស្ត្រ....................៥
៥.១-ការវិភាគជាយុទ្ធសាស្ត្រ....................៥
៥.២-សកម្មភាព....................១១
៦-ធនធានហិរញ្ញវត្ថុ និងការអនុវត្ត....................២២
៦.១-ធនធានហិរញ្ញវត្ថុ....................២២
៦.២-ការអនុវត្ត....................២២
៧-ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ....................២៣

# បញ្ជីតារាង និងឧបសម្ព័ន្ធ


តារាងទី១ តារាងយុទ្ធសាស្ត្រអាទិភាព ..... ៧
តារាងទី២ ទិដ្ឋភាពរួមនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព ឆ្នាំ២០២០-២០២៤ ..... ១១
តារាងទី៣ សកម្មភាពឆ្នាំ២០២០-២០២៤ ..... ១២
តារាងទី៤ ប្រភពថវិកា ..... ២២
តារាងទី៥ ទិដ្ឋភាពទូទៅនៃតំណាក់កាលទាំង៤វដ្ត ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ..... ៣៤
ឧបសម្ព័ន្ធទី១-សំណើរអំពីលក្ខខណ្ឌប្រតិបត្តិរបស់ការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន ..... ២៤
លក្ខខណ្ឌប្រតិបត្តិ ..... ២៤
១- សម្របសម្រួល ..... ២៤
២- ការគ្រប់គ្រងពត៌មាន ..... ២៤
៣- ការគាំទ្រដល់ការផ្តល់សេវាសុខភាពនៅក្នុងភាពអាសន្ន ..... ២៥
៤- ការគ្រប់គ្រងធនធាន ..... ២៥
ឧបសម្ព័ន្ធទី២-សេចក្តីស្នើគំរូស្តង់ដារ ផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបហានិភ័យសុខភាព ពេលមាន គ្រោះមហន្តរាយរបស់មន្ទីរសុខាភិបាលខេត្ត ..... ២៧
ឧបសម្ព័ន្ធទី៣-និយមន័យនិងទស្សនទាន ..... ៣១
១-វិបត្តិ ( Crisis ) ..... ៣១
២-គ្រោះមហន្តរាយ ( Disaster ) ..... ៣១
៣-គ្រោះអាសន្ន ( Emergency ) ..... ៣១
៤-មុខសញ្ញាគ្រោះថ្នាក់ ( Hazard ) ..... ៣១
៥-ភាពងាយរងគ្រោះ ( Vulnerability ) ..... ៣១
៦-ហានិភ័យ ( Risk ) ..... ៣២
៧-ការកាត់បន្ថយហានិភ័យ ( Risk Reduction ) ..... ៣២
៨-ការបង្ការ ( Prevention ) ..... ៣២
៩-បន្ធូរបន្ថយ ( Mitigation ) ..... ៣២
១០-ការត្រៀមទុកជាមុន ( Preparedness ) ..... ៣២
១១-ការឆ្លើយតប ( Response ) ..... ៣៣
១២-ការស្តារឡើងវិញ ( Recovery ) ..... ៣៣
១៣-ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ( Disaster Risk Management ) ..... ៣៣
១៤-វដ្តនៃការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ( Disaster Risk Management Cycle ) ..... ៣៣
១៥-សមត្ថភាពបន្សាំ ( Adaptive capacity ) ..... ៣៤
១៦-សមត្ថភាពដោះស្រាយ ( Coping capacity ) ..... ៣៤
១៧-ការប៉ះពាល់ ( Exposure ) ..... ៣៤
១៨-ភាពងាយរងផលប៉ះពាល់ ( Susceptibility ) ..... ៣៤
១៩-ភាពធន់ ( Resilience ) ..... ៣៤
ឧបសម្ព័ន្ធទី៤-កញ្ចប់សេវាបន្តពូជអប្បបរមាដំបូង(MISP) ..... ៣៥

១-តើ MISP គឺជាអ្វី ? ..... ៣៥
២-គោលបំណងទាំង៥ របស់ MISP ..... ៣៥
៣-ការសម្របសម្រួលត្រូវបានកំណត់ ដើម្បីដឹកនាំការអនុវត្ត MISP ..... ៣៦
៤-ការពារអំពើហិង្សាផ្លូវភេទ ..... ៣៧
៥-កាត់បន្ថយការចម្លងមេរោគអេដស៍ ..... ៣៨
៦-ធានាឱ្យមានសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើត (EmONC) ..... ៣៩
៧- EmONC កម្រិតមូលដ្ឋាន ..... ៣៩
៨-សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើតកម្រិតពេញលេញ(Comprehensive EmONC) ..... ៣៩
៩-បង្កើតប្រព័ន្ធបញ្ជូន ដើម្បីគ្រប់គ្រងសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើត ..... ៣៩
១០-ឧបករណ៍សម្រាលកូនស្អាត(Clean Delivery Kit) ..... ៣៩
១១-ផែនការMISP សម្រាប់ការត្រៀមនិងឆ្លើយតបលើការថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ..... ៤០
ឧបសម្ព័ន្ធទី៥-ឯកសារយោង ..... ៤១
ឧបសម្ព័ន្ធទី៦-ការអភិវឌ្ឍសកល និងតំបន់ឯកសាយោង ..... ៤២
១-ការអភិវឌ្ឍថ្នាក់អន្តរជាតិ ..... ៤២
២-ការអភិវឌ្ឍថ្នាក់តំបន់ ..... ៤២
ឧបសម្ព័ន្ធទី៧៖ គោលការណ៍ណែនាំ ..... ៤៣
ឧបសម្ព័ន្ធទី៨៖ បញ្ជីផ្ទៀងផ្ទាត់ស្តីពី “ការគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាពទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ” ..... ៤៤
ផ្នែកទី១-អភិបាលកិច្ច គោលនយោបាយ និងសម្របសម្រួល ..... ៤៤
ផ្នែកទី២-ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង ..... ៤៧
ផ្នែកទី៣-ការផ្តល់សេវាសុខាភិបាល ..... ៤៧
ផ្នែកទី៤-ធនធាន (ជំនាញ មនុស្ស ហិរញ្ញវត្ថុ សម្ភារ និងការផ្គត់ផ្គង់) ..... ៤៧

# អក្សរកាត់ និងពាក្យកាត់

| | | |
|---|---|---|
| AOP | Annual Operation Plan | ផែនការប្រតិបត្តិប្រចាំឆ្នាំ |
| AADMER | ASEAN Agreement on Disaster Management and Emergency Response | កិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបនឹងគ្រោះអាសន្ន |
| ACDM | ASEAN Disaster Management Committee | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយអាស៊ាន |
| APSED | Asia Pacific Strategy for Emerging Diseases | យុទ្ធសាស្ត្រអាស៊ីប៉ាស៊ីហ្វិក សម្រាប់ជំងឺដែលកើតឡើងថ្មីៗ |
| ASEAN | Association of South-east Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CamDi | Cambodia Disaster Loss and Damage Database | ទិន្នន័យមូលដ្ឋានកម្ពុជាសម្រាប់ការបាត់បង់និងខូចខាតពេលមានគ្រោះមហន្តរាយ |
| CCA | Common country assessment | ការវាយតម្លៃប្រទេសតាមធម្មតា |
| CDC | Communicable Disease Control | នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| CRC | Cambodia Red Cross | កាកបាទក្រហមកម្ពុជា |
| DCDM | District Committee for Disaster Management | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ |
| DMEH | Disaster Management and Environmental Health | ការគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន |
| DRM | Disaster Risk Management | ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ |
| DRMH | Disaster Risk Management for Health | ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព |
| ERM | Emergency Risk Management | ការគ្រប់គ្រងហានិភ័យគ្រោះអាសន្ន |
| EmONC | Emergency Obstetric & Newborn Care | ការថែទាំសម្រាលបន្ទាន់ |
| HERM | Health Emergency Risk Management (framework) | (ក្របខ័ណ្ឌ)គ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាព |
| HRF | Humanitarian Response Forum | វេទិកាឆ្លើយតបមនុស្សធម៌ |
| HSSP2 | Health Sector Support Programme 2 | កម្មវិធីទ្រទ្រង់វិស័យសុខាភិបាលជំហានទី២ |
| IHR | International Health Regulation | និយ័តកម្មសុខភាពអន្តរជាតិ |
| INGOs | International Non-Governmental Organisations | អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ |
| IREC | International Relations and External Cooperation | មជ្ឈមណ្ឌលសម្របសម្រួលប្រតិបត្តិការ និងទំនាក់ទំនងអន្តរជាតិ |
| IFRC | International Federation of Red | សហព័ន្ធអន្តជាតិនៃកាកបាទក្រហមអឌ្ឍចន្ទក្រហម |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| PFERNA | Post Flood Early Recovery Need Assessment | ការប៉ាន់ប្រមាណតម្រូវការស្តារឡើងវិញភ្លាមៗក្រោយគ្រោះទឹកជំនន់ |

| | | |
|---|---|---|
| PMTCT | Prevention of Mother-to-Child Transmission | ការបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| | Terms of Reference (ToR) | លក្ខខណ្ឌប្រតិបត្តិ |
| TWGH | Technical Working Group for Health | ក្រុមការងារបច្ចេកទេសសុខាភិបាល |
| UN | United Nations | អង្គការសហប្រជាជាតិ |
| WHA | World Health Assembly | សន្និបាតសុខភាពពិភពលោក |
| UNFPA | United Nations Population Fund | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| WHO | World Health Organisation | អង្គការសុខភាពពិភពលោក |
| WHO CCS | WHO Country Cooperation Strategy | យុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការប្រចាំប្រទេស អង្គការសុខភាពពិភពលោក |
| UNDAF | United Nations Development Assistance Framework | ក្របខណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |

# សេចក្តីថ្លែងអំណរគុណ

ផែនការយុទ្ធសាស្ត្រជាតិស្តីពី ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព ត្រូវបានធ្វើបច្ចុប្បន្នភាព ដែលដឹកនាំ និងសម្របសម្រួល ដោយនាយកដ្ឋានការពារសុខភាព ជាមួយនឹងស្ថាប័ន-ក្រសួងពាក់ព័ន្ធ និងក្រុមមន្ត្រីបង្គោល ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងចំណាយពេលវេលាប្រាជ្ញាស្មារតី ចូលរួមយ៉ាងសកម្មញ៉ាំងឱ្យផែនការយុទ្ធសាស្ត្រនេះកាន់តែមានភាពល្អប្រសើរ ស្របតាមបរិបទនៃការគ្រប់គ្រង គ្រោះមហន្តរាយ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារនៃនាយកដ្ឋានការពារសុខភាព ដែលបានដឹកនាំ និងសម្របសម្រួលដំណើរការរៀបចំធ្វើបច្ចុប្បន្នភាពឯកសារនេះ ជាមួយនឹងស្ថាប័ន-ក្រសួងពាក់ព័ន្ធ និងក្រុមមន្ត្រីបង្គោល ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងចំណាយពេលវេលាប្រាជ្ញាស្មារតីចូលរួមយ៉ាងសកម្ម ញ៉ាំងឱ្យផែនការយុទ្ធសាស្ត្រនេះឱ្យកាន់តែមានភាពប្រសើរ ស្របតាមបរិបទនៃការគ្រប់គ្រងគ្រោះមហន្តរាយ របស់ប្រទេសកម្ពុជា។

សូមថ្លែងអំណរគុណអង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(UNFPA) ដែលបានផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុព្រមទាំងជំនួយបច្ចេកទេសដែលផ្តល់ដោយការិយាល័យប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិករបស់UNFPA ប្រចាំទីក្រុងបាងកកប្រទេសថៃ សម្រាប់ការធ្វើបច្ចុប្បន្នភាព "ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព ២០២០-២០២៤" ព្រមទាំងអង្គការសុខភាពពិភពលោក (WHO) ដែលបានគាំទ្រទាំងបច្ចេកទេស និងថវិកាសម្រាប់អភិវឌ្ឍន៍ "ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព២០១៤-២០១៨" និងអង្គការសុខភាពពិភពលោក ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ដើម្បីសកម្មភាព(ខែធ្នូ២០១២)[(1)]។

# សង្ខេប

ផែនការយុទ្ធសាស្ត្រជាតិស្តីពី ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាពនេះ ផ្តល់នូវចំណុចសំខាន់ៗ នៃការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះបញ្ហាប្រឈមដែលកំពុងតែកើនឡើងនៃហានិភ័យទាក់ទងទៅនឹងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ជំងឺឆ្លង និងជំងឺរាតត្បាតជាសកល។

ការគ្រប់គ្រងហានិភ័យគ្រោះអាសន្នសុខភាព តម្រូវឱ្យមានអភិក្រមពហុវិស័យដើម្បីឆ្លើយតបនឹងមុខសញ្ញាគ្រោះថ្នាក់ដែលមានការចូលរួមពីក្រសួងសុខាភិបាល ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ទីភ្នាក់ងារមនុស្សធម៌ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ ធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហាប្រឈមជាក់លាក់នៅក្នុងដំណាក់កាលនីមួយៗ ក្នុងវដ្តនៃការគ្រប់គ្រងហានិភ័យគ្រោះអាសន្ន។

ផែនការនេះ បង្ហាញពីការយកចិត្តទុកដាក់របស់ក្រសួងសុខាភិបាលនៃរាជរដ្ឋាភិបាលកម្ពុជាសំដៅឆ្ពោះទៅរក និងកែលម្អសមត្ថភាពជាតិនៅដំណាក់កាលទាំងបួន ការត្រៀមបង្ការនិងកាត់បន្ថយគ្រោះថ្នាក់ ការត្រៀមរៀបចំដោយផ្តោតលើដំណាក់កាលមុនពេលកើតមានគ្រោះមហន្តរាយការឆ្លើយតប-សង្គ្រោះបន្ទាន់ និងការស្តារឡើងវិញសំដៅគ្រប់គ្រងនូវគ្រោះអាសន្ន និងគ្រោះមហន្តរាយផ្នែកសុខភាពឱ្យកាន់តែល្អប្រសើរ ព្រមទាំងដាក់បញ្ចូលកញ្ចប់សេវាបន្តពូជអប្បបរមាដំបូង (MISP)។ ផែនការនេះ គឺជាកិច្ចការចាំបាច់មួយដោយហេតុថាគ្រោះមហន្តរាយបានបង្កឱ្យមានភាពងាយរងគ្រោះកាន់តែខ្លាំងឡើងទាក់ទងទៅនឹងភាពក្រីក្រ ភាពអត់ឃ្លានភាពគ្មានការងារធ្វើ ការផ្លាស់ប្តូរទីលំនៅ និងចំណាកស្រុក។

ផែនការយុទ្ធសាស្ត្រជាតិនេះ នឹងរួមចំណែកដល់ការគ្រប់គ្រងហានិភ័យគ្រោះអាសន្នសុខភាពជារួមក្នុងការដោះស្រាយមុខសញ្ញាគ្រោះថ្នាក់ហើយនឹងត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាពអភិវឌ្ឍន៍ដទៃទៀតផងដែរ។ ម៉្យាងវិញទៀត ដើម្បីបង្កើនប្រសិទ្ធភាពបន្ថែម និងការបំពេញបង្គ្រប់ទៅលើកិច្ចព្រមព្រៀងថ្នាក់ជាតិថ្នាក់តំបន់ និងថ្នាក់អន្តរជាតិដែលមានស្រាប់។

## ១.សេចក្តីផ្តើម

គ្រោះមហន្តរាយ និងគ្រោះអាសន្នដទៃទៀតតែងតែបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងមកលើសុខភាពរបស់មនុស្សរួមទាំងការបាត់បង់ជីវិតផងដែរ។ រាល់ការគំរាមកំហែងថ្មីដែលលេចឡើងបង្ហាញពីបញ្ហាប្រឈមក្នុងការគ្រប់គ្រងហានិភ័យផ្នែកសុខភាព និងផលប៉ះពាល់នៃគ្រោះអាសន្ន និងគ្រោះមហន្តរាយ។ ការស្លាប់របួស ជំងឺពិការភាពបញ្ហាផ្លូវចិត្ត-សង្គម និងផលប៉ះពាល់លើសុខភាពដទៃទៀតអាចចៀសវាងបានឬអាចកាត់បន្ថយដោយមានវិធានការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ដែលពាក់ព័ន្ធនឹងវិស័យសុខាភិបាល និងវិស័យដទៃទៀត។

### ១.១ សាវតាររបស់ប្រទេសកម្ពុជា

កម្ពុជាមានប្រជាជនប្រមាណ១៥,៧លាននាក់[2]ហើយប្រជាពលរដ្ឋភាគច្រើនរស់នៅក្នុងតំបន់ជនបទនិងជាប្រទេសដែលមានប្រវត្តិយូរអង្វែង និងសម្បូណ៌បែប។ ទោះបីជាទើបតែងើបផុតពីសង្គ្រាម និងអស្ថិរភាពនយោបាយផ្ទៃក្នុងជាច្រើនទសវត្សរ៍ក៏ដោយប្រទេសនេះមានការរីកចម្រើនយ៉ាងខ្លាំង ហើយបច្ចុប្បន្ននេះ ទទួលបានសន្តិភាពដោយក្នុងនោះសូចនាករអភិវឌ្ឍន៍សេដ្ឋកិច្ច និងមនុស្សបង្ហាញពីភាពប្រសើរឡើងជាប្រចាំ។ ការបោះឆ្នោតសភាត្រូវបានធ្វើឡើងរៀងរាល់ប្រាំឆ្នាំម្តង ហើយការបោះឆ្នោតចុងក្រោយគឺបានធ្វើឡើងក្នុងឆ្នាំ២០១៨។ ការកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចគឺជាកិច្ចការដែលមានសារៈសំខាន់កាន់តែខ្លាំងឡើងៗនៅលើរបៀបវារៈរបស់រាជរដ្ឋាភិបាល។ បើទោះបីជាមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចក្តីក៏១៣,៥% នៃប្រជាពលរដ្ឋកម្ពុជានៅតែរស់នៅក្រោមបន្ទាត់ភាពក្រីក្រ (NSDP 2019 - 2023)[3] ហើយភាពក្រីក្រនេះធ្វើឱ្យសហគមន៍កាន់តែងាយរងគ្រោះថែមទៀតទៅនឹងផលប៉ះពាល់នៃគ្រោះហមន្តរាយធម្មជាតិ និងមនុស្សបង្កើត។

### ១.២ ការប្រែប្រួលអាកាសធាតុគ្រោះធម្មជាតិ និងការប្រឈមនានា

កម្ពុជាគឺជាប្រទេសដែលងាយរងគ្រោះយ៉ាងខ្លាំងទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលរួមមានគ្រោះរាំងស្ងួតទឹកជំនន់ និងកំណើនកម្ពស់ទឹកសមុទ្រដែលធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិរបស់ពួកគេស្ទើរតែរាល់ឆ្នាំ[4]។ ទឹកជំនន់និងខ្យល់ព្យុះឆ្នាំ២០១៣ បានបង្ហាញថាអ្នកក្រងាយរងគ្រោះបំផុតដោយសារគ្រោះមហន្តរាយ ដូចដែលបានបង្ហាញក្នុងរបាយការណ៍នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយលើការប៉ាន់ប្រមាណតម្រូវការស្តារឡើងវិញពីគ្រោះទឹកជំនន់២០១៣ នៅក្នុងខេត្តសៀមរាប និងបាត់ដំបង។ កសិករនៅទូទាំងប្រទេសបានបាត់បង់ផលដំណាំរបស់ពួកគេ ហើយបច្ចុប្បន្ននេះ នៅតែខិតខំស្តារស្ថានភាពឡើងវិញនៅឡើយ។ វិស័យសេដ្ឋកិច្ចដទៃទៀតដូចជាក្រុមហ៊ុនកាត់ដេរ និងហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ត្រូវរងគ្រោះដោយសារទឹកជំនន់ ដែលធ្វើឱ្យខាតបង់សេដ្ឋកិច្ច[5]។

### ១.៣ ការខាតបង់ជីវិតមនុស្ស និងសេដ្ឋកិច្ចដោយសារគ្រោះមហន្តរាយធម្មជាតិ

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសកម្ពុជាបានជួបប្រទះស្ថានភាពងាយរងគ្រោះកាន់តែខ្លាំងដោយសារទឹកជំនន់ដែលកើតឡើងស្ទើរតែរាល់ឆ្នាំ។ នៅឆ្នាំ២០០៩ ខ្យល់ព្យុះកេតសាណាបានប៉ះពាល់ទៅលើខេត្តចំនួន១៤ និងបានបង្កឱ្យមនុស្សស្លាប់ចំនួន៤៣នាក់។ ឆ្នាំ២០១១ ខេត្តចំនួន១៨ ត្រូវបានជន់លិចដោយបង្កឱ្យស្លាប់មនុស្សចំនួន២៤៧នាក់ និងប៉ះពាល់ដល់៣៥០,០០០គ្រួសារ ដែលមានមនុស្សជាង១,៦៤លាននាក់ (រួមទាំងកុមារ៧០០,០០០នាក់)ត្រូវជម្លៀស។ នៅឆ្នាំ២០១២ ទឹកជំនន់រហ័សបានធ្វើឱ្យប៉ះពាល់ដល់ ១១,៧០០ គ្រួសារហើយ ៣.៥០០គ្រួសារត្រូវផ្លាស់ប្តូរទីលំនៅ។

រដូវវស្សាឆ្នាំ២០១៣ (ខែឧសភាដល់ខែតុលា ឆ្នាំ២០១៣) ទឹកជំនន់ទ្រង់ទ្រាយធំកើតឡើងជាថ្មីក្នុងតំបន់អាស៊ីអាគ្នេយ៍បន្ទាប់ពីមានភាពស្ងប់ស្ងាត់ក្នុងឆ្នាំ២០១២មក។ ការរួមបញ្ចូលគ្នានូវខ្យល់ព្យុះកំបុតត្បូងទីហ្វុងជាបន្តបន្ទាប់កំណើនយ៉ាងខ្លាំងនូវកម្រិតទឹកទន្លេមេគង្គទឹកជំនន់រហ័សឆ្លងដែននៅក្នុងខេត្តភាគខាងលិច

និងទឹកភ្លៀងមូសុងខ្ពស់ជាងមធ្យមភាគបានបង្កឱ្យមានទឹកជំនន់យ៉ាងខ្លាំងក្លានៅទូទាំងប្រទេសកម្ពុជា។ នៅថ្ងៃទី១៨ ខែតុលា គ.ជ.គ.ម.បានរាយការណ៍ថាទឹកជំនន់បានប៉ះពាល់ទៅលើ៣៧៧,៣៥៤ គ្រួសារដែលមានមនុស្ស១,៨លាននាក់ ដែលរស់នៅក្នុងខេត្តចំនួន២០។ សាលារៀនចំនួន១,២៤២ខ្នង មណ្ឌលសុខភាពនិងមន្ទីរពេទ្យចំនួន៧៨កន្លែងត្រូវទឹកជន់លិច។ ទឹកជំនន់នេះ បានធ្វើឱ្យមនុស្សស្លាប់ចំនួន១៦៨នាក់ ភាគច្រើនជាកុមារ[6]។ ការខូចខាតសរុប និងខាតបង់ដែលបង្កដោយទឹកជំនន់ឆ្នាំ២០១៣ត្រូវបានប៉ាន់ស្មានថាមានចំនួន៣៥៦លានដុល្លារអាមេរិក ដែលក្នុងនោះ១៥៣លានដុល្លារគឺខាតបង់ទៅលើទ្រព្យសម្បត្តិរូបវន្ត និង២០៣លានដុល្លារខាតបង់ទៅលើលំហូរផលិតកម្ម និងសេដ្ឋកិច្ច។ តាមការប៉ាន់ប្រមាណតម្រូវការស្តារឡើងវិញភ្លាមៗក្រោយគ្រោះទឹកជំនន់ឆ្នាំ២០១៤ ខេត្តជាច្រើនក្នុងចំណោមខេត្តដែលរងគ្រោះក្នុងទឹកជំនន់ឆ្នាំ២០១៣គឺជាខេត្តដែលមានប្រជាជនស្ថិតនៅក្រោមបន្ទាត់ក្រីក្រ។ ខណៈដែលប្រជាពលរដ្ឋកម្ពុជានៅតំបន់ជនបទដែលងាយរងគ្រោះខ្លាំងដោយសារហានិភ័យ និងបញ្ហាបន្ទាន់នានាទឹកជំនន់បានធ្វើឱ្យប៉ះពាល់បន្ថែមទៀតដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ[7]។

### ១.៤ ការវិវត្តថ្នាក់សកល និងថ្នាក់តំបន់

កិច្ចប្រជុំថ្នាក់ដឹកនាំអាស៊ានពិសេសស្តីពីផលវិបាកនៃគ្រោះរញ្ជួយដី និងរលកយក្សស៊ូណាមិ ដែលបានកើតឡើងកាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៥ បានអនុម័តសេចក្តីប្រកាសស្តីពីសកម្មភាពដើម្បីពង្រឹងជំនួយសង្គ្រោះបន្ទាន់ការស្តារឡើងវិញការកសាងឡើងវិញ និងការទប់ស្កាត់បន្ទាប់ពីផលវិបាកនៃគ្រោះរញ្ជួយដី និងរលកយក្សស៊ូណាមិកាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៤។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយអាស៊ាន មានការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិរបស់ប្រទេសជាសមាជិកអាស៊ាន និងប្រតិបត្តិកិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបគ្រោះអាសន្នដែលជាកិច្ចព្រមព្រៀងស្របច្បាប់។

និយ័តកម្មសុខភាពអន្តរជាតិ(២០០៥) បានចូលជាធរមានក្នុងឆ្នាំ២០០៧។ នៅក្នុងនិយ័តកម្មសុខភាពអន្តរជាតិ(២០០៥) ការរៀបចំផែនការសម្រាប់គ្រោះអាសន្នផ្នែកសុខភាពសាធារណៈការត្រៀមជាមុន និងការឆ្លើយតបត្រូវបានកំណត់ថាជាសមត្ថភាពស្នូល។ ដើម្បីសម្រេចបានសមត្ថភាពស្នូលរបស់និយ័តកម្មសុខភាពអន្តរជាតិយុទ្ធសាស្ត្រអាស៊ីប៉ាស៊ីហ្វិក សម្រាប់ជំងឺដែលកើតឡើងថ្មីត្រូវបានអនុម័ត និងអនុវត្តនៅក្នុងរដ្ឋជាសមាជិកដែលក្នុងនោះរួមទាំងប្រទេសកម្ពុជាផងដែរ។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងក៏នៅតែមានការខ្វះខាតដែរ ហើយនៅក្នុងឆ្នាំ២០១១ សន្និបាតសុខភាពពិភពលោកបានអនុម័តសេចក្តីសម្រេចចិត្តលេខ៦៤.១០ (២០១១) ដែល "ទទូចឱ្យរដ្ឋជាសមាជិកពង្រឹងកម្មវិធីគ្រប់គ្រងហានិភ័យគ្រោះអាសន្ន និងគ្រោះមហន្តរាយផ្នែកសុខភាពសម្រាប់គ្រប់មុខសញ្ញាគ្រោះថ្នាក់ទាំងអស់ដែលជាផ្នែកមួយនៃប្រព័ន្ធសុខាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកែលម្អលទ្ធផលសុខភាពកាត់បន្ថយអត្រាស្លាប់ និងមានជំងឺការពារហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និងពង្រឹងភាពធន់របស់ប្រព័ន្ធសុខាភិបាលនិងសង្គមទាំងមូល"។ បន្ទាប់ពីសេចក្តីសម្រេចចិត្តនេះមក ក្របខ័ណ្ឌថ្នាក់តំបន់នៃការិយាល័យថ្នាក់តំបន់ប៉ាស៊ីហ្វិកខាងលិចរបស់អង្គការសុខភាពពិភពលោក សម្រាប់សកម្មភាពស្តីពីការគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់មុខសញ្ញាគ្រោះថ្នាក់ធម្មជាតិដែលទាក់ទងនឹងសុខភាព(២០១៣) ត្រូវបានអភិវឌ្ឍឡើង ដើម្បីណែនាំដល់រដ្ឋជាសមាជិក។ *ឯកសារយោងមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៥។* សុខភាពផ្លូវភេទ និងសុខភាពបន្តពូជគឺជាផ្នែកមួយនៃសិទ្ធិមនុស្ស និងជាសមាសធាតុសំខាន់នៃការឆ្លើយតបផ្នែកមនុស្សធម៌។ កិច្ចខិតខំប្រឹងប្រែងដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សុខភាពផ្លូវភេទ និងសុខភាពបន្តពូជរបស់ប្រជាជនដែលរងផលប៉ះពាល់ក្នុងពេលគ្រោះមហន្តរាយត្រូវបានធ្វើឡើងភ្លាមៗដោយរដ្ឋាភិបាលអង្គការសហប្រជាជាតិអង្គការក្រៅរដ្ឋាភិបាល អ្នកជំនាញនិងដៃគូពាក់ព័ន្ធដទៃទៀតដោយបង្កើតគោលការណ៍ណែនាំជាសកលដូចជា៖ សៀវភៅណែនាំអន្តរទីភ្នាក់ងារ

ស្តីពីសុខភាពបន្តពូជក្នុងបរិបទមនុស្សធម៌(Inter-AgencyField Manual on Reproductive Health in Humanitarian Settings (IAFM)និងកញ្ចប់សេវាអប្បបរមាដំបូង (Minimum Initial Service Package (MISP)សម្រាប់ផ្តល់សេវាសុខភាពបន្តពូជនៅក្នុងស្ថានភាពមានវិបត្តិ។ កញ្ចប់សេវាអប្បបរមាដំបូង(MISP) គឺជាសកម្មភាពចាំបាច់ជាការងារបន្ទាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសុខភាពបន្តពូជនៅពេលចាប់ផ្តើមនៃរាល់វិបត្តិមនុស្សធម៌។ MISPមិនមែនគ្រាន់តែជាឧបករណ៍និងការផ្គត់ផ្គង់ប៉ុណ្ណោះទេ វាជាសំណុំនៃសកម្មភាពដែលត្រូវអនុវត្តក្នុងលក្ខណសម្របសម្រួលដោយបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ។

នៅថ្នាក់ការិយាល័យប្រចាំតំបន់របស់UNFPA ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកបាននិងកំពុងធ្វើការជាមួយរដ្ឋាភិបាលក្នុងការបកប្រែគោលការណ៍ណែនាំទាំងនេះទៅតាមបរិបទប្រទេសផ្សេងៗ និងដើម្បីធានាការអនុវត្ត MISP នៅក្នុងស្ថានភាពគ្រោះអាសន្ន គ្រោះមហន្តរាយផ្សេងៗគ្នាក្នុងការសង្គ្រោះជីវិតជាមូលដ្ឋានផ្នែកសុខភាពផ្លូវភេទ សុខភាពបន្តពូជដល់ប្រជាជនដែលរងផលប៉ះពាល់រួមមានស្ត្រីក្មេងជំទង់និងក្មេងស្រី។

### ១.៥ ការវិវត្តនៅថ្នាក់ជាតិ

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ **(គ.ជ.គ.ម)** នៅប្រទេសកម្ពុជាបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ និងត្រូវបានរៀបចំកែសម្រួលជាបន្តបន្ទាប់ ដើម្បីឆ្លើយតបនឹងស្ថានភាព និងទំហំនៃការងារគ្រប់គ្រងគ្រោះមហន្តរាយ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយមានយន្តការរចនាសម្ព័ន្ធពីថ្នាក់ជាតិ រហូតដល់មូលដ្ឋានដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីជាប្រធាន** មានរដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាលជាសមាជិក និងមានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាល ដើម្បីដឹកនាំគ្រប់គ្រង និងសម្របសម្រួលការងារគ្រប់គ្រងគ្រោះមហន្តរាយនៅព្រះរាជាណាចក្រកម្ពុជា។ មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការដោយមាននាយកដ្ឋានចំណុះចំនួន៦រួមមាន៖ នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នាយកដ្ឋានផែនការនិងស្រាវជ្រាវ នាយកដ្ឋានសហប្រតិបត្តិការនិងអាស៊ាន នាយកដ្ឋានពត៌មានគ្រប់គ្រងគ្រោះមហន្តរាយ នាយកដ្ឋានអប់រំផ្សព្វផ្សាយនិងបណ្តុះបណ្តាល នាយកដ្ឋានប្រតិបត្តិការឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយមាននៅថ្នាក់កណ្តាលថ្នាក់ខេត្ត ថ្នាក់ស្រុក ថ្នាក់ឃុំនិងថ្នាក់ភូមិ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានខិតខំយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពនៅថ្នាក់ជាតិថ្នាក់ក្រោមជាតិ និងមូលដ្ឋានសហគមន៍លើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដោយផ្សារភ្ជាប់ជាមួយការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់អាយុជីវិតទ្រព្យសម្បត្តិសម្ភារដោយសារគ្រោះមហន្តរាយក្នុងគោលដៅកសាងភាពធន់របស់ប្រជាជន និងសហគមន៍ទៅនឹងគ្រោះមហន្តរាយ។

### ក- វេទិកាឆ្លើយតបមនុស្សធម៌

វេទិកាឆ្លើយតបមនុស្សធម៌ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១១ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសម្រាប់ការសម្របសម្រួលរវាងដៃគូអភិវឌ្ឍន៍នានា សំដៅដោះស្រាយតម្រូវការរបស់គ្រោះមហន្តរាយមនុស្សធម៌ ជាពិសេសគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត។ គោលដៅរបស់វេទិកាឆ្លើយតបមនុស្សធម៌គឺដើម្បីធានាការសម្របសម្រួលនិងការប្រាស្រ័យទាក់ទងប្រកបដោយភាពរលូនអំពីការត្រៀមបង្ការសម្រាប់គ្រោះអាសន្ន និងការឆ្លើយតបផ្នែកមនុស្សធម៌ រវាងអង្គការសហប្រជាជាតិអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការអន្តរជាតិនានា។ វេទិកាឆ្លើយតបមនុស្សធម៌ធ្វើការដោយសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល និងជាពិសេស គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (**គ.ជ.គ.ម.**)។

អង្គការសុខភាពពិភពលោកក៏ជាសមាជិកនៃវេទិកាឆ្លើយតបផ្នែកមនុស្សធម៌និងជាទីភ្នាក់ងារនាំមុខវិស័យសុខភាព។

### ខ- ផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិ

ការគ្រប់គ្រងហានិភ័យសុខភាពបង្កដោយគ្រោះមហន្តរាយ និងការត្រៀមទុកជាមុន ស្ថិតក្នុងចំណោមគោលបំណងដែលបានចែងក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិ សេវាសុខភាពមានគុណភាពប្រសិទ្ធភាព និងសមធម៌២០១៦-២០២០ (ឧសភា ២០១៦) ដែលផ្តល់ធាតុចូលគ្រប់គ្រាន់ដល់យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាពដោយផ្តោតជាពិសេសទៅលើ "ធម្មជាតិ" គ្រោះថ្នាក់ និងរបួសដោយគ្រោះថ្នាក់ចរាចរណ៍ក្រោមឆ័ត្រកាត់បន្ថយការឈឺចាប់ និងស្លាប់ដោយជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដ៏ទៃទៀត។

### គ- ការគ្រប់គ្រងគ្រោះមហន្តរាយក្នុងក្រសួងសុខាភិបាល

លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ នៃក្រសួងសុខាភិបាល ដឹកនាំដោយរដ្ឋលេខាធិការមួយរូប។ ក្រុមលេខាធិការដ្ឋានមានសមាសភាព អនុរដ្ឋលេខាធិការចំនួនពីររូប អគ្គនាយកបច្ចេកទេសសុខាភិបាលនិងអគ្គនាយករដ្ឋបាលជាអនុប្រធាន។ អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត អគ្គនាយករងបច្ចេកទេស អគ្គាធិការរង ប្រធាននាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួង និងប្រធានមន្ទីរពេទ្យជាតិទាំងអស់ជាសមាជិក ព្រមទាំងមានមន្ត្រីបង្គោល ដែលមានចំនួនសរុប១៦រូប។ លេខាធិការដ្ឋានមានភារកិច្ចជាសេនាធិការឱ្យយន្តការគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងសុខាភិបាល និងមានតួនាទីសំខាន់ក្នុងការសម្របសម្រួលការងារទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ អង្គភាពពាក់ព័ន្ធ ដើម្បីធានាលើការគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យសុខាភិបាលប្រកបដោយប្រសិទ្ធភាព។ លេខាធិការដ្ឋានមានទីតាំងនៅ នាយកដ្ឋានការពារសុខភាពនៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល ក្រសួងសុខាភិបាល។

### ឃ- ការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន

ការិយាល័យនេះ ស្ថិតនៅក្នុងនាយកដ្ឋានការពារសុខភាព នៃទីស្តីការក្រសួងសុខាភិបាល មានមន្ត្រីចំនួនប្រាំមួយរូប និងមានតួនាទីជាលេខាធិការដ្ឋានដោយមានភារកិច្ចរៀបចំគោលនយោបាយផែនការគោលការណ៍ណែនាំ និងមានទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងសម្របសម្រួលជាមួយនាយកដ្ឋានពាក់ព័ន្ធដទៃទៀតនៅក្នុងក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

## ២ ចក្ខុវិស័យ

ធានាថាហានិភ័យគ្រោះមហន្តរាយដែលបង្កដល់សុខភាពរបស់ប្រជាជន ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធពល។

## ៣ បេសកកម្ម

ពង្រឹងគាំទ្រនិងដឹកនាំគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ លើបញ្ហាសុខភាពក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។

## ៤ គោលបំណង និងគោលដៅ

គោលបំណងនៃ "ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព" ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា និងការពារផលប៉ះពាល់ពីគ្រោះមហន្តរាយតាមរយៈការធ្វើសកម្មភាពសុខភាពសាធារណៈការត្រៀមបង្ការ ការកាត់បន្ថយ ការឆ្លើយតបនិងការធ្វើឱ្យល្អប្រសើរឡើងវិញ។

គោលដៅយុទ្ធសាស្ត្រនៃផែនការនេះគឺដើម្បីពង្រឹងវិស័យសុខាភិបាលឱ្យមានសមត្ថភាពគ្រប់គ្រាន់សម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងត្រៀមបង្ការសម្រាប់គ្រោះអាសន្នការឆ្លើយតប និងការស្តារឡើងវិញ

នៅក្នុងវិស័យសុខាភិបាល ដើម្បីកាត់បន្ថយផលអវិជ្ជមានសម្រាប់សហគមន៍ និងប្រព័ន្ធសេវាថែទាំសុខភាព បង្កើនភាពធន់នៃគ្រោះអាសន្នគ្រោះមហន្តរាយ និងវិបត្តិដទៃទៀត។

គោលដៅជាក់លាក់នៃផែនការយុទ្ធសាស្ត្រនេះគឺដើម្បីបង្កើនសមត្ថភាពរបស់ក្រសួងសុខាភិបាលទាក់ទងទៅនឹងគ្រប់ដំណាក់កាលទាំងអស់នៃវដ្តគ្រប់គ្រងហានិភ័យគ្រោះអាសន្នផ្នែកសុខភាពពោលគឺការបង្ការការត្រៀមរៀបចំការឆ្លើយតប និងការស្តារឡើងវិញ។ ដោយចាប់ផ្តើមពីការវិភាគស្ថានភាពបច្ចុប្បន្នផែនការនេះកំណត់ចំនួនដែលសំខាន់សម្រាប់វាស់វែងគោលដៅប្រតិបត្តិរយៈពេល៥ឆ្នាំ(២០២០-២០២៤)។

## ៥ ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ផែនការនេះ បានផ្តោតលើគ្រោះថ្នាក់ធម្មជាតិ ពិសេសផ្តោតលើគ្រោះទឹកជំនន់-រាំងស្ងួត និងខ្យល់ព្យុះស្របតាមគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានកំណត់។ ក្របខ័ណ្ឌនេះ ផ្តោតទៅលើការដោះស្រាយមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិដោយការបំពេញបង្គ្រប់ និងសកម្មភាពប្រកបដោយប្រសិទ្ធភាពបន្ថែមជាមួយយុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមដែលមានស្រាប់ ដើម្បីស្រាវជ្រាវរកនិងឆ្លើយតបទៅនឹងព្រឹត្តិការណ៍ និងគ្រោះអាសន្នសុខភាពសាធារណៈការរាតត្បាតនៃជំងឺឆ្លងជាដំបូងដូចដែលតម្រូវឡើងដោយវេទិកាឆ្លើយតបមនុស្សធម៌។ គោលការណ៍ណែនាំដែលត្រូវបានប្រើក្នុងការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រនេះ ត្រូវបានរាយនៅក្នុងឧបសម្ព័ន្ធទី៦។

### ៥.១ ការវិភាគជាយុទ្ធសាស្ត្រ

ការវិភាគជាយុទ្ធសាស្ត្រត្រូវបានធ្វើឡើងដោយផ្អែកលើក្របខ័ណ្ឌសកម្មភាពរបស់អង្គការសុខភាពពិភពលោក(ខែធ្នូឆ្នាំ២០១២) ដែលក្នុងនោះគោលបំណងចម្បងគឺកំណត់សមាសភាពទាំងបួន ដើម្បីលើកកម្ពស់សមត្ថភាពជាតិក្នុងការគ្រប់គ្រងគ្រោះអាសន្ន និងគ្រោះមហន្តរាយផ្នែកសុខភាពឱ្យកាន់តែប្រសើរ។

១-អភិបាលកិច្ចនិងភាពជាអ្នកដឹកនាំ និងយន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព

២-ពង្រឹងការគ្រប់គ្រងពត៌មាននិងចំណេះដឹង

៣-បង្កើនការត្រៀមជាស្រេចនៃការផ្តល់សេវាសុខភាព

៤-លើកកម្ពស់សមត្ថភាពធនធាន(ធនធានមនុស្សសម្ភារនិងធនធានហិរញ្ញវត្ថុ)។

សមាសធាតុនៃក្របខ័ណ្ឌយុទ្ធសាស្ត្រថ្នាក់តំបន់នេះ សមស្របជាមួយសសរស្តម្ភនៃផែនការយុទ្ធសាស្ត្រសុខាភិបាល (សូមមើលរូបភាពទី១)។ សមាសភាពទាំង៤សម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយអង្គការសុខភាពពិភពលោកប្រចាំអាស៊ីប៉ាស៊ីហ្វិកខាងលិច ក្របខ័ណ្ឌសុខភាពនិងយុទ្ធសាស្ត្រសុខាភិបាល៖

| | ការផ្តល់សេវាសុខភាព | ថវិកាថែទាំសុខភាព | ធនធានមនុស្សសម្រាប់សុខភាព | ប្រព័ន្ធពត៌មានសុខាភិបាល | ប្រព័ន្ធសុខាភិបាលអភិបាលកិច្ច |
|---|---|---|---|---|---|
| ភាពជាអ្នកដឹកនាំសម្របសម្រួល | | | | | X |
| ពត៌មានចំណេះដឹងនិងការគ្រប់គ្រង | X | | | X | |
| ការផ្តល់សេវាសុខភាព | | | | | |
| ធនធាន | | X | X | | |

ផ្អែកលើការវិភាគដោយប្រើសមាសភាព ដែលមានបញ្ជាក់ខាងលើទាំង៤សកម្មភាពចាំបាច់នានា ត្រូវបានកំណត់សម្រាប់ឆ្នាំ២០២០-២០២៤ ក្នុងអំឡុងសិក្ខាសាលារៀបចំផែនការជាតិស្តីពីការគ្រប់គ្រងហានិភ័យ

គ្រោះមហន្តរាយសម្រាប់សុខភាពចំនួនពីរវគ្គដែលបានប្រព្រឹត្តិទៅកាលពីចុងឆ្នាំ២០១៩ និងដើមឆ្នាំ២០២០។ តារាងទី១ ខាងក្រោមនេះ សង្ខេបសកម្មភាពជាអាទិភាពដែលបានកំណត់សម្រាប់សមាសភាពទាំង៤ និង

យោងទៅតាមដំណាក់កាលនីមួយៗនៃវដ្តគ្រប់គ្រងហានិភ័យ។ សកម្មភាពជាអក្សរដិតគឺជាអាទិភាពដែលត្រូវអនុវត្តសម្រាប់ឆ្នាំ២០២០-២០២៤។

## តារាងទី១ តារាងយុទ្ធសាស្ត្រអាទិភាព

| វដ្តនៃការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ | អភិបាលកិច្ចគោលនយោបាយនិងការសម្របសម្រួល | ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង | ការផ្តល់សេវាសុខភាព | ធនធាន |
|---|---|---|---|---|
| បង្ការការប្រឈមនិងកាត់បន្ថយភាពងាយរងគ្រោះ | -ពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យសុខាភិបាល<br>-អនុម័តនិងអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព ២០២០-២០២៤<br>-រៀបចំគោលនយោបាយជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព<br>-រៀបចំការប្រើប្រាស់ថវិកាហិរញ្ញប្បទានរបស់ជាតិនិងពីប្រភពផ្សេងៗ ក្នុងករណីនៃគ្រោះមហន្តរាយនិងការ | -ពង្រឹងការផ្លាស់ប្តូរព័ត៌មានសុខាភិបាលប្រចាំសប្តាហ៍ជាផ្លូវការរវាងនា.ការពារសុខភាព(ការិ.គ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន)នា.ប្រយុទ្ធនឹងជំងឺឆ្លងនិងនា.ផែនការនិងព័ត៌មានសុខាភិបាល<br>-ធ្វើបច្ចុប្បន្នភាពផែនទីនៃទីតាំងមូលដ្ឋានសុខាភិបាលសាធារណៈ<br>-កំណត់តំបន់ដែលមានហានិភ័យខ្ពស់និងតំបន់ដែលមានសេវាសុខភាពគ្របដណ្តប់ទាប<br>-យករបាយការណ៍សុខភាពប្រចាំសប្តាហ៍"របាយការណ៍សូន្យ" ពីកិច្ចប្រជុំគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនិងការឆ្លើយតបពីអង្គការមនុស្សធម៌ផ្សេងៗ | -ធ្វើឱ្យមានដំណើរការឡើងវិញនូវកម្មវិធី"សុវត្ថិភាពមន្ទីរពេទ្យ"ដោយផ្តោតលើតំបន់ហានិភ័យខ្ពស់<br>-ជួសជុល កសាងពង្រឹងឬប្តូរទីតាំងមូលដ្ឋានសុខាភិបាលនៅក្នុងទីតាំងដែលមានហានិភ័យខ្ពស់ | -ស្នើសុំថវិកាសម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយក្នុងវិស័យសុខាភិបាល<br>-ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយដល់បុគ្គលិកសុខាភិបាលគ្រប់កម្រិត<br>-ស្វែងរកកន្លែងដែលមានហានិភ័យនៃគ្រោះមហន្តរាយខ្ពស់ សម្រាប់គម្រោងកាត់បន្ថយហានិភ័យដោយសហការពីសហគមន៍អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន |

| | | | | |
|---|---|---|---|---|
| | ធានាឱ្យបាននូវបទដ្ឋានស្រប នៅទូទាំងប្រទេស<br>-រៀបចំគោលការណ៍ណែនាំ សម្រាប់កសាងផែនការត្រៀម បម្រុងឆ្លើយតបគ្រោះមហន្ត រាយថ្នាក់ក្រោមជាតិ | -ប្រើទិន្នន័យសុខភាពដើម្បីជូន ដំណឹងដល់ថ្នាក់ដឹកនាំ ដែលគ្រប់ គ្រងហានិភ័យគ្រោះមហន្តរាយ វិស័យផ្សេងទៀត។ | | |
| ការត្រៀមរៀបចំជាមុន | -រៀបចំផែនការត្រៀមបម្រុង សម្រាប់ឆ្លើយតបនឹងគ្រោះ មហន្តាយសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>-រៀបចំនិតិវិធីទម្រង់ការ សម្រាប់ការទំនាក់ទំនងជា មួយនឹងជំនួយពីដៃគូជាតិ និងអន្តរជាតិរបស់ក្រសួង សុខាភិបាល | -បញ្ចូលមុខវិជ្ជាសិក្សាស្តីពីការគ្រប់ គ្រងហានិភ័យនៃគ្រោះមហន្តរាយ ក្នុងកម្មវិធីសិក្សាជាតិសម្រាប់គ្រឹះ ស្ថានសិក្សា<br>-ពង្រឹងប្រព័ន្ធប្រកាសឱ្យដឹងមុន (Early Warning System) ពីមុខសញ្ញាគ្រោះថ្នាក់(Hazard) ក្នុងវិស័យសុខាភិបាល<br>-ប៉ាន់ប្រមាណនិងតាមដានភាព ងាយរងគ្រោះនិងសមត្ថភាពប្រជា ជនដោយប្រើឧបករណ៍វាយតម្លៃ និយាម<br>-រៀបចំកម្មវិធីសិក្សាសំណុំសេវា សុខភាពអប្បបរមាដំបូង (MISP) សម្រាប់សុខភាពបន្តពូជផ្លូវភេទរួម | -កំណត់ឡើងវិញប្រព័ន្ធបញ្ជូននិង ការត្រៀមខ្លួនជាស្រេចនៅគ្រប់ រាជធានី/ ខេត្ត<br>-ពង្រឹងកិច្ចសហប្រតិបត្តិការរវាង សុខាភិបាលនិងអង្គភាពពាក់ព័ន្ធ (នគរបាល កងទ័ព អង្គភាពពន្លត់ អគ្គីភ័យ កាកបាទក្រហមកម្ពុជា។ ល។)<br>-អភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ "សន្ទុះ កើនឡើង"ជាបន្តបន្ទាប់ក្នុងផែនការ គ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដោយ សមាសភាពនៃសេវាសុខភាពផ្សេងៗ គ្នាដើម្បីធ្វើការផ្សព្វផ្សាយនិងបណ្តុះ បណ្តាលដល់មន្ត្រីសុខាភិបាល | -បញ្ចូលថវិការត្រៀមបម្រុងសម្រាប់ ឆ្លើយតបទៅក្នុងផែនការប្រតិបត្តិ ប្រចាំឆ្នាំ<br>-បច្ចុប្បន្នភាពទិន្នន័យនៃការបណ្តុះ បណ្តាលលើការងារគ្រប់គ្រងគ្រោះ មហន្តរាយនិងមន្ត្រីជំនាញនៅក្នុង ប្រព័ន្ធទិន្នន័យធនធានមនុស្សដែល មានស្រាប់ក្នុងអង្គភាពសាមី<br>-អភិវឌ្ឍយន្តការដែលមានស្រាប់ សម្រាប់ ចល័តបុគ្គលិកសង្គ្រោះពី រាជធានីទៅខេត្តនិងពីខេត្តទៅខេត្ត និងក្នុងខេត្តនៅពេលមានសន្ទុះកើន ឡើងលឿននៃមុខសញ្ញាគ្រោះថ្នាក់"<br>-កំណត់ពីឧបករណ៍ និងសម្ភារដែល ចាំបាច់តាមរយៈការវាយតម្លៃ និងការ |

| | | | | |
|---|---|---|---|---|
| | | ទាំងការបង្ការអំពើហិង្សាយេនឌ័រ<br>-បណ្ដុះបណ្ដាលជនបង្គោលគ្រោះមហន្តរាយថ្នាក់ជាតិ និងក្រោមជាតិស្ដីពីប្រព័ន្ធMISP សុខភាពបន្តពូជ សុខភាពផ្លូវភេទ រួមទាំងការការពារអំពើហិង្សាយេនឌ័រ (GBV) | ពាក់ព័ន្ធ | វិភាគហានិភ័យ<br>-កំណត់តម្រូវការសំណុំសេវាអប្បបរមាដំបូង(MISP) សម្រាប់សុខភាពបន្តពូជ-ផ្លូវភេទដើម្បីស្នើសុំប្រើប្រាស់សម្ភារMISP ក្នុងពេលមានគ្រោះអាសន្ន និងគ្រោះមហន្តរាយដែលមិនអាចគ្រប់គ្រងបានដោយប្រកាស<br>-កែសម្រួលឧបករណ៍សង្គ្រោះបន្ទាន់ប្រសិនបើចាំបាច់<br>-ធានាបាននូវការរក្សាទុកសម្ភារបរិក្ខារក្នុងទីតាំងសមស្រប<br>-ត្រួតពិនិត្យគុណភាពសម្ភារបរិក្ខារ និងស្តុកមានសុវត្ថិភាព |
| ការឆ្លើយតប | -ជំរុញយន្តការសម្របសម្រួលឱ្យបានជិតស្និទ្ធជាមួយដៃគូ (អង្គការ និងសប្បុរសជន) ដែលនៅតំបន់មានគ្រោះមហន្តរាយ<br>-ការផ្ដល់ជំនួយសង្គ្រោះបន្ទាន់ត្រូវយកចិត្តទុកដាក់លើមូលហេតុដ៏សំខាន់មួយនៃការ | -ពង្រឹងប្រព័ន្ធប្រកាសឱ្យដឹងមុន (Early Warning System)ពីមុខសញ្ញាគ្រោះថ្នាក់(Hazard)ក្នុងវិស័យសុខាភិបាល<br>-ប្រើទិន្នន័យសុខភាព ដើម្បីកៀរគរជំនួយ និងដើម្បីជូនដំណឹងដល់អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាដើម្បីធ្វើការឆ្លើយតប | -រៀបចំផ្ដល់សេវាសុខភាពជាបណ្ដោះអាសន្ននិងដាក់ពង្រាយក្រុមគ្រូពេទ្យចល័តនិងពហុវិស័យនៅកន្លែងដែលសេវាសុខាភិបាលមិនទាន់ដំណើរការ<br>-ផ្ដល់សេវាសុខភាពជាមូលដ្ឋាននិងការអប់រំសុខភាពចំពោះជនរងគ្រោះដោយគ្រោះមហន្តរាយ(ផ្ដល់ថ្នាំបង្ការការថែទាំបឋម របួស សុខភាពផ្លូវចិត្ត | -ឆ្លើយតបតាមការវិភាគហានិភ័យ<br>-ប្រមូលផ្ដុំស្តុកទុកការផ្គត់ផ្គង់វេជ្ជសាស្ត្រ និងឧបករណ៍អប្បបរមសំខាន់<br>-ធានាថារាជធានី-ខេត្ត/ក្រុង / ស្រុកដែលមានការប៉ះពាល់មានមូលនិធិគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ<br>-តាមដាននិងរៀបចំផែនការដើម្បីធានាបាននិរន្តរភាពនៃបុគ្គលិកការ |

| | | | | |
|---|---|---|---|---|
| | ស្លាប់ និងក្រុមជនងាយរងគ្រោះច្រើនបំផុត។ | | និងសុខភាពបន្តពូជ“MISP” ជាដើម) | ផ្គត់ផ្គង់និងលំហូរសាច់ប្រាក់ |
| ការស្តារឡើងវិញ | -សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធសម្រាប់ការស្តារឡើងវិញ និងការអភិវឌ្ឍ | -បន្ទាប់ពីព្រឹត្តិការណ៍កើតឡើងភ្លាមត្រូវធ្វើការវាយតម្លៃរហ័សពីផលប៉ះពាល់និងតម្រូវការលើសុខភាពនិងផ្សព្វផ្សាយ<br>-ពង្រឹងប្រព័ន្ធតាមដានជំងឺ<br>-ផ្តល់ទិន្នន័យសុខភាពដើម្បីជូនដំណឹងពីការស្តារឡើងវិញនៃវិស័យផ្សេងទៀត។ | -ប៉ាន់ប្រមាណ និងពង្រឹងមូលដ្ឋានផ្តល់ សេវាសុខាភិបាល<br>-ជំនួស និងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានសុខាភិបាលដោយបំពាក់ឧបករណ៍និងសម្ភារៈ<br>-ផ្តល់ប្រឹក្សាផ្នែកចិត្តសាស្ត្រ<br>-ចាប់ផ្តើមឡើងវិញនូវកម្មវិធីផ្តល់ថ្នាំបង្ការ។ល។ | -ប៉ាន់ប្រមាណតម្រូវការបុគ្គលិកក្រោយគ្រោះមហន្តរាយ<br>-កៀរគរធនធាន |

## តារាងទី២ ទិដ្ឋភាពរួមនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ សម្រាប់សុខភាព ឆ្នាំ២០២០-២០២៤

### ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ

**គោលបំណង:** ជីវិតនិងសុខុមាលភាពរបស់ប្រជាជននៅកម្ពុជាត្រូវបានការពារពីផលប៉ះពាល់នៃគ្រោះមហន្តរាយ ដោយកិច្ចអន្តរាគមន៍សុខភាពសាធារណៈសមស្រប

**គោលដៅ:** វិស័យសុខាភិបាលនៅប្រទេសកម្ពុជាមានសមត្ថភាពគ្រប់គ្រាន់ សម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយដោយកំណត់ផលប៉ះពាល់របស់ប្រជាជន ដោយមុខសញ្ញាគ្រោះថ្នាក់មួយចំនួន ដើម្បីបង្កើនភាពធន់នៃសហគមន៍ និងប្រព័ន្ធផ្តល់សេវាថែទាំសុខភាព ព្រមទាំងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននៃគ្រោះអាសន្នឬគ្រោះមហន្តរាយនានា។

| | | | |
|---|---|---|---|
| អភិបាលកិច្ច គោលនយោបាយនិង ការសម្របសម្រួល | ការគ្រប់គ្រង ព័ត៌មាននិងចំណេះដឹង | ការផ្តល់សេវា សុខភាព | ធនធាន (ធនធានមនុស្ស សម្ភារៈនិងហិរញ្ញវត្ថុ) |

### ៥.២ សកម្មភាព

ជំហានអាទិភាពទីមួយគឺពង្រឹងការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាននៃក្រសួងសុខាភិបាលដោយមានលក្ខខណ្ឌជាក់លាក់នៃសេចក្តីយោង (សូមមើលឧបសម្ព័ន្ធបានស្នើឡើងក្នុងក្របខ័ណ្ឌការងារ) និងចាំបាច់ផ្តល់នូវសិទ្ធិដែលជាការលើកទឹកចិត្ត និងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ ដោយសារតែធនធានហិរញ្ញវត្ថុ និងធនធានមនុស្សរបស់កម្ពុជានៅមានកំណត់ ការអនុវត្តយុទ្ធសាស្ត្រត្រូវតែជ្រើសរើសអាទិភាព និងការចំណាយឱ្យមានប្រសិទ្ធភាព។ តារាងទី២ ខាងក្រោមគឺការអនុវត្តផែនការលម្អិតនៃសកម្មភាពដោយមានគោលដៅបណ្តោះអាសន្នសម្រាប់ឆ្នាំ២០២០-២០២៤។

## តារាងទី៣ សកម្មភាពឆ្នាំ ២០២០-២០២៤

| ១-អភិបាលកិច្ចគោលនយោបាយ និងការសម្របសម្រួល | | | | | |
|---|---|---|---|---|---|
| **សកម្មភាព** | **ឆ្នាំ** | | | | |
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
| ១.១-ពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយក្នុងវិស័យសុខាភិបាល | -រៀបចំលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងសុខាភិបាល<br>-ពង្រឹងការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន<br>-ពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិក្នុងវិស័យសុខាភិបាល | -ពង្រឹងលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងសុខាភិបាល<br>-ពង្រឹងការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយនិងសុខភាពបរិស្ថាន<br>-ពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិក្នុងវិស័យសុខាភិបាល | -ពង្រឹងលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងសុខាភិបាល<br>-ពង្រឹងការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយនិងសុខភាពបរិស្ថាន<br>-ពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិក្នុងវិស័យសុខាភិបាល | -ពង្រឹងលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងសុខាភិបាល<br>-ពង្រឹងការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយនិងសុខភាពបរិស្ថាន<br>-ពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិក្នុងវិស័យសុខាភិបាល | -ពង្រឹងលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងសុខាភិបាល<br>-ពង្រឹងការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយនិងសុខភាពបរិស្ថាន<br>-ពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិក្នុងវិស័យសុខាភិបាល |
| ១.២-អនុម័តនិងអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព២០២០-២០២៤ | ផែនការយុទ្ធសាស្ត្រជាតិនឹងត្រូវបានអនុម័ត ផ្សព្វផ្សាយ និងអនុវត្ត | អនុវត្តផែនការពិនិត្យតាមដាន | អនុវត្តផែនការ ពិនិត្យតាមដាននិងវាយតម្លៃ | អនុវត្តផែនការបន្តពិនិត្យតាមដាន | អង្កេតនិងវាយតម្លៃលទ្ធផលសម្រេចបាន |
| ១.៣-រៀបចំគោលនយោបាយជាតិស្តីពី ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព | រៀបចំគោលនយោបាយជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព | បន្តរៀបចំគោលនយោបាយគ្រោះមហន្តរាយជាតិសម្រាប់សុខភាព | បន្តរៀបចំគោលនយោបាយគ្រោះមហន្តរាយជាតិសម្រាប់សុខភាពបានអនុម័តនិងបោះពុម្ព ផ្សព្វផ្សាយ និងអនុវត្ត | គោលនយោបាយគ្រោះមហន្តរាយជាតិសម្រាប់សុខភាពបានអនុវត្ត | ពិនិត្យវាយតម្លៃឡើងវិញគោលនយោបាយគ្រោះមហន្តរាយជាតិសម្រាប់សុខភាពបានអនុវត្ត |

| | | | | | |
|---|---|---|---|---|---|
| ១.៤-រៀបចំការប្រើប្រាស់ថវិកាហិរញ្ញប្បទានរបស់ជាតិ និងពីប្រភពផ្សេងៗ ក្នុងករណីនៃគ្រោះមហន្តរាយនិងការធានាឱ្យបាននូវបទដ្ឋានស្របនៅទូទាំងប្រទេស | រៀបចំផែនការថវិកានិងបទដ្ឋានច្បាស់លាស់ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា | រៀបចំផែនការថវិកា និងបទដ្ឋានច្បាស់លាស់ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា | អនុម័តនិងអនុវត្តផែនការថវិកា និង បទដ្ឋានច្បាស់លាស់ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា | អនុវត្តផែនការថវិកា និងបទដ្ឋានច្បាស់លាស់ ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា | ពិនិត្យវាយតម្លៃឡើងវិញនូវការអនុវត្តន៍ផែនការថវិកា និងបទដ្ឋានច្បាស់លាស់ ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា |
| ១.៥-រៀបចំគោលការណ៍ណែនាំសម្រាប់កសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ | | -រៀបចំគោលការណ៍ណែនាំសម្រាប់កសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ<br>-អនុម័តគោលការណ៍ណែនាំសម្រាប់កសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ | ផ្សព្វផ្សាយនិងអនុវត្តគោលការណ៍ណែនាំសម្រាប់កសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ | ពិនិត្យ និងវាយតម្លៃលើគោលការណ៍ណែនាំសម្រាប់កសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ | ពិនិត្យ និងវាយតម្លៃលើគោលការណ៍ណែនាំសម្រាប់កសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ |
| ១.៦-រៀបចំផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះមហន្តាយសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | -នាយកដ្ឋានការពារសុខភាពមានផែនការត្រៀមបម្រុងសម្រាប់ថ្នាក់ជាតិនិងក្រោមជាតិ | ធ្វើបច្ចុប្បន្នភាពផែនការត្រៀមបម្រុងសម្រាប់ថ្នាក់ជាតិ និងក្រោមជាតិ | ធ្វើបច្ចុប្បន្នភាពផែនការត្រៀមបម្រុងសម្រាប់ថ្នាក់ជាតិ និងក្រោមជាតិ | ធ្វើបច្ចុប្បន្នភាពផែនការត្រៀមបម្រុងសម្រាប់ថ្នាក់ជាតិ និងក្រោមជាតិ |
| ១.៧-ពិនិត្យឡើងវិញនិងអនុវត្តនូវនិយាមជាតិនៃការផ្តល់សេវាសុខភាពជាសារវ័ន្ត និងការថែទាំទៅតាមកម្រិត | | ពិនិត្យ កែសម្រួល រៀបចំ និងអនុម័តគោលការណែនាំស្តីពីកញ្ចប់សេវាសុខភាពដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ | អនុវត្តគោលការណែនាំស្តីពីកញ្ចប់សេវាសុខភាពដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ | អនុវត្តគោលការណែនាំស្តីពីកញ្ចប់សេវាសុខភាពដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ | ពិនិត្យឡើងវិញនូវលទ្ធផលនៃការអនុវត្តន៏គោលការណែនាំស្តីពីកញ្ចប់សេវាសុខភាពដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ |
| ១.៨-រៀបចំនិតិវិធីទម្រង់ការសម្រាប់ការទំនាក់ទំនងជាមួយនឹងជំនួយពីដៃគូជាតិនិងអន្តរជាតិរបស់ក្រសួងសុខាភិបាល | | រៀបចំនិតិវិធី និងទម្រង់ការសម្រាប់ទំនាក់ទំនងនឹងដៃគូរជាតិ និងអន្តជាតិ | មាននិតិវិធី និងទម្រង់ការសម្រាប់ទំនាក់ទំនងជាមួយដៃគូរជាតិ និងអន្តជាតិ | មាននិតិវិធី និងទម្រង់ការសម្រាប់ទំនាក់ទំនងជាមួយដៃគូរជាតិ និងអន្តជាតិ | មាននិតិវិធី និងទម្រង់ការសម្រាប់ទំនាក់ទំនងជាមួយដៃគូរជាតិ និងអន្តជាតិ |
| ១.៩-ជំរុញយន្តការសម្របសម្រួលឱ្យបាន | | ពិនិត្យ និងពង្រឹងយន្តការ | ពង្រឹងយន្តការសម្របសម្រួល | ពង្រឹងយន្តការសម្របសម្រួល | ពង្រឹងយន្តការសម្របសម្រួល |

| | | | | | |
|---|---|---|---|---|---|
| ជិតស្និទ្ធជាមួយដៃគូ(អង្គការ និងសប្បុរសជន) ដែលនៅ តំបន់មានគ្រោះមហន្តរាយ | | សម្របសម្រួលនេះ ដើម្បីឱ្យមានប្រសិទ្ធភាព | នេះ ដើម្បីឱ្យមានប្រសិទ្ធភាព | នេះ ដើម្បីឱ្យមានប្រសិទ្ធភាព | នេះ ដើម្បីឱ្យមានប្រសិទ្ធភាព |
| ១.១០-សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធសម្រាប់ការស្តារឡើងវិញ និងការអភិវឌ្ឍ | | | -រៀបចំក្រុមការងារប៉ាន់ប្រមាណការខូចខាត និងតម្រូវការស្តារឡើងវិញ និងអភិវឌ្ឍ<br>-ពង្រឹងសមត្ថភាពក្រុមការងារ និងនាក់ទំនងសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធ | ពង្រឹងសមត្ថភាពក្រុមការងារ និងទំនាក់ទំនងសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធ | ពង្រឹងសមត្ថភាពក្រុមការងារ និងទំនាក់ទំនងសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធ |
| **២-ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង** | | | | | |
| **សកម្មភាព** | **ឆ្នាំ** | | | | |
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
| ២.១-ពង្រឹងការផ្លាស់ប្តូរព័ត៌មានសុខាភិបាលប្រចាំសប្តាហ៍ជាផ្លូវការរវាងនាយកដ្ឋានការពារសុខភាព(ការិ.គ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន) នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល | បង្កើតការប្រជុំប្រចាំត្រីមាសរវាងនាយកដ្ឋានការពារសុខភាព នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល | បង្កើតការប្រជុំប្រចាំត្រីមាសរវាងនាយកដ្ឋានការពារសុខភាព នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល | បង្កើតការប្រជុំប្រចាំត្រីមាសរវាងនាយកដ្ឋានការពារសុខភាព នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល | បង្កើតការប្រជុំប្រចាំត្រីមាសរវាងនាយកដ្ឋានការពារសុខភាព នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល | បង្កើតការប្រជុំប្រចាំត្រីមាសរវាងនាយកដ្ឋានការពារសុខភាព នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល |
| ២.២-ធ្វើបច្ចុប្បន្នភាពផែនទីនៃទីតាំងមូលដ្ឋានសុខាភិបាលសាធារណៈ | ធ្វើបច្ចុប្បន្នភាពផែនទីនៃទីតាំងមូលដ្ឋានសុខាភិបាលឱ្យបាន ១០០% | ធ្វើបច្ចុប្បន្នភាពផែនទីនៃទីតាំងមូលដ្ឋានសុខាភិបាលឱ្យបាន ១០០% | ធ្វើបច្ចុប្បន្នភាពផែនទីនៃទីតាំងមូលដ្ឋានសុខាភិបាលឱ្យបាន ១០០% | ធ្វើបច្ចុប្បន្នភាពផែនទីនៃទីតាំងមូលដ្ឋានសុខាភិបាលឱ្យបាន ១០០% | ធ្វើបច្ចុប្បន្នភាពផែនទីនៃទីតាំងមូលដ្ឋានសុខាភិបាលឱ្យបាន ១០០% |
| ២.៣-កំណត់តំបន់ដែលមានហានិភ័យខ្ពស់ និងតំបន់ដែលមានសេវាសុខភាពគ្របដណ្តប់ទាប | វិភាគ និងវាយតម្លៃតំបន់ដែលមានហានិភ័យខ្ពស់ និងតំបន់ដែលមានការគ្របដណ្តប់សេវាសុខភាពទាប | ជំរឿនពលរដ្ឋដែលរស់នៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់ និងតំបន់ដែលមានការគ្របដណ្តប់សេវាសុខភាពទាប | ប៉ាន់ប្រមានតម្រូវការសម្រាប់ការត្រៀម និងឆ្លើយតប និងការស្តារឡើងវិញ | ប៉ាន់ប្រមានតម្រូវការសម្រាប់ការត្រៀម និងឆ្លើយតប និងការស្តារឡើងវិញ | ប៉ាន់ប្រមានតម្រូវការសម្រាប់ការត្រៀម និងឆ្លើយតប និងការស្តារឡើងវិញ |

| | | | | | |
|---|---|---|---|---|---|
| ២.៤-ប៉ាន់ប្រមាណនិងតាមដានភាពងាយរងគ្រោះ និងសមត្ថភាពប្រជាជន ដោយប្រើឧបករណ៍វាយតម្លៃនិយាម | | ការចាប់ផ្ដើមពិភាក្សារវាងនាយកដ្ឋានការពារសុខភាព និងគ្រឹះស្ថានបណ្ដុះបណ្ដាល | ឧបករណ៍ត្រូវបានរៀបចំ | ឧបករណ៍ដែលធ្វើហើយត្រូវបានធ្វើតេស្ត | -ការអង្កេតចាប់ផ្ដើមធ្វើនៅក្នុងខេត្តចំនួនបួន<br>-ផ្សព្វផ្សាយលទ្ធផលអង្កេត |
| ២.៥-បញ្ចូលមុខវិជ្ជាសិក្សាស្ដីពីការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយក្នុងកម្មវិធីសិក្សាជាតិសម្រាប់គ្រឹះស្ថានសិក្សាសុខាភិបាលរដ្ឋនិងឯកជន | ដាក់បញ្ចូលកម្មវិធីសិក្សាទៅក្នុងគ្រឹះស្ថានបណ្ដុះបណ្ដាលទាំងរដ្ឋនិងឯកជន | ចាប់ផ្ដើមពិភាក្សារវាងនាយកដ្ឋានការពារសុខភាព និងសកលវិទ្យាល័យ | រៀបចំកម្មវិធីសិក្សា និងអនុម័ត | វគ្គសិក្សាចាប់ផ្ដើម | -វាយតម្លៃវគ្គសិក្សា<br>-កែសម្រួលកម្មវិធីសិក្សាបើចាំបាច់ |
| ២.៦-បង្កើតនិងបណ្ដុះបណ្ដាលក្រុមការងារដើម្បីធ្វើការប៉ាន់ប្រមាណរហ័សផ្នែកសុខភាព | | ជ្រើសរើសក្រុមប៉ាន់ប្រមាណថ្នាក់ខេត្ត និងបណ្ដុះបណ្ដាល | បណ្ដុះបណ្ដាល និងបំប៉ន | បណ្ដុះបណ្ដាល និងបំប៉ន | បណ្ដុះបណ្ដាល និងបំប៉ន |
| ២.៧-បន្ទាប់ពីព្រឹត្តិការណ៍កើតឡើងភ្លាមត្រូវធ្វើការវាយតម្លៃរហ័សពីផលប៉ះពាល់ និងតម្រូវការលើសុខភាពនិងផ្សព្វផ្សាយ | មន្ទីរសុខាភិបាលនិងក្រុមការងារពាក់ពន្ធ័ចុះធ្វើការវាយតម្លៃ ដោយប្រើឧបករណ៍វាយតម្លៃ | មន្ទីរសុខាភិបាល និងក្រុមការងារពាក់ពន្ធ័ចុះធ្វើការវាយតម្លៃដោយប្រើឧបករណ៍វាយតម្លៃ | មន្ទីរសុខាភិបាល និងក្រុមការងារពាក់ពន្ធ័ចុះធ្វើការវាយតម្លៃដោយប្រើឧបករណ៍វាយតម្លៃ | មន្ទីរសុខាភិបាល និងក្រុមការងារពាក់ពន្ធ័ចុះធ្វើការវាយតម្លៃដោយប្រើឧបករណ៍វាយតម្លៃ | មន្ទីរសុខាភិបាល និងក្រុមការងារពាក់ពន្ធ័ចុះធ្វើការវាយតម្លៃដោយប្រើឧបករណ៍វាយតម្លៃ |
| ២.៨-ប្រើទិន្នន័យសុខភាពដើម្បីកៀរគរជំនួយ និងដើម្បីជូនដំណឹងដល់អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាដើម្បីធ្វើការឆ្លើយតប | តាមដានតាមរយៈគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងផ្សព្វផ្សាយទិន្នន័យសុខភាព | តាមដានតាមរយៈគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងផ្សព្វផ្សាយទិន្នន័យសុខភាព | តាមដានតាមរយៈគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងផ្សព្វផ្សាយទិន្នន័យសុខភាព | តាមដានតាមរយៈគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងផ្សព្វផ្សាយទិន្នន័យសុខភាព | តាមដានតាមរយៈគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងផ្សព្វផ្សាយទិន្នន័យសុខភាព |
| ២.៩-រៀបចំកម្មវិធីសិក្សាសំណុំសេវាសុខភាពអប្បបរមាដំបូង (MISP) សម្រាប់សុខភាពបន្តពូជផ្លូវភេទ រួមទាំងការបង្ការអំពើហិង្សាយេនឌ័រ | អនុម័តកម្មវិធីបណ្ដុះបណ្ដាលស្ដីពី MISP(នាយកដ្ឋានការពារសុខភាព ក្រសួងសុខាភិបាល) | | | | អនុម័តកម្មវិធីបណ្ដុះបណ្ដាលស្ដីពី MISP(នាយកដ្ឋានការពារសុខភាព ក្រសួងសុខាភិបាល) |
| ២.១០-បណ្ដុះបណ្ដាលជនបង្គោល គ្រោះមហន្តរាយថ្នាក់ជាតិនិងក្រោមជាតិស្ដីពីប្រព័ន្ធ MISP សុខភាពបន្តពូជសុខភាពផ្លូវភេទរួម | បណ្ដុះបណ្ដាលជនបង្គោលគ្រោះមហន្តរាយខេត្តស្ដីពីប្រព័ន្ធMISP សុខភាពបន្តពូជសុខភាពផ្លូវភេទរួមទាំងការការពារអំពើហិង្សា | បណ្ដុះបណ្ដាលមន្ត្រីសុខាភិបាលនៅOD មណ្ឌលសុខភាពស្ដីពីប្រព័ន្ធ MISP សុខភាពបន្តពូជសុខភាពផ្លូវភេទរួមទាំងការ | បណ្ដុះបណ្ដាលនិងរំលឹកមន្ត្រីសុខាភិបាលនៅOD មណ្ឌលសុខភាពស្ដីពីប្រព័ន្ធ MISPសុខភាពបន្តពូជសុខភាពផ្លូវភេទរួមទាំង | បណ្ដុះបណ្ដាលនិងរំលឹកមន្ត្រីសុខាភិបាលនៅOD មណ្ឌលសុខភាពស្ដីពីប្រព័ន្ធMISP សុខភាពបន្តពូជសុខភាពផ្លូវភេទរួមទាំង | បណ្ដុះបណ្ដាលនិងរំលឹកមន្ត្រីសុខាភិបាលនៅOD មណ្ឌលសុខភាពស្ដីពីប្រព័ន្ធMISPសុខភាពបន្តពូជសុខភាពផ្លូវភេទរួមទាំង |

| | | | | | |
|---|---|---|---|---|---|
| ទាំងការការពារអំពើហិង្សាយេនឌ័រ (GBV) | យេនឌ័រ(GBV) | ការពារអំពើហិង្សា យេនឌ័រ (GBV) | ការការពារអំពើហិង្សាយេនឌ័រ (GBV) | ការការពារអំពើហិង្សា យេនឌ័រ(GBV) | ការការពារអំពើហិង្សា យេនឌ័រ (GBV) |
| ២.១១ពង្រឹងប្រព័ន្ធប្រកាសឱ្យដឹងមុន(Early Warning System )ពីមុខសញ្ញាគ្រោះថ្នាក់ (Hazard)ក្នុងវិស័យសុខាភិបាល | ពិនិត្យឡើងវិញនូវយន្តការប្រព័ន្ធប្រកាសឱ្យដឹងមុននិងសមាសភាពមន្ត្រីទទួលបន្ទុកការងារគ្រប់គ្រងគ្រោះមហន្តរាយ | រៀបចំយន្តការប្រព័ន្ធប្រកាសឱ្យដឹងមុន និងបណ្តុះបណ្តាលសមាសមន្ត្រីបង្គោលទទួលបន្ទុក | ពិនិត្យប្រព័ន្ធប្រកាសឱ្យដឹងមុន និងបណ្តុះបណ្តាលរំលឹកសមាសភាពមន្ត្រីបង្គោលទទួលបន្ទុក | ពិនិត្យប្រព័ន្ធប្រកាសឱ្យដឹងមុន និងបណ្តុះបណ្តាលរំលឹកសមាសភាពមន្ត្រីបង្គោលទទួលបន្ទុក | ពិនិត្យប្រព័ន្ធប្រកាសឱ្យដឹងមុន និងបណ្តុះបណ្តាលរំលឹកសមាសភាពមន្ត្រីបង្គោលទទួលបន្ទុក |
| **៣-ការផ្តល់សេវាសុខភាព និងសំណុំសេវាអប្បបរមាដំបូងសម្រាប់សុខភាពបន្តពូជ(MISP)** | | | | | |
| **សកម្មភាព** | **ឆ្នាំ** | | | | |
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
| ៣.១-ធ្វើឱ្យមានដំណើរការឡើងវិញនូវកម្មវិធីសុវត្ថិភាពមន្ទីរពេទ្យ"ដោយផ្តោតលើតំបន់ហានិភ័យខ្ពស់ | នាយកដ្ឋានការពារសុខភាពដាក់សំណើធ្វើឱ្យមានដំណើរការឡើងវិញនូវកម្មវិធី"សុវត្ថិភាពមន្ទីរពេទ្យ" ជូនថ្នាក់ដឹកនាំក្រសួងសម្រេច | ធ្វើឱ្យមានដំណើរការឡើងវិញនូវកម្មវិធី"សុវត្ថិភាពមន្ទីរពេទ្យ" តាមមូលដ្ឋានសុខាភិបាល | ដំណើរការបន្ត និងត្រួតពិនិត្យឡើងវិញ | ដំណើរការបន្ត និងត្រួតពិនិត្យឡើងវិញ | ដំណើរការបន្តនិងធ្វើការវាយតម្លៃ |
| ៣.២-ជួសជុល កសាងពង្រឹងឬប្តូរទីតាំងមូលដ្ឋានសុខាភិបាលនៅក្នុងទីតាំងដែលមានហានិភ័យខ្ពស់ | កំណត់បានចំនួនទីតាំងដែលមានហានិភ័យខ្ពស់និងទីតាំងដែលត្រូវជួសជុលឡើងវិញ | ជ្រើសរើសទីតាំងអាទិភាពធ្វើមុន និងជួសជុល សាងសង់ | ធ្វើបន្ត | ធ្វើបន្ត | វាយតម្លៃឡើងវិញ |
| ៣.៣-កំណត់ឡើងវិញប្រព័ន្ធបញ្ជូននិងការត្រៀមខ្លួនជាស្រេចនៅគ្រប់រាជធានី/ ខេត្ត | -ត្រួតពិនិត្យគុណភាពនៃប្រព័ន្ធបញ្ជូន<br>-ពង្រឹង បំពេញបន្ថែម និងជួសជុលឡើងវិញ | -ត្រួតពិនិត្យគុណភាពនៃប្រព័ន្ធបញ្ជូន<br>-ពង្រឹងបំពេញបន្ថែមនិងជួសជុលឡើងវិញ | -ត្រួតពិនិត្យគុណភាពនៃប្រព័ន្ធបញ្ជូន<br>-ពង្រឹង បំពេញបន្ថែម និងជួសជុលឡើងវិញ | -ត្រួតពិនិត្យគុណភាពនៃប្រព័ន្ធបញ្ជូន<br>-ពង្រឹងបំពេញបន្ថែមនិងជួសជុលឡើងវិញ | --ត្រួតពិនិត្យគុណភាពនៃប្រព័ន្ធបញ្ជូន<br>-ពង្រឹងបំពេញបន្ថែមនិងជួសជុលឡើងវិញ និងវាយតម្លៃ |
| ៣.៤-ពង្រឹងកិច្ចសហប្រតិបត្តិការរវាងសុខាភិបាល និងអង្គភាពពាក់ព័ន្ធ (នគរបាល កងទ័ព អង្គភាពពន្លត់ អគ្គីភ័យ កាកបាទក្រហមកម្ពុជា... )។ | -ត្រួតពិនិត្យយន្តការនៃកិច្ចសហប្រតិបត្តិការ<br>-ពង្រឹងកិច្ចសហការវាងអង្គភាពពាក់ព័ន្ធចូលរួមគ្រប់សកម្មភាព | -ត្រួតពិនិត្យយន្តការនៃកិច្ចសហប្រតិបត្តិការ<br>-បន្តពង្រឹងកិច្ចសហការវាងអង្គភាពពាក់ព័ន្ធចូលរួមគ្រប់សកម្មភាព | -ត្រួតពិនិត្យយន្តការនៃកិច្ចសហប្រតិបត្តិការ<br>-បន្តពង្រឹងកិច្ចសហការវាងអង្គភាពពាក់ព័ន្ធចូលរួមគ្រប់សកម្មភាព | -ត្រួតពិនិត្យយន្តការនៃកិច្ចសហប្រតិបត្តិការ<br>-បន្តពង្រឹងកិច្ចសហការវាងអង្គភាពពាក់ព័ន្ធចូលរួមគ្រប់សកម្មភាព | វាយតម្លៃឡើងវិញ |
| ៣.៥-អភិវឌ្ឍយុទ្ធសាស្រ្តសម្រាប់ "សន្ទុះកើន | នាយកដ្ឋានការពារសុខភាពរៀបចំ | ធ្វើការផ្សព្វផ្សាយនិងបណ្តុះ | ធ្វើការផ្សព្វផ្សាយនិងបណ្តុះ | ធ្វើការផ្សព្វផ្សាយនិងបណ្តុះ | វាយតម្លៃ |

| | | | | | |
|---|---|---|---|---|---|
| ឡើង"ជាបន្តបន្ទាប់ក្នុងផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដោយសមាសភាពនៃសេវាសុខភាពផ្សេងៗគ្នា ដើម្បីធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់មន្ត្រីសុខាភិបាលពាក់ព័ន្ធ | ការពិភាក្សាជាមួយនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រសន្ទុះកើនឡើង និងសុំការអនុម័តពីថ្នាក់ដឹកនាំក្រសួង | បណ្តាលបន្តដល់មន្ត្រីសុខាភិបាលពាក់ព័ន្ធ | បណ្តាលបន្តដល់មន្ត្រីសុខាភិបាលពាក់ព័ន្ធ | បណ្តាលបន្តដល់មន្ត្រីសុខាភិបាលពាក់ព័ន្ធ | |
| ៣.៦-ពង្រឹងយន្តការសហការគ្នារវាង នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ដែលមានមជ្ឈមណ្ឌលប្រតិបត្តិការគ្រោះបន្ទាន់(EOC: Emergency Operations Center)នៅក្រសួងសុខាភិបាល | រៀបចំការប្រជុំជាប្រចាំមួយត្រីមាសម្តងរវាងនាយកដ្ឋានការពារសុខភាព និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងតាមការចាំបាច់ | រៀបចំការប្រជុំជាប្រចាំមួយត្រីមាសម្តងរវាងនាយកដ្ឋានការពារសុខភាព និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនិងតាមការចាំបាច់ | រៀបចំការប្រជុំជាប្រចាំមួយត្រីមាសម្តងរវាងនាយកដ្ឋានការពារសុខភាព និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនិងតាមការចាំបាច់ | រៀបចំការប្រជុំជាប្រចាំមួយត្រីមាសម្តងរវាងនាយកដ្ឋានការពារសុខភាព និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនិងតាមការចាំបាច់ | វាយតម្លៃ |
| ៣.៧-បង្កើតនិងពង្រឹងយន្តការនៃការសម្របសម្រួលក្នុងការរៀបចំនិងឆ្លើយតបនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនៅក្នុង MISP-SRH រួមទាំងការការពារអំពើហិង្សាប្រឆាំងនឹងផ្លូវភេទ | បង្កើតនិងពង្រឹងយន្តការនៃការសម្របសម្រួល ក្នុងការត្រៀមរៀបចំតាមរយៈការបណ្តុះបណ្តាល MISP រយៈពេល៥ថ្ងៃ | ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបន្តដោយសហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស | ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបន្តដោយសហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស | ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបន្តដោយសហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស | វាយតម្លៃ |
| ៣.៨-រៀបចំផ្តល់សេវាសុខភាពជាបណ្តោះអាសន្ននិងដាក់ពង្រាយក្រុមគ្រូពេទ្យចល័តនិងពហុវិស័យនៅកន្លែងដែលសេវាសុខាភិបាលមិនទាន់ដំណើរការ | បង្កើតក្រុមការងារត្រៀមសង្គ្រោះនិងបណ្តុះបណ្តាល | ធ្វើបច្ចុប្បន្នភាពសមាសភាពនិងបន្តពង្រឹងសមត្ថភាពក្រុមការងារនិងបណ្តុះបណ្តាល | ធ្វើបច្ចុប្បន្នភាពសមាសភាពនិងបន្តពង្រឹងសមត្ថភាពក្រុមការងារនិងបណ្តុះបណ្តាល | ធ្វើបច្ចុប្បន្នភាពសមាសភាពនិងបន្តពង្រឹងសមត្ថភាពក្រុមការងារនិងបណ្តុះបណ្តាល | វាយតម្លៃ |
| ៣.៩-បំបាត់នូវរាល់ឧបសគ្គទាំងឡាយណាដែលមិនអាចទទួល និងផ្តល់សេវាថែទាំសុខភាពបានចំពោះជនរងគ្រោះដោយគ្រោះមហន្តរាយឧ.មិនយកថ្លៃសេវានិង | កំណត់គោលការណ៍នៃការផ្តល់និងទទួលសេវាសុខភាពឱ្យបានច្បាស់លាស់ចំពោះជនរងគ្រោះដោយគ្រោះមហន្តរាយ | ផ្សព្វផ្សាយ និងអនុវត្ត | ផ្សព្វផ្សាយ និងអនុវត្ត | ផ្សព្វផ្សាយ និងអនុវត្ត | វាយតម្លៃ |

| | | | | | |
|---|---|---|---|---|---|
| ពង្រីកការផ្តល់សេវាមូលដ្ឋាន | | | | | |
| ៣.១០-ផ្តល់សេវាសុខភាពជាមូលដ្ឋាននិងការអប់រំសុខភាពចំពោះជនរងគ្រោះដោយគ្រោះមហន្តរាយ(ផ្តល់ថ្នាំបង្ការ ការថែទាំបឋម របួស សុខភាពផ្លូវចិត្ត និងសុខភាពបន្តពូជ "MISP" ជាដើម) | អនុវត្តតាមគោលការណ៍ណែនាំរបស់កម្មវិធីជាតិពាក់ព័ន្ធ | អនុវត្តតាមគោលការណ៍ណែនាំរបស់កម្មវិធីជាតិពាក់ព័ន្ធ | អនុវត្តតាមគោលការណ៍ណែនាំរបស់កម្មវិធីជាតិពាក់ព័ន្ធ | អនុវត្តតាមគោលការណ៍ណែនាំរបស់កម្មវិធីជាតិពាក់ព័ន្ធ | វាយតម្លៃ |
| ៣.១១-ប៉ាន់ប្រមាណនិងពង្រឹងមូលដ្ឋានផ្តល់សេវាសុខាភិបាល | ចុះធ្វើការប៉ានប្រមាណសេចក្តីត្រូវការតាមមូលដ្ឋានសេវាសុខាភិបាល | -ចុះធ្វើការប៉ានប្រមាណសេចក្តីត្រូវការតាមមូលដ្ឋានសេវាសុខាភិបាល<br>-បំពេញបន្ថែមទៅតាមលទ្ធផលនៃការប៉ានប្រមាណ | -ចុះធ្វើការប៉ានប្រមាណសេចក្តីត្រូវការតាមមូលដ្ឋានសេវាសុខាភិបាល<br>-បំពេញបន្ថែមទៅតាមលទ្ធផលនៃការប៉ានប្រមាណ | -ចុះធ្វើការប៉ានប្រមាណសេចក្តីត្រូវការតាមមូលដ្ឋានសេវាសុខាភិបាល<br>-បំពេញបន្ថែមទៅតាមលទ្ធផលនៃការប៉ានប្រមាណ | វាយតម្លៃ |
| ៣.១២-ជំនួសនិងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានសុខាភិបាលដោយបំពាក់ឧបករណ៍និងសម្ភារៈ | វាយតម្លៃនិងប៉ាន់ប្រមាណនូវមូលដ្ឋានសុខាភិបាល និងសម្ភារដែលមានស្រាប់ | ធ្វើផែនការដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រតិបត្តិអនុវត្តផែនការ | កែសម្រួលផែនការ<br>ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រតិបត្តិ<br>និងវាយតម្លៃ<br>អនុវត្តផែនការ | កែសម្រួលផែនការ<br>ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រតិបត្តិ<br>និងវាយតម្លៃ<br>អនុវត្តផែនការ | វាយតម្លៃ |
| ៣.១៣-ចាប់ផ្តើមឡើងវិញនូវកម្មវិធីផ្តល់ថ្នាំបង្ការ។ល។ | អនុវត្តតាមគោលការណ៍ណែនាំរបស់កម្មវិធីជាតិ | អនុវត្តតាមគោលការណ៍ណែនាំរបស់កម្មវិធីជាតិ | អនុវត្តតាមគោលការណ៍ណែនាំរបស់កម្មវិធីជាតិ | អនុវត្តតាមគោលការណ៍ណែនាំរបស់កម្មវិធីជាតិ | វាយតម្លៃ |

**៤-ធនធាន**

| **សកម្មភាព** | **ឆ្នាំ** | | | | |
|---|---|---|---|---|---|
| | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
| ៤.១-ស្នើសុំថវិកាសម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយក្នុងវិស័យសុខាភិបាល | លើកគម្រោងផែនការថវិកាជាតិឬដៃគូរអភិវឌ្ឍន៍ប្រចាំឆ្នាំនិងស្នើសុំអនុម័តពីថ្នាក់ដឹកនាំក្រសួង | លើកគម្រោងផែនការថវិកាជាតិឬដៃគូរអភិវឌ្ឍន៍ប្រចាំឆ្នាំនិងស្នើសុំអនុម័តពីថ្នាក់ដឹកនាំក្រសួង | លើកគម្រោងផែនការថវិកាជាតិឬដៃគូរអភិវឌ្ឍន៍ប្រចាំឆ្នាំនិងស្នើសុំអនុម័តពីថ្នាក់ដឹកនាំក្រសួង | លើកគម្រោងផែនការថវិកាជាតិឬដៃគូរអភិវឌ្ឍន៍ប្រចាំឆ្នាំនិងស្នើសុំអនុម័តពីថ្នាក់ដឹកនាំក្រសួង | លើកគម្រោងផែនការថវិកាជាតិឬដៃគូរអភិវឌ្ឍន៍ប្រចាំឆ្នាំនិងស្នើសុំអនុម័តពីថ្នាក់ដឹកនាំក្រសួង |
| ៤.២-ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង | -ពិនិត្យកែសម្រួលកម្មវិធិសិក្សាពី | -ផ្តល់វគ្គបណ្តុះបណ្តាលចំនួន | -ផ្តល់វគ្គបណ្តុះបណ្តាលចំនួន | -ផ្តល់វគ្គបណ្តុះបណ្តាលចំនួន | -ផ្តល់វគ្គបណ្តុះបណ្តាលចំនួន |

| | | | | | |
|---|---|---|---|---|---|
| ហានិភ័យនៃគ្រោះមហន្តរាយដល់បុគ្គលិកសុខាភិបាលគ្រប់កម្រិត | ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ<br>-រៀបចំគម្រោងផែនការសម្រាប់ការបណ្តុះបណ្តាល<br>-ផ្តល់វគ្គបណ្តុះបណ្តាលចំនួន ១០%នៃចំនួនសរុបដែលត្រូវបណ្តុះបណ្តាល | ២៥%នៃចំនួនសរុបដែលត្រូវបណ្តុះបណ្តាល | ២៥%នៃចំនួនសរុបដែលត្រូវបណ្តុះបណ្តាល | ២៥%នៃចំនួនសរុបដែលត្រូវបណ្តុះបណ្តាល | ២៥%នៃចំនួនសរុបដែលត្រូវបណ្តុះបណ្តាល និងវាយតម្លៃ |
| ៤.៣-ស្វែងរកកន្លែងដែលមានហានិភ័យនៃគ្រោះមហន្តរាយខ្ពស់សម្រាប់គម្រោងកាត់បន្ថយហានិភ័យដោយសហការពីសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន | -សិក្សាពីតំបន់ដែលមានហានិភ័យខ្ពស់<br>-កំណត់ផែនទីអំពីតំបន់ដែលមានហានិភ័យខ្ពស់<br>-ផែនការផ្សព្វផ្សាយ | -បន្តធ្វើការផ្សព្វផ្សាយដល់បណ្តាខេត្តដែលមានហានិភ័យខ្ពស់ និងសុំសហការពីសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន | -បន្តធ្វើការផ្សព្វផ្សាយដល់បណ្តាខេត្តដែលមានហានិភ័យខ្ពស់ និងសុំសហការពីសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន | -បន្តធ្វើការផ្សព្វផ្សាយដល់បណ្តាខេត្តដែលមានហានិភ័យខ្ពស់ និងសុំសហការពីសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន | -បន្តធ្វើការផ្សព្វផ្សាយដល់បណ្តាខេត្តដែលមានហានិភ័យខ្ពស់ និងសុំសហការពីសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន<br>-វាយតម្លៃ |
| ៤.៤-បញ្ចូលថវិកាត្រៀមបម្រុងសម្រាប់ឆ្លើយតបទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ | -ធ្វើការប៉ាន់ប្រមាណថវិកាត្រៀមបម្រុង<br>-លើកគម្រោងថវិកាត្រៀមបម្រុងទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ | -ធ្វើការប៉ាន់ប្រមាណថវិកាត្រៀមបម្រុង<br>-លើកគម្រោងថវិកាត្រៀមបម្រុងទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ | -ធ្វើការប៉ាន់ប្រមាណថវិកាត្រៀមបម្រុង<br>-លើកគម្រោងថវិកាត្រៀមបម្រុងទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ | -ធ្វើការប៉ាន់ប្រមាណថវិកាត្រៀមបម្រុង<br>-លើកគម្រោងថវិកាត្រៀមបម្រុងទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ | -ធ្វើការប៉ាន់ប្រមាណថវិកាត្រៀមបម្រុង<br>-លើកគម្រោងថវិកាត្រៀមបម្រុងទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ<br>-វាយតម្លៃ |
| ៤.៥-បច្ចុប្បន្នភាពទិន្នន័យនៃការបណ្តុះបណ្តាលលើការងារគ្រប់គ្រងគ្រោះមហន្តរាយ និងមន្ត្រីជំនាញនៅក្នុងប្រព័ន្ធទិន្នន័យធនធានមនុស្សដែលមានស្រាប់ក្នុងអង្គភាពសាមុី | -ប្រមូលទិន្នន័យនៃការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងគ្រោះមហន្តរាយ និងមន្ត្រីជំនាញ<br>-បច្ចុប្បន្នភាពទិន្នន័យក្នុងរយៈពេល៣ខែម្តង | -ប្រមូលទិន្នន័យនៃការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងគ្រោះមហន្តរាយនិងមន្ត្រីជំនាញ<br>-បច្ចុប្បន្នភាពទិន្នន័យក្នុងរយៈពេល៣ខែម្តង | -ប្រមូលទិន្នន័យនៃការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងគ្រោះមហន្តរាយនិងមន្ត្រីជំនាញ<br>-បច្ចុប្បន្នភាពទិន្នន័យក្នុងរយៈពេល៣ខែម្តង | -ប្រមូលទិន្នន័យនៃការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងគ្រោះមហន្តរាយនិងមន្ត្រីជំនាញ<br>-បច្ចុប្បន្នភាពទិន្នន័យក្នុងរយៈពេល៣ខែម្តង | -ប្រមូលទិន្នន័យនៃការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងគ្រោះមហន្តរាយនិងមន្ត្រីជំនាញ<br>-បច្ចុប្បន្នភាពទិន្នន័យក្នុងរយៈ<br>-ពេល៣ខែម្តង<br>វាយតម្លៃ |

| | | | | | |
|---|---|---|---|---|---|
| ៤.៦-អភិវឌ្ឍយន្តការដែលមានស្រាប់ សម្រាប់ ចល័តបុគ្គលិក សង្គ្រោះពីរាជធានីទៅខេត្តនិង ពីខេត្តទៅខេត្តនិង ក្នុងខេត្ត នៅពេលមានសន្ទុះកើនឡើង លឿននៃមុខសញ្ញាគ្រោះថ្នាក់" | -ពង្រឹងយន្តការដែលមានស្រាប់ សម្រាប់ចល័តបុគ្គលិកសង្គ្រោះ ពីរាជធានីទៅខេត្ត និងពីខេត្ត ទៅខេត្ត និងក្នុងខេត្ត នៅពេល មានសន្ទុះកើនឡើងលឿននៃ ព្រឹត្តិការណ៍<br>-បង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រឹងយន្តការចល័ត | -ពង្រឹងយន្តការដែលមានស្រាប់ សម្រាប់ចល័តបុគ្គលិកសង្គ្រោះ ពីរាជធានីទៅខេត្ត និងពីខេត្ត ទៅខេត្ត និងក្នុងខេត្ត នៅពេល មានសន្ទុះកើនឡើងលឿននៃ ព្រឹត្តិការណ៍<br>-បង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រឹងយន្តការចល័ត | -ពង្រឹងយន្តការដែលមានស្រាប់ សម្រាប់ចល័តបុគ្គលិកសង្គ្រោះ ពីរាជធានីទៅខេត្ត និងពីខេត្ត ទៅខេត្ត និងក្នុងខេត្ត នៅពេល មានសន្ទុះកើនឡើងលឿននៃ ព្រឹត្តិការណ៍<br>-បង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រឹងយន្តការចល័ត | -ពង្រឹងយន្តការដែលមានស្រាប់ សម្រាប់ចល័តបុគ្គលិកសង្គ្រោះ ពីរាជធានីទៅខេត្ត និងពីខេត្ត ទៅខេត្ត និងក្នុងខេត្ត នៅពេល មានសន្ទុះកើនឡើងលឿននៃ ព្រឹត្តិការណ៍<br>-បង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រឹងយន្តការចល័ត | -ពង្រឹងយន្តការដែលមានស្រាប់ សម្រាប់ចល័តបុគ្គលិកសង្គ្រោះ ពីរាជធានីទៅខេត្ត និងពីខេត្ត ទៅខេត្ត និងក្នុងខេត្ត នៅពេល មានសន្ទុះកើនឡើងលឿននៃ ព្រឹត្តិការណ៍<br>-បង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រឹងយន្តការចល័ត<br>-វាយតម្លៃ |
| ៤.៧-កំណត់ពីឧបករណ៍និងសម្ភារដែលចាំបាច់តាមរយៈការវាយតម្លៃនិងការវិភាគហានិភ័យ | កំណត់ពីតម្រូវការឧបករណ៍ និងសម្ភារសម្រាប់ការឆ្លើយ តមគ្រោះមហន្តរាយដោយ ពិភាក្សារវាង នាយកដ្ឋាន ការពារសុខភាពនិងឃ្លាំង ឱសថកណ្តាល | កំណត់ពីតម្រូវការឧបករណ៍ និងសម្ភារសម្រាប់ការឆ្លើយតម គ្រោះមហន្តរាយដោយ ពិភាក្សារវាង នាយកដ្ឋាន ការពារសុខភាពនិងឃ្លាំង ឱសថកណ្តាល | កំណត់ពីតម្រូវការឧបករណ៍ និងសម្ភារសម្រាប់ការឆ្លើយ តមគ្រោះមហន្តរាយដោយ ពិភាក្សារវាង នាយកដ្ឋាន ការពារសុខភាពនិងឃ្លាំង ឱសថកណ្តាល | កំណត់ពីតម្រូវការឧបករណ៍ និងសម្ភារសម្រាប់ការឆ្លើយតម គ្រោះមហន្តរាយដោយ ពិភាក្សារវាង នាយកដ្ឋាន ការពារសុខភាពនិងឃ្លាំង ឱសថកណ្តាល | កំណត់ពីតម្រូវការឧបករណ៍ និងសម្ភារសម្រាប់ការឆ្លើយ តមគ្រោះមហន្តរាយដោយ ពិភាក្សារវាង នាយកដ្ឋាន ការពារសុខភាពនិងឃ្លាំង ឱសថកណ្តាល |
| ៤.៨-កំណត់តម្រូវការសំណុំសេវាអប្បបរមាដំបូង(MISP) សម្រាប់សុខភាពបន្តពូជ-ផ្លូវភេទ ដើម្បីស្នើសុំប្រើប្រាស់សម្ភារMISP ក្នុងពេលមានគ្រោះអាសន្ន និងគ្រោះមហន្តរាយដែលមិនអាចគ្រប់គ្រងបានដោយប្រកាសរាជរដ្ឋាភិបាល | កំណត់តម្រូវការតាមរយៈការ បណ្តុះបណ្តាលMISPទៅខេត្ត ដែលងាយរងគ្រោះអាសន្ន/ គ្រោះមហន្តរាយ | កំណត់តម្រូវការតាមរយៈការ បណ្តុះបណ្តាលMISPទៅខេត្ត ដែលងាយរងគ្រោះអាសន្ន/ គ្រោះមហន្តរាយ | កំណត់តម្រូវការតាមរយៈការ បណ្តុះបណ្តាលMISPទៅខេត្ត ដែលងាយរងគ្រោះអាសន្ន/ គ្រោះមហន្តរាយ | កំណត់តម្រូវការតាមរយៈការ បណ្តុះបណ្តាលMISPទៅខេត្ត ដែលងាយរងគ្រោះអាសន្ន/ គ្រោះមហន្តរាយ | កំណត់តម្រូវការតាមរយៈការ បណ្តុះបណ្តាលMISPទៅខេត្ត ដែលងាយរងគ្រោះអាសន្ន/ គ្រោះមហន្តរាយ |
| ៤.៩-កែសម្រួលឧបករណ៍សង្គ្រោះបន្ទាន់ប្រសិនបើចាំបាច់ | -សិក្សានិងវាយតម្លៃឧបករណ៍ស ង្គ្រោះបន្ទាន់តាមស្ថានភាពជាក់ ស្តែង<br>-ធ្វើបច្ចុប្បន្នភាពឃីតឧបករណ៍ សង្គ្រោះ | -សិក្សានិងវាយតម្លៃឧបករណ៍ សង្គ្រោះបន្ទាន់តាមស្ថានភាព ជាក់ស្តែង<br>-ធ្វើបច្ចុប្បន្នភាពឃីតឧបករណ៍ សង្គ្រោះ | -សិក្សានិងវាយតម្លៃឧបករណ៍ស ង្គ្រោះបន្ទាន់តាមស្ថានភាពជាក់ ស្តែង<br>-ធ្វើបច្ចុប្បន្នភាពឃីតឧបករណ៍ សង្គ្រោះ | -សិក្សានិងវាយតម្លៃឧបករណ៍ សង្គ្រោះបន្ទាន់តាមស្ថានភាព ជាក់ស្តែង<br>-ធ្វើបច្ចុប្បន្នភាពឃីតឧបករណ៍ សង្គ្រោះ | -សិក្សានិងវាយតម្លៃឧបករណ៍ សង្គ្រោះបន្ទាន់តាមស្ថានភាព ជាក់ស្តែង<br>-ធ្វើបច្ចុប្បន្នភាពឃីតឧបករណ៍ សង្គ្រោះ |
| ៤.១០-ធានាបាននូវការរក្សាទុកសម្ភារបរិក្ខារ | រក្សាទុកសម្ភារបរិក្ខារក្នុងទីតាំងៈ | រក្សាទុកសម្ភារបរិក្ខារក្នុងទីតាំងៈ | រក្សាទុកសម្ភារបរិក្ខារក្នុងទីតាំងៈ | រក្សាទុកសម្ភារបរិក្ខារក្នុងទីតាំងៈ | រក្សាទុកសម្ភារបរិក្ខារក្នុងទីតាំងៈ |

| | | | | | |
|---|---|---|---|---|---|
| ក្នុងទីតាំងសមស្រប | -ថ្នាក់កណ្តាលនៅCMS<br>-ថ្នាក់ខេត្តនៅOD | -ថ្នាក់កណ្តាលនៅCMS<br>-ថ្នាក់ខេត្តនៅOD | -ថ្នាក់កណ្តាលនៅCMS<br>-ថ្នាក់ខេត្តនៅOD | -ថ្នាក់កណ្តាលនៅCMS<br>-ថ្នាក់ខេត្តនៅOD | -ថ្នាក់កណ្តាលនៅCMS<br>-ថ្នាក់ខេត្តនៅOD<br>វាយតម្លៃ |
| ៤.១១-ត្រួតពិនិត្យគុណភាពសម្ភារបរិក្ខារ និងស្តុកមានសុវត្ថិភាព | -ចុះបញ្ជីសារពើភណ្ឌ<br>-ត្រួតពិនិត្យតាមបញ្ជីផ្ទៀងផ្ទាត់រួមរៀងរាល់ត្រីមាស | -ចុះបញ្ជីសារពើភណ្ឌ<br>-ត្រួតពិនិត្យតាមបញ្ជីផ្ទៀងផ្ទាត់រួមរៀងរាល់ត្រីមាស | -ចុះបញ្ជីសារពើភណ្ឌ<br>-ត្រួតពិនិត្យតាមបញ្ជីផ្ទៀងផ្ទាត់រួមរៀងរាល់ត្រីមាស | -ចុះបញ្ជីសារពើភណ្ឌ<br>-ត្រួតពិនិត្យតាមបញ្ជីផ្ទៀងផ្ទាត់រួមរៀងរាល់ត្រីមាស | -ចុះបញ្ជីសារពើភណ្ឌ<br>-ត្រួតពិនិត្យតាមបញ្ជីផ្ទៀងផ្ទាត់រួមរៀងរាល់ត្រីមាស<br>-វាយតម្លៃ |
| ៤.១២-ឆ្លើយតបតាមការវិភាគហានិភ័យ | សូមអានយុទ្ធសាស្រ្តទី១ខាងលើ | សូមអាន យុទ្ធសាស្រ្តទី១ខាងលើ | សូមអាន យុទ្ធសាស្រ្តទី១ខាងលើ | សូមអាន យុទ្ធសាស្រ្តទី១ខាងលើ | សូមអាន យុទ្ធសាស្រ្តទី១ខាងលើ |
| ៤.១៣-ប្រមូលផ្តុំស្តុកទុកការផ្គត់ផ្គង់វេជ្ជសាស្រ្ត និងឧបករណ៍អប្បបរមាសំខាន់ | សូមអាចលើចំណុច៤.១០ខាងលើ | សូមអាចលើចំណុច៤.១០ ខាងលើ | សូមអាចលើចំណុច៤.១០ ខាងលើ | សូមអាចលើចំណុច៤.១០ ខាងលើ | សូមអាចលើចំណុច៤.១០ ខាងលើ |
| ៤.១៤-ធានាថារាជធានី-ខេត្ត/ក្រុង / ស្រុកដែលមានការប៉ះពាល់មានមូលនិធិគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ | សូមអាចលើចំណុច៤.៣ខាងលើ | សូមអាចលើចំណុច៤.៣ខាងលើ | សូមអាចលើចំណុច៤.៣ខាងលើ | សូមអាចលើចំណុច៤.៣ខាងលើ | សូមអាចលើចំណុច៤.៣ខាងលើ |
| ៤.១៥-តាមដាន និងរៀបចំផែនការ ដើម្បីធានាបាននិរន្តរភាពនៃបុគ្គលិកការផ្គត់ផ្គង់និងលំហូរសាច់ប្រាក់ | -ត្រួតពិនិត្យតាមបញ្ជីផ្ទៀងផ្ទាត់រួមរៀងរាល់ឆ្នាំ<br>-រៀបចំផែនការនិងអភិបាលកិច្ច | -ត្រួតពិនិត្យតាមបញ្ជីផ្ទៀងផ្ទាត់រួមរៀងរាល់ឆ្នាំ<br>-រៀបចំផែនការនិងអភិបាលកិច្ច | -ត្រួតពិនិត្យតាមបញ្ជីផ្ទៀងផ្ទាត់រួមរៀងរាល់ឆ្នាំ<br>-រៀបចំផែនការនិងអភិបាលកិច្ច | -ត្រួតពិនិត្យតាមបញ្ជីផ្ទៀងផ្ទាត់រួមរៀងរាល់ឆ្នាំ<br>-រៀបចំផែនការនិងអភិបាលកិច្ច | -ត្រួតពិនិត្យតាមបញ្ជីផ្ទៀងផ្ទាត់រួមរៀងរាល់ឆ្នាំ<br>-រៀបចំផែនការនិងអភិបាលកិច្ច<br>-វាយតម្លៃ |
| ៤.១៦-ប៉ាន់ប្រមាណតម្រូវការបុគ្គលិកក្រោយគ្រោះមហន្តរាយ | រៀបចំឧបករណ៍ប៉ាន់ប្រមាណដោយបញ្ជាក់ពីមុខនាទីទទួលខុសត្រូវឱ្យបានច្បាស់លាស់ | ធ្វើការប៉ាន់ប្រមាណដោយបញ្ជាក់ពីមុខនាទីទទួលខុសត្រូវឱ្យបានច្បាស់លាស់ | ធ្វើការប៉ាន់ប្រមាណដោយបញ្ជាក់ពីមុខនាទីទទួលខុសត្រូវឱ្យបានច្បាស់លាស់ | ធ្វើការប៉ាន់ប្រមាណដោយបញ្ជាក់ពីមុខនាទីទទួលខុសត្រូវឱ្យបានច្បាស់លាស់ | -ធ្វើការប៉ាន់ប្រមាណដោយបញ្ជាក់ពីមុខនាទីទទួលខុសត្រូវឱ្យបានច្បាស់លាស់<br>-វាយតម្លៃ |

## ៦ ធនធានហិរញ្ញវត្ថុ និងការអនុវត្ត

### ៦.១ ធនធានហិរញ្ញវត្ថុ

ធនធានហិរញ្ញវត្ថុ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះនឹងបានមកពីប្រភពថវិកាដែលអាចមានចំនួនបីដូចមានបញ្ជាក់ក្នុងតារាងទី៣ ដូចខាងក្រោម។

**តារាងទី៤ ប្រភពថវិកា**

| ប្រភព | គោលបំណង/អាទិភាពសម្រាប់ការប្រើប្រាស់ថវិកា |
|---|---|
| ថវិការដ្ឋ | ដើម្បីគាំទ្រដល់ការចំណាយប្រតិបត្តិការស្នូលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងសមត្ថភាពចាំបាច់ សម្រាប់អនុវត្តវដ្តគ្រប់គ្រងហានិភ័យដែលរួមមានការបង្ការការត្រៀមរៀបចំជាមុនការឆ្លើយតបនិងការស្តារឡើងវិញ។ |
| ថវិកាម្ចាស់ជំនួយរួមគ្នា ឧទា. កម្មវិធីទ្រទ្រង់វិស័យសុខាភិបាលជំហានទី២ | ដើម្បីគាំទ្រដល់ការពង្រឹងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ សម្រាប់សុខភាព រចនាសម្ព័ន្ធ/គោលនយោបាយ និងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ សម្រាប់សុខភាព។ |
| ថវិកាសង្គ្រោះបន្ទាន់ដោយមានការគាំទ្រពីវេទិកាឆ្លើយតបមនុស្សធម៌ | ដើម្បីគាំទ្រដល់សកម្មភាពរយៈពេលខ្លីនៅក្នុងស្ថានភាពធ្ងន់ធ្ងរខ្លាំងមានលទ្ធភាពដែលមានស្រាប់ចំនួនបី៖<br>-ថវិកាជំនួយជាសាច់ប្រាក់សង្គ្រោះបន្ទាន់<br>-ថវិកាបានពីឱកាសឆ្លើយតបបន្ទាន់<br>-ថវិកាបានពីការអំពាវនាវរហ័ស<br>សម្រាប់ព័ត៌មានលម្អិតបន្ថែមសូមមើលគោលការណ៍ណែនាំស្តីពីថវិកាសង្គ្រោះបន្ទាន់របស់វេទិកាឆ្លើយតបមនុស្សធម៌នៅក្នុងផែនការត្រៀមបម្រុងឆ្លើយតប។ |

ថវិកាជំនួយផ្តល់នូវសក្តានុពលដ៏ធំធេងក្នុងការប្រើប្រាស់ជំនួយ ដើម្បីគាំទ្រដល់អាទិភាពរបស់រដ្ឋាភិបាល។ រហូតមកទល់ពេលនេះ ការប្រើប្រាស់ថវិកាម្ចាស់ជំនួយរួមគ្នាមានកម្រិតមិនស្មើគ្នាទៅលើការបណ្តុះបណ្តាលនិងការទិញបរិក្ខារដោយក្នុងនោះពុំមានការតាមដាន/ការផ្សារភ្ជាប់ឱ្យបានគ្រប់គ្រាន់ទៅលើការផ្លាស់ប្តូរនៃសកម្មភាពឡើយ។

### ៦.២ ការអនុវត្ត

ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ សម្រាប់សុខភាពតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការពីអង្គភាពនៅក្នុងក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ។ រដ្ឋលេខាធិការទទួលបន្ទុកនឹងទទួលខុសត្រូវក្នុងការធានាថា សកម្មភាពដែលមានបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រនេះត្រូវបានអនុវត្ត។ នាយកដ្ឋានឬស្ថាប័នរដ្ឋាភិបាល ដែលទទួលខុសត្រូវលើសកម្មភាពនីមួយៗ មានបញ្ជាក់នៅក្នុងឧសម្ព័ន្ធទី៥ស្តីពីសកម្មភាពជាអាទិភាព។ នៅទីណាដែលមាននាយកដ្ឋានជាច្រើនទទួលខុសត្រូវលើសកម្មភាពតែមួយ សកម្មភាពនោះនឹងត្រូវបានសម្របសម្រួលតាមរយៈកិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិភាក្សាអំពីសកម្មភាពនោះ។

ក្រុមការងារគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយសម្រាប់សុខភាពត្រូវធានាថាធនធានត្រូវបានបែងចែក (នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) យោងទៅតាមអាទិភាពដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិនេះ។ ការគាំទ្រផ្នែកលេខាធិការដ្ឋាននឹងត្រូវបានផ្តល់ជូនក្រុមការងារនេះ ដើម្បីជួយនៅក្នុងការងាររបស់ខ្លួន។

នាយកដ្ឋាននីមួយៗត្រូវទទួលខុសត្រូវក្នុងការរាយការណ៍អំពីវឌ្ឍនភាពនៃសកម្មភាពរបស់ពួកគេរៀងៗខ្លួនដល់ក្រុមការងារនេះ។ ចាំបាច់ត្រូវធ្វើការសម្របផែនការជាតិនេះ ជាមួយផែនការជាតិដទៃទៀតដែលទាក់ទងទៅនឹងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយដូចជា ផែនការជាតិស្តីពីការបង្ការ និងការប្រយុទ្ធនឹងជំងឺឆ្លងរាលដាលជាសកលជាដើម។

## ៧ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

ការត្រួតពិនិត្យតាមដានផែនការយុទ្ធសាស្ត្រជាតិនឹងត្រូវធ្វើឡើងតាមរយៈ

- ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព ដែលនឹងត្រូវធ្វើឡើងក្នុងឆ្នាំ២០២២ ហើយលទ្ធផលនឹងត្រូវបានប្រើប្រាស់ដើម្បីធ្វើការកែតម្រូវដែលចាំបាច់នានា ទៅលើសកម្មភាពដែលគ្រោងឡើងសម្រាប់រយៈពេលដែលនៅសេសសល់នៃយុទ្ធសាស្ត្រនេះ។
- ការពិនិត្យឡើងវិញប្រចាំឆ្នាំនៃសមត្ថភាពស្នូលអប្បបរមារបស់និយ័តកម្មសុខភាពអន្តរជាតិ(IHR)រួមទាំងគ្រោះអាសន្ននៃសុខភាពសាធារណៈផងដែរ។
- របាយការណ៍ប្រចាំឆ្នាំដែលនឹងត្រូវចងក្រង និងសរសេរដោយការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយនិងសុខភាពបរិស្ថាន។

# ឧបសម្ព័ន្ធទី១

## សំណើអំពីលក្ខខណ្ឌប្រតិបត្តិរបស់ការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន

## ការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន

ការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថានស្ថិតនៅក្នុងនាយកដ្ឋានការពារសុខភាព ត្រូវបានប្រគល់ភារកិច្ច ជាលេខាធិការដ្ឋានរបស់ក្រុមសម្របសម្រួលឆ្លើយតបបន្ទាន់ និងធ្វើឱ្យប្រសើរឡើងវិញ នៅក្នុងក្រសួងសុខាភិបាល។ ការិយាល័យនេះ ជួយក្រសួងសុខាភិបាលក្នុងការរៀបចំគោលនយោបាយ ផែនការ និងសេចក្ដីណែនាំ ព្រមទាំងសម្របសម្រួលជាមួយនាយកដ្ឋាននានា និងកម្មវិធីផ្សេងៗទៀត នៅក្នុងក្រសួងសុខាភិបាល មន្ទីរសុខាភិបាលរាជធានី-ខេត្ត និងរក្សាទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងដៃគូអន្តរជាតិក្នុងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ។ អាណត្តិរបស់ការិយាល័យនេះ បានគ្របដណ្ដប់ដំណាក់កាលទាំងអស់នៃវដ្តគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ គោលបំណងរបស់ការិយាល័យនេះគឺដើម្បីបង្កើនការប្រើប្រាស់ធនធាននានារបស់វិស័យសុខាភិបាលសម្រាប់គ្រប់គ្រងហានិភ័យគ្រោះមហន្តរាយឱ្យបានជាអតិបរិមា ដោយធ្វើឱ្យប្រសើរឡើងនៃការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការនៅគ្រប់កម្រិតរបស់ថ្នាក់ជាតិ និងអន្តរជាតិ។

### លក្ខខណ្ឌប្រតិបត្តិ

### ១-សម្របសម្រួល

- ធានាឱ្យមានការតាមដានទៀងទាត់ និងវាយតម្លៃចំពោះកិច្ចពិភាក្សា និងសេចក្ដីសម្រេចនៃក្រុមសម្របសម្រួលការឆ្លើយតបបន្ទាន់ និងធ្វើឱ្យប្រសើរឡើងវិញនៃក្រសួងសុខាភិបាល។
- ជួយក្នុងការរៀបចំគោលនយោបាយជាតិគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព នៅគ្រប់ដំណាក់កាលទាំងបួននៃវដ្តគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនេះ។
- ផ្តល់ដំបូន្មានដល់នាយកដ្ឋានផែនការ និងប្រព័ន្ធព័ត៌មានសុខាភិបាល លើបញ្ហាដែលទាក់ទងនឹងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។
- រួមចំណែកដល់ការពង្រឹងមជ្ឈមណ្ឌលប្រតិបត្តិការសម្រាប់គ្រោះអាសន្ន របស់ក្រសួងសុខាភិបាលក្នុងកិច្ចសម្របសម្រួលការឆ្លើយតបទៅនឹងឧបទ្ទវហេតុបន្ទាន់។
- រក្សាទំនាក់ទំនងប្រតិបត្តិជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដោយផ្តោតលើសមាសភាពនៃការជូនដំណឹងប្រកាសអាសន្នផែនការជម្លៀស និងយុទ្ធនាការនានា ដើម្បីកាត់បន្ថយហានិភ័យដែលមានស្រាប់ ឬជៀសវាងហានិភ័យថ្មី។
- រក្សាទំនាក់ទំនងប្រតិបត្តិការជាមួយអង្គការមនុស្សធម៌សហប្រជាជាតិនានា សម្រាប់ការអភិវឌ្ឍយុទ្ធសាស្ត្រ និងការធ្វើផែនការរួមគ្នាពាក់ព័ន្ធទៅនឹងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព គាំទ្រដោយទីភ្នាក់ងារអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងដៃគូផ្សេងៗទៀត។
- សម្របសម្រួលជាមួយនាយកដ្ឋានកម្មវិធីផ្សេងៗទៀត នៅក្នុងក្រសួងសុខាភិបាល និងជាមួយមន្ទីរសុខាភិបាលខេត្ត ដើម្បីជំរុញភាពធន់របស់សហគមន៍ តាមរយៈភាពជាដៃគូជាមួយសង្គមស៊ីវិលអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ ដោយផ្តោតអាទិភាពលើការថែទាំសុខភាព ការបង្ការនិងព្យាបាល។

### ២-ការគ្រប់គ្រងពត៌មាន

- ធានាពត៌មានសុខាភិបាល និងទស្សនៈវិស័យសុខភាព ត្រូវបានគេបញ្ចូលនៅក្នុងការវាយតម្លៃហានិភ័យពហុវិស័យនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងថ្នាក់មូលដ្ឋាន។
- សម្របសម្រួលជាមួយនាយកដ្ឋានកម្មវិធីផ្សេងៗទៀត នៅក្រសួងសុខាភិបាលក្នុងការបង្កើតនីតិវិធីសម្រាប់

ការគ្រប់គ្រង និងការប្រើប្រាស់ព័ត៌មាន និងចំណេះដឹងដែលបានមកពីការវាយតម្លៃហានិភ័យក្នុងចំណោមដៃគូពាក់ព័ន្ធជាមួយនឹងវិស័យសុខាភិបាល និងវិស័យផ្សេងទៀត។

- សម្របសម្រួលជាមួយនាយកដ្ឋាន និងកម្មវិធីនានា នៅក្រសួងសុខាភិបាល ដើម្បីបង្កើតគោលនយោបាយ យន្តការ និងនីតិវិធីផ្សេងៗ សម្រាប់ការប្រាស្រ័យទាក់ទងហានិភ័យ សម្រាប់សាធារណជន ប្រព័ន្ធផ្សព្វផ្សាយ និងក្រុមឆ្លើយតប។

## ៣-ការគាំទ្រដល់ការផ្តល់សេវាសុខភាពនៅក្នុងភាពអាសន្ន

- សម្របសម្រួលជាមួយនាយកដ្ឋាន និងកម្មវិធីនានា នៅក្រសួងសុខាភិបាលនិងជាមួយមន្ទីរសុខាភិបាលខេត្ត ក្នុងគោលបំណង ដើម្បីឱ្យសេវាសុខភាពត្រូវគ្នាជាមួយនឹងទម្រង់នៃមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យ ដែលត្រូវបានវាយតម្លៃនិងពិនិត្យតាមដាន នៅថ្នាក់ជាតិនិង ថ្នាក់ក្រោមជាតិ។
- សម្របសម្រួលជាមួយនាយកដ្ឋាននិងកម្មវិធីនានា ក្នុងគោលបំណង ដើម្បីសម្របតាមកញ្ចប់សេវាសុខភាព ដែលមានស្រាប់សម្រាប់ការឆ្លើយតបគ្រោះមហន្តរាយ។
- បង្កើតយុទ្ធសាស្ត្រ ដើម្បីនិរន្តរភាពនៃការផ្តល់សេវាសុខភាព និងយន្តការសម្រាប់ ប្រតិបត្តិការឆ្លើយតប និងធ្វើឱ្យប្រសើរឡើងវិញ៖
  - + កំណត់ស្តង់ដារយន្តការ និងនីតិវិធីប្រតិបត្តិការដើម្បីដាក់ឱ្យចំកន្លែង និងបង្កើតជាបណ្តោះអាសន្ន (តង់) និង/ឬ ហេដ្ឋារចនាសម្ព័ន្ធសុខភាពអន្តរកាល
  - + អភិវឌ្ឍយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងពេលមានហេតុការណ៍កើតឡើងមិនអាចទប់ទល់បានភ្លាមៗដើម្បីដាក់ពង្រាយក្រុមគ្រូពេទ្យចល័តពហុជំនាញ នៅកន្លែងដែលប្រព័ន្ធសុខាភិបាលមិនដំណើរការ
  - + អភិវឌ្ឍផែនការយថាភាព ដោយផ្អែកលើការវាយតម្លៃ និងការវិភាគអំពីកង្វះខាត នៃមុខសញ្ញាគ្រោះថ្នាក់ និងភាពងាយរងគ្រោះនៅនឹងកន្លែងតាមកម្រិតនៃការថែទាំ។
- ផ្តល់យោបល់ដល់នាយកដ្ឋានពាក់ព័ន្ធនៅក្នុងក្រសួងសុខាភិបាលក្នុងគោលបំណងអភិវឌ្ឍ និងលើកកម្ពស់ការផ្តួចផ្តើមមន្ទីរពេទ្យមានសុវត្ថិភាព និងមិនគ្រាន់តែគ្របដណ្តប់មន្ទីរពេទ្យប៉ុណ្ណោះទេ គឺមូលដ្ឋានសុខាភិបាលសំខាន់ៗទាំងអស់ដែលស្ថិតក្នុងតំបន់គ្រោះថ្នាក់ក៏ត្រូវចូលរួមដែរ។
- បង្កើតចំយន្តការវាយតម្លៃរហ័សពីសមត្ថភាពនៃមូលដ្ឋានសេវាសុខាភិបាល ដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយដើម្បីបន្តការផ្តល់សេវាបន្តទៀត។
- កំណត់ទីតាំងសម្រាប់មន្ទីរពេទ្យថ្មី និងមណ្ឌលសុខភាព តាមរយៈការវាយតម្លៃហានិភ័យ និងការសាងសង់ទីតាំងថ្មីណាមួយ ដោយយោងតាមក្រមនៃការសាងសង់ជាក់លាក់ទៅតាមហានិភ័យ។

## ៤-ការគ្រប់គ្រងធនធាន

- សម្របសម្រួលជាមួយនាយកដ្ឋានធនធានមនុស្សនៃក្រសួងសុខាភិបាលក្នុងការអភិវឌ្ឍជំនាញ និងបទពិសោធន៍នៅក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាពដែលមាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនិងថ្នាក់មូលដ្ឋាន។
- ផ្តល់ដំបូន្មានលើផែនការថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងយន្តការ ដើម្បីបំពេញនូវតម្រូវការបុគ្គលិកដែលត្រូវការពេលមានហេតុការណ៍កើនឡើងមិនអាចទប់ទល់បានភ្លាមៗ។
- កំណត់តម្រូវការ និងផ្តល់ដំបូន្មានលើការផ្គត់ផ្គង់បរិក្ខារវេជ្ជសាស្ត្រ និងឧបករណ៍សំខាន់ៗ តាមរយៈការវាយតម្លៃនិងការវិភាគហានិភ័យ ដើម្បីធានាបាននូវកម្រិតស្តុកអប្បបរមាក្នុងទីតាំងសមស្រប។
- ផ្តល់ដំបូន្មានលើនីតិវិធីសម្រាប់ការចុះកិច្ចសន្យាសង្គ្រោះបន្ទាន់ក្នុងការផ្គត់ផ្គង់បរិក្ខារវេជ្ជសាស្ត្រ និងសេវាសុខភាព។

- បង្កើត និងការដាក់ស្នើគោលនយោបាយ សម្រាប់ការផ្តល់មូលនិធិទៅគ្រប់ដណ្តប់សមាសភាពទាំងអស់នៃការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាព។
- ផ្តល់ដំបូន្មាន និងស្វែងរកការគាំទ្រមតិ ដើម្បីផ្តល់មូលនិធិយថាភាពសម្រាប់គ្រោះមហន្តរាយ។

## ឧបសម្ព័ន្ធទី២

## សេចក្តីស្នើគំរូស្តង់ដារ ផែនការត្រៀមបម្រុង

## សម្រាប់ឆ្លើយតបហានិភ័យសុខភាពពេលមានគ្រោះមហន្តរាយរបស់មន្ទីរសុខាភិបាលខេត្ត

**ខេត្ត**..............................................................................................

| ធាតុ | | |
|---|---|---|
| ១-សេណារីយ៉ូ | ១.១-តើនឹងមានអ្វី/អាចកើតឡើង ? | ទឹកជំនន់នឹងធ្វើឱ្យប្រជាជនរស់នៅដាច់ដោយឡែកពីគេ និងមានអានុភាពដល់អ្នកដទៃទៀតឱ្យស្វែងរកជម្រក និង/ឬត្រូវបានជម្លៀសទៅកាន់តំបន់មានសុវត្ថិភាព។ មណ្ឌលសុខភាពអាចនឹងត្រូវបានលិចទឹក និងមិនអាចដំណើរការបាន។ ប្រជាជនអាចធ្វើការបម្លាស់ទីជាមួយអាហារមួយចំនួនហើយនឹងយកសត្វពាហនៈទៅជាមួយនឹងពួកគាត់។ |
| | ១.២-តើមនុស្សប៉ុន្មាននាក់នឹងត្រូវរងផលប៉ះពាល់? តើនៅកន្លែងណា? | |
| | ១.៣-តើអ្វីជាមូលហេតុចម្បងនៃការស្លាប់ និងការកើតជំងឺ? | លង់ទឹក ពស់ចឹក របួស ជំងឺរាក ជំងឺផ្លូវដង្ហើមគ្រុនចាញ់ នឹងក្លាយជាមូលហេតុចម្បងនៃការស្លាប់ និងការកើតជំងឺ។ ករណីស្លាប់ និងករណីជំងឺនឹងកាន់តែកើនច្រើនឡើង ដែលបង្កឡើងដោយកង្វះនៃការទទួលបានការថែទាំសុខភាពសម្រាប់ស្ត្រីមានផ្ទៃពោះ និងអ្នកជំងឺរ៉ាំរ៉ៃ។ |
| ២-យុទ្ធសាស្ត្រឆ្លើយតប | តើអ្វីទៅជាកត្តាហានិភ័យដ៏សំខាន់ដែលត្រូវដោះស្រាយតើមានអ្វីខ្លះ? | -ធានាផ្តល់នូវការសង្គ្រោះបឋម សម្រាប់ករណី លង់ទឹក ពស់ចឹក និងរបួស<br>-ធានាផ្តល់នូវការព្យាបាលភ្លាមៗរាល់ករណីជំងឺរាក ជំងឺផ្លូវដង្ហើមនិងជំងឺគ្រុនចាញ់<br>-ធានាបន្តការព្យាបាលដល់អ្នកជំងឺរ៉ាំរ៉ៃ<br>-ធានាការថែទាំសមរម្យដល់ស្ត្រីមានផ្ទៃពោះកុមារកង្វះអាហារូបត្ថម្ភ និងករណីមានផលពិបាកនៃជំងឺ កំណត់ហានិភ័យសម្រាប់ជំងឺរាក ជំងឺផ្លូវដង្ហើម និងជំងឺគ្រុនចាញ់ ដោយធានាថានឹងផ្តល់ទឹកស្អាត និងបង្គន់អនាម័យ ជម្រកត្រឹមត្រូវនិងមុងដល់ប្រជាជនដែលរងផលប៉ះពាល់ទាំងអស់។ |

| | | |
|---|---|---|
| ៣-ការអនុវត្ត<br>ផែនការ | -តើយើងអាចសម្រេចបាននូវផែនការនេះឬទេ?<br>-តើយើងត្រូវការធ្វើអ្វីដើម្បីកាត់បន្ថយកត្តាហានិភ័យនេះ? | -ផ្តល់នូវសេវាព្យាបាលមូលដ្ឋានដល់ភូមិ/ផ្ទះដែលនៅដាច់ស្រយ៉ាល និងប្រជាជននៅក្នុងទីទួលសុវត្ថិភាព<br>-ផ្តល់ពត៌មានដល់ប្រជាជនពីស្ថានភាពមណ្ឌលសុខភាព (ពីពេល បើក/បិទ,កំពុងដំណើរការ/មិនអាចដំណើរការបានជាដើម)<br>-កំណត់អត្តសញ្ញាណ និងចុះឈ្មោះ បុគ្គលដែលមានហានិភ័យខ្ពស់ (ឧទាហរណ៍ ស្ត្រីមានផ្ទៃពោះ កុមារកង្វះអាហារូបត្ថម្ភ ជនពិការ អ្នកដែលមានផ្ទុកមេរោគអេដស៍ របេង ករណីជំងឺរ៉ាំរ៉ៃផ្សេងទៀត ដែលកំពុងទទួលការព្យាបាលជាដើម)។ ផ្តល់នូវការជម្លៀស និងបញ្ជូនអ្នកដែលត្រូវការការថែរក្សាពិសេស<br>-ធានាដល់ការត្រួតពិនិត្យជំងឺ៖ បង្កើតកន្លែងព្យាបាលជំងឺរាកបង្កាជំងឺគ្រុនចាញ់ និងវិធានការការត្រួតពិនិត្យមូស<br>-ការផ្សព្វផ្សាយសារអប់រំអំពីអនាម័យដោយសម្របសម្រួលជាមួយអង្គការយូនីសេហ្វ និងដៃគូពាក់ព័ន្ធផ្សេងទៀត<br>-ផ្តល់នូវការឆ្លើយតបសុខភាពសាធារណៈរាល់ការផ្ទុះជំងឺឆ្លងណាមួយ។ |
| ៤-ការប្រតិបត្តិ<br>ផែនការ | តើយើងត្រូវប្រតិបត្តិផែនការរបៀបយ៉ាងណាខ្លះ? | **ក្នុងរយៈពេល៧២ម៉ោង**<br>-ទាក់ទងជាមួយនាយកដ្ឋានការពារសុខភាពនៃក្រសួងសុខាភិបាល/ស្រុកប្រតិបត្តិ/មណ្ឌលសុខភាព និងប្រភពផ្សេងទៀត (ឧ.អង្គការអន្តរជាតិអង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន) ដើម្បីប្រមូលព័ត៌មានជាក់លាក់សម្រាប់វិស័យផ្សេងៗ ដើម្បីចែករំលែកជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត<br>-បើសិនជាអ្នករៀបចំឬចូលរួមប្រមូលពត៌មានមិនបានគ្រប់គ្រាន់ក្នុងការវាយតម្លៃរួមគ្នាជាមួយក្រសួងសុខាភិបាលក្នុងតំបន់ដែលរងផលប៉ះពាល់ ត្រូវបើកកិច្ចប្រជុំដើម្បីសម្របសម្រួលជាមួយដៃគូទាំងអស់ ដើម្បីប្រមូលពត៌មានបន្ថែមទៀតនៅលើព្រឹត្តិការណ៍ និងលើផែនការរបស់ពួកគាត់<br>-ប្រមូលផ្តុំក្រុមឆ្លើយតបរហ័សថ្នាក់ខេត្ត ដើម្បីវាយតម្លៃស្ថានភាពនិងហានិភ័យសុខភាព<br>-លទ្ធផលនៃការវាយតម្លៃ និងចែករំលែកពត៌មានរួមជាមួយអ្នកជាប់ពាក់ព័ន្ធទាំងអស់។<br>**ថ្ងៃបន្តមកទៀត / សប្តាហ៍**<br>-ប្រមូលផ្តុំ និងគាំទ្រដល់ក្រុមសុខភាពចល័តដែលផ្តល់ការថែទាំដល់ប្រជាជន<br>-ផ្តល់ឃីតសុខភាពដល់ក្រុមចល័តនិងផ្តល់ទៅមណ្ឌលសុខភាពដែលរងផលប៉ះពាល់ដោយទឹកជំនន់ ឬខ្យល់ព្យុះ |

| | | |
|---|---|---|
| | | ឬទទួលចំនួនអ្នកជំងឺកើនឡើង<br>-កំណត់ទីកន្លែង និងយន្តការសម្រាប់ជម្លៀសកន្លែងផ្តល់សេវាទៅជិតមន្ទីរពេទ្យជំនាញឯកទេស<br>-តាមដានត្រួតពិនិត្យតម្រូវការសុខភាពនៅក្នុង "ទីទួលសុវត្ថិភាព" ឬតំបន់ទួលដែលប្រជាជនធ្វើការបម្លាស់ទីមករស់នៅបណ្តោះអាសន្ន ជាពិសេសលទ្ធភាពទទួលបានទឹកស្អាត និងបង្គន់អនាម័យមិនបានគ្រប់គ្រាន់ឬមិនទទួលបានសោះ<br>-ដៃគូគាំទ្រទាំងអស់ធានាថាស្តង់ដារសុខភាពត្រូវទទួលបានជាអប្បបរមា ហើយអាចនឹងធ្វើទៅបានលើសពីនេះ<br>-តាមដានត្រួតពិនិត្យប្រភពព្រមានដំបូង និងការតាមដានជំងឺឆ្លងក្នុងចំណោមប្រជាជនដែលទទួលរងផលប៉ះពាល់។ តាមដានព្រឹត្តប័ត្រ/ពត៌មានជាមួយអ្នកពាក់ព័ន្ធ ជាពិសេសវិស័យទឹកស្អាត និងអនាម័យ<br>-ផ្តល់រាល់ពត៌មានពីសកម្មភាព ផែនការ និងការតាមដានត្រួតពិនិត្យទិន្ន័យដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងចម្លងជូនទៅក្រសួងសុខាភិបាល<br>-តាមដានត្រួតពិនិត្យ និងចែករំលែកពត៌មានស្តីពីភាពរីកចំរើននៃវិស័យសុខាភិបាល និងការផ្តល់មូលនិធិ។ វាយតម្លៃ និងស្វែងរកដំណោះស្រាយចំពោះកង្វះការផ្តល់សេវារៀងរាល់សប្តាហ៍<br>-រៀបចំ អំពាវនាវ/ សំណើ ដើម្បីបំពេញចរិកាដែលខ្វះខាត និងសំណើដែលបានលើកធានាថាបានចែករំលែកឱ្យដល់គ្រប់វិស័យ/គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តត្រូវសម្របសម្រួលក្នុងការរៀបចំការធ្វើឱ្យល្អប្រសើរឡើងវិញ។ |
| ៥-ផែនការត្រៀមទុកជាមុន | -តើយើងត្រូវធ្វើអ្វីឥឡូវនេះ?<br>-តើយើងមានពត៌មានគ្រប់គ្រាន់?<br>-តើយើងមានសិទ្ធិអំណាចគ្រប់គ្រាន់?<br>-តើយើងមានធនធានគ្រប់គ្រាន់ ?<br>-តើយើងមានប្រព័ន្ធនៅហ្នឹងកន្លែង ?<br>-តើយើងមានដៃគូគ្រប់គ្រាន់ ? | -ចូលរួម/រៀបចំ កិច្ចប្រជុំមួយជាមួយគណៈគម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងដៃគូផ្នែកសុខភាព និងវិភាគលើមេរៀនដែលបានរៀនពីគ្រោះទឹកជំនន់កន្លងមកនេះ<br>-ត្រួតពិនិត្យលំហូរនៃការតាមដានជំងឺនិងពត៌មានសុខាភិបាលមកពីស្រុកប្រតិបត្តិ<br>-វាយតម្លៃភាពងាយរងគ្រោះ នៃគ្រឹះស្ថានសុខាភិបាលដែល និងកំណត់ពត៌មានត្រឡប់នៃដំណោះស្រាយសម្រាប់ដំណើរការបឋមនិងការបញ្ជូនទៅក្នុង " ទីទួលសុវត្ថិភាព "។<br>-ដាក់ឱ្យចំកន្លែង/រៀបចំទីធ្លាសម្រាប់ជម្រក ថៃទាំសុខភាព ធុងដាក់ទឹក បង្គន់ ។ល។ នៅក្នុងការកំណត់"ទីទួល |

| | | |
|---|---|---|
| | | សុវត្ថិភាព" ដោយប្រើស្តង់ដារស្វែរ ដើម្បីប៉ាន់ប្រមាណតម្រូវការ<br>-ធ្វើបច្ចុប្បន្នភាព និងចែករំលែកបញ្ជីឈ្មោះដៃគូផ្នែកសុខភាព បច្ចុប្បន្នភាពផែនទីរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលអាចចូលរួមនៅក្នុងការឆ្លើយតបសុខភាព ក្នុងអំឡុងពេលមាន គ្រោះអាសន្ន<br>-បាន់ប្រមាណតម្រូវការដំបូង សម្រាប់ផ្គត់ផ្គង់ឱសថបរិក្ខានិងបុគ្គលិកនៅមណ្ឌលសុខភាព ដែលរងផលប៉ះពាល់ ដោយសម្របសម្រួលជាមួយក្រសួងសុខាភិបាល<br>-កំណត់ចំនួនធនធានដែលអាចរកបានសម្រាប់ការឆ្លើយតបការសង្គ្រោះបន្ទាន់ (ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស ឱសថ និងគ្រឿងបរិក្ខារ)<br>-សាកសួរដៃគូសុខភាពទាំងអស់ ដោយចែករំលែកផែនការដែលបានរៀបចំ តាមរយៈផ្លូវ៣ (បញ្ជាក់ឱ្យច្បាស់ទីតាំងចុះទៅឃុំ/ភូមិ កំណត់រយៈពេលដែលផ្តល់ជំនួយការចំណុចលក្ខខណ្ឌចាប់យកផែនការរយៈពេលវែង ធនធានដែលមានស្រាប់<br>-ចែករំលែកពត៌មានត្រឡប់ដល់ស្រុកប្រតិបត្តិៈ ឧទាហរណ៍ ប្រព័ន្ធពត៌មានសុខាភិបាលនៅមណ្ឌលសុខភាព តំបន់គ្របដណ្តប់ ប្រភេទនៃកន្លែងផ្តល់សេវា ប្រភេទសេវាដែលបានផ្តល់<br>-កំណត់ជនបង្គោលថ្នាក់ខេត្ត សម្រាប់វាយតម្លៃសុខភាពនិងធានាថាពួកគាត់ដឹង ពីរបៀបប្រើ ទំរង់ស្តង់ដាររបស់ក្រសួងសុខាភិបាល និងវិធីសាស្ត្រសម្រាប់ការវាយតម្លៃ<br>-ផ្គត់ផ្គង់និងផ្តល់វ៉ាក់សាំងជាសារវ័ន្តឱសថសារវ័ន្តនិងអាហាររូបត្ថម្ភ។ ធានាឱ្យបាននូវការរក្សាទុកORSនិងសេរ៉ូម Ringers Lactateឱ្យបានគ្រប់គ្រាន់ និងឱសថ ឧបករណ៍ដទៃទៀត<br>-រៀបចំបន្ទាត់បំពេញបន្ថែម សម្រាប់ផ្គត់ផ្គង់វេជ្ជសាស្ត្រ ហើយបើចាំបាច់ត្រូវត្រួតពិនិត្យរក ប្រភពព្រមានដំបូងនិងការតាមដានជំងឺឆ្លង ក្នុងតំបន់ដែលមានហានិភ័យខ្ពស់។ |
| ៦-ថវិកា | តើការចំណាយក្នុងចំណុចទី៤ប៉ុន្មាន? | បុគ្គលិក ....................................<br>បរិក្ខារ........................................<br>ផ្គត់ផ្គង់ ......................................<br>សាច់ប្រាក់ ................................... |

## ឧបសម្ព័ន្ធទី៣

## និយមន័យ និងទស្សនាទាន

និយមន័យ និងទស្សនទានមួយចំនួនពុំមានវិធីច្បាស់លាស់ណាមួយ ដើម្បីកំណត់ទស្សនាទានគន្លឹះនៅក្នុងវិស័យនៃការគ្រប់គ្រងហានិភ័យនៃគ្រោះអាសន្នឡើយ ប៉ុន្តែមានពាក្យពេចន៍ និងនិយមន័យជាច្រើនដែលផ្តោតទៅលើការប្រើប្រាស់ និងការយល់ជាទូទៅនៃវិស័យនេះ នៅក្នុងបរិបទមនុស្សធម៌ជាពិសេស ទាក់ទងទៅនឹងគ្រោះមហន្តរាយធម្មជាតិ គ្រោះអាសន្នសាំញ៉ាំ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ និយមន័យទាំងឡាយខាងក្រោមនេះ មានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការគ្រប់គ្រងហានិភ័យនៃគ្រោះអាសន្នក្នុងវិស័យសុខាភិបាល។

### ១-វិបត្តិ (Crisis)

គឺជាព្រឹត្តិការណ៍ ឬព្រឹត្តិការណ៍ដែលកើតឡើងបន្តបន្ទាប់ទាំងឡាយ ដែលបង្កការគំរាមកំហែងដល់សុខភាព សុវត្ថិភាព សន្តិសុខ ឬសុខុមាលភាពរបស់សហគមន៍មួយជាធម្មតានៅក្នុងតំបន់ដ៏ធំមួយ ជម្លោះប្រដាប់អាវុធ ជំងឺឆ្លងរាតត្បាត គ្រោះទុរ្ភិក្ស គ្រោះមហន្តរាយធម្មជាតិ គ្រោះអាសន្នបរិស្ថាន និងព្រឹត្តិការណ៍គ្រោះថ្នាក់ធំៗដទៃទៀត ដែលអាចពាក់ព័ន្ធឬបណ្តាលឱ្យមានវិបត្តិមនុស្សធម៌។

### ២-គ្រោះមហន្តរាយ (Disaster)

គឺជាការរំខានធ្ងន់ធ្ងរទៅដំណើរការរបស់សហគមន៍មួយ ឬសង្គមមួយ ដែលបង្កឱ្យមានការខាតបង់មនុស្ស សម្ភារ សេដ្ឋកិច្ច ឬបរិស្ថាន ក្នុងទ្រង់ទ្រាយធំ ដែលលើសពីសមត្ថភាពរបស់សហគមន៍ ឬសង្គមដែលប៉ះពាល់នោះក្នុងការដោះស្រាយដោយប្រើធនធានផ្ទាល់របស់ខ្លួន។ គ្រោះមហន្តរាយគឺជាមុខងារមួយនៃដំណើរការហានិភ័យកើតឡើងពីការរួមបញ្ចូលគ្នានៃមុខសញ្ញាគ្រោះថ្នាក់ លក្ខខណ្ឌនៃភាពងាយរងគ្រោះ និងសមត្ថភាពឬវិធានការមិនគ្រប់គ្រាន់ ដើម្បីកាត់បន្ថយសក្តានុពលនៃផលវិបាកអវិជ្ជមានរបស់ហានិភ័យ។

ឧប្បត្តិហេតុណាមួយដែលបង្កការខូចខាត ការរំខានផ្នែកអេកូឡូស៊ីការបាត់បង់ជីវិតមនុស្សឬការធ្លាក់ចុះនូវសុខភាពឬសេវាសុខភាពក្នុងទ្រង់ទ្រាយមួយ ដែលតម្រូវឱ្យមានការឆ្លើយតបវិសាមញ្ញមួយពីខាងក្រៅសហគមន៍ឬតំបន់ដែលរងគ្រោះនោះ។

### ៣-គ្រោះអាសន្ន (Emergency)

គឺជាឧប្បត្តិហេតុភ្លាមៗមួយ ដែលតម្រូវឱ្យមានវិធានការភ្លាមៗ ដែលអាចកើតឡើងដោយសារតែជំងឺឆ្លងរាតត្បាតមហន្តរាយធម្មជាតិ ឬបច្ចេកវិទ្យាជម្លោះ ឬមូលហេតុផ្សេងៗទៀត ដែលបង្កឡើងដោយមនុស្ស។

### ៤-មុខសញ្ញាគ្រោះថ្នាក់ (Hazard)

គឺជា“បាតុភូតសារធាតុសកម្មភាពរបស់មនុស្សឬលក្ខខណ្ឌប្រកបដោយគ្រោះថ្នាក់មួយដែលអាចបង្កការបាត់បង់ជីវិតរបួស ឬផលប៉ះពាល់លើសុខភាពផ្សេងៗទៀត ការខូចខាតទ្រព្យសម្បត្តិ ការខាតបង់ជីវភាពប្រចាំថ្ងៃ និងសេវាការរំខានផ្នែកសង្គម និងសេដ្ឋកិច្ចឬការខូចខាតលើបរិស្ថាន”។

គឺជាបាតុភូតណាមួយ ដែលមានសក្តានុពលបង្កការរំខានឬការខូចខាតដល់មនុស្ស និងបរិស្ថានរបស់ពួកគេ។

### ៥-ភាពងាយរងគ្រោះ (Vulnerability)

“ចរិតលក្ខណៈ និងកាលៈទេសៈនៃសហគមន៍ប្រព័ន្ធឬទ្រព្យសម្បត្តិមួយដែលធ្វើឱ្យងាយទទួលរងផលបច្ច័យដែលបង្កការខូចខាតពីមុខសញ្ញាគ្រោះថ្នាក់មួយ”

- លក្ខខណ្ឌនានាដែលកំណត់ដោយកត្តាឬដំណើរការរូបវ័ន្ត សង្គមសេដ្ឋកិច្ច និងបរិស្ថានដែលបង្កើនភាពងាយទទួលរងផលប៉ះពាល់របស់សហគមន៍មួយទៅនឹងមុខសញ្ញាគ្រោះថ្នាក់នានា

- កម្រិតដែលប្រជាពលរដ្ឋឬបុគ្គលមិនអាចមានសមត្ថភាពរំពឹងទុកជាមុនក្នុងការដោះស្រាយតបត និងស្តារឡើងវិញពីផលប៉ះពាល់របស់គ្រោះមហន្តរាយមួយ។

### ៦-ហានិភ័យ (Risk)

ភវនីយភាពនៃផលវិបាកប្រកបដោយគ្រោះថ្នាក់ ឬការបាត់បង់ដែលរំពឹងទុក (ការស្លាប់របួសទ្រព្យសម្បត្តិ ជីវភាពរស់នៅសកម្មភាពសេដ្ឋកិច្ច ដែលត្រូវបានរំខានឬបរិស្ថានដែលត្រូវបានធ្វើឱ្យខូចខាត) ដែលកើតចេញពីអន្តរកម្មរវាងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិឬបង្កដោយមនុស្ស និងភាពងាយរងគ្រោះ។

ហានិភ័យគឺជាមុខងារមួយនៃមុខសញ្ញាគ្រោះថ្នាក់ដែលសហគមន៍ប្រឈម និងភាពងាយរងគ្រោះរបស់សហគមន៍នោះ។ ទោះបីជាយ៉ាងណាក្តី ហានិភ័យនោះត្រូវបានកែប្រែដោយកម្រិតនៃការត្រៀមជាមុនរបស់សហគមន៍ដែលប្រឈមនឹងហានិភ័យនោះ។ ហានិភ័យត្រូវបានបង្ហាញដោយសញ្ញាណខាងក្រោម៖

| ហានិភ័យគឺសមាមាត្រទៅនឹងមុខសញ្ញាគ្រោះថ្នាក់ X ភាពងាយរងគ្រោះ / កម្រិតនៃការត្រៀមជាមុន |
|---|

### ៧-ការកាត់បន្ថយហានិភ័យ (Risk Reduction)

ការកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងវិធានការនានា ដែលត្រូវបានតាក់តែងឡើងដើម្បីទប់ស្កាត់មុខសញ្ញាគ្រោះថ្នាក់មិនឱ្យបង្កើតហានិភ័យ ឬកាត់បន្ថយរបាយភាពខ្លាំងក្លាឬភាពធ្ងន់ធ្ងរនៃមុខសញ្ញាគ្រោះថ្នាក់។ វិធានការទាំងនេះ រួមមានការងារសំណង់ដើម្បីបន្ធូរបន្ថយទឹកជំនន់ និងការរៀបចំផែនការប្រើប្រាស់ដីធ្លីសមស្របដោយរួមបញ្ចូលផងដែរ នូវវិធានការកាត់បន្ថយភាពងាយរងគ្រោះនានា ដូចជាការផ្សព្វផ្សាយបង្កើនការយល់ដឹង ការបង្កើនសន្តិសុខ សុខភាពសហគមន៍ និងការផ្លាស់ប្តូរទីលំនៅឬការការពារប្រជាពលរដ្ឋឬសំណង់ដែលងាយរងគ្រោះ។

ធាតុផ្សំដែលត្រូវបានពិចារណាជាមួយលទ្ធភាព ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងហានិភ័យនៃគ្រោះមហន្តរាយនៅក្នុងសង្គមមួយ ដើម្បីជៀសវាង(ការទប់ស្កាត់) ឬកម្រិត (បន្ធូរបន្ថយ និងការត្រៀមជាមុន) ផលប៉ះពាល់អវិជ្ជមាននៃមុខសញ្ញាគ្រោះថ្នាក់នៅក្នុងបរិបទទូលំទូលាយនៃការអភិវឌ្ឍប្រកបដោយចីរភាព។

### ៨-ការបង្ការ (Prevention)

សកម្មភាពនានា ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមាននៃមុខសញ្ញាគ្រោះថ្នាក់ និងមធ្យោបាយនានា ដើម្បីកាត់បន្ថយជាអប្បបរមានូវគ្រោះមហន្តរាយផ្នែកបរិស្ថានបច្ចេកវិទ្យា និងជីវសាស្ត្រដែលពាក់ព័ន្ធ។

សកម្មភាពនានាដែលជាវិធានការមានរចនាសម្ព័ន្ធឬគ្មានរចនាសម្ព័ន្ធ ការផ្សព្វផ្សាយជាសាធារណៈ និងការអប់រំរួមទាំងវិធានការច្បាប់។

### ៩-បន្ធូរបន្ថយ (Mitigation)

គឺជាវិធានការដែលមានរចនាសម្ព័ន្ធនិងគ្មានរចនាសម្ព័ន្ធដែលត្រូវបានចាត់ធ្វើឡើង ដើម្បីកម្រិតពីផលប៉ះពាល់អវិជ្ជមាននៃមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិភាពវិចវិលនៃបរិស្ថាន និងមុខសញ្ញាគ្រោះថ្នាក់នៃបច្ចេកវិទ្យា។

សំណុំនៃវិធានការនានាដើម្បីកាត់បន្ថយ ឬអព្យាក្រឹតកម្មផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ ដោយការកាត់បន្ថយភាពងាយរងគ្រោះផ្នែកសង្គមមុខងារឬរូបវ័ន្ត។

### ១០-ការត្រៀមទុកជាមុន (Preparedness)

សកម្មភាព និងវិធានការនានា ដែលចាត់ធ្វើឡើងជាមុនដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ រួមទាំងការចេញសេចក្តីព្រមានពីដំបូងឱ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព និងការជម្លៀសមនុស្ស និងទ្រព្យសម្បត្តិជាបណ្តោះអាសន្នពីទីកន្លែងដែលទទួលរងការគំរាមកំហែង។

សកម្មភាពរយៈពេលវែងដែលមានគោលបំណងពង្រឹងសមត្ថភាព និងកម្លាំងទាំងមូលរបស់ប្រទេសមួយ ឬសហគមន៍មួយ ដើម្បីគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវគ្រោះអាសន្នគ្រប់ប្រភេទ និងរបៀបនាំមកនូវអន្តរកាលតាំងពីការសង្គ្រោះរហូតដល់ការស្តារឡើងវិញ និងត្រឡប់មករកការអភិវឌ្ឍប្រកបដោយចីរភាពវិញ ដោយតម្រូវឱ្យមានការបង្កើតផែនការគ្រោះអាសន្ន ការបណ្តុះបណ្តាលបុគ្គលិកនៅគ្រប់កម្រិតថ្នាក់ និងនៅក្នុងគ្រប់វិស័យព្រមទាំងអប់រំសហគមន៍ ដែលប្រឈមនឹងហានិភ័យក៏ដូចជាត្រួតពិនិត្យតាមដាន និងវាយតម្លៃជាទៀងទាត់។

## ១១-ការឆ្លើយតប (Response)

គឺជាការរួមបញ្ចូលគ្នានៃការសម្រេចចិត្ត និងសកម្មភាពដែលចាត់ធ្វើឡើងក្នុងអំឡុងពេល និងក្រោយពេលគ្រោះមហន្តរាយរួមទាំងការសង្គ្រោះភ្លាមៗ ការស្តារឡើងវិញ និងការកសាងឡើងវិញ។

## ១២-ការស្តារឡើងវិញ (Recovery)

ការសម្រេចចិត្ត និងសកម្មភាពនានា ដែលធ្វើឡើងបន្ទាប់ពីមានគ្រោះមហន្តរាយមួយ ក្នុងគោលបំណងស្តារឡើងវិញឬធ្វើឱ្យប្រសើរនូវលក្ខខណ្ឌនៃការរស់នៅមុនពេលគ្រោះមហន្តរាយរបស់សហគមន៍ ដែលប៉ះពាល់ខណៈពេលជាមួយគ្នានោះ លើកទឹកចិត្ត និងសម្រួលដល់ការកែតម្រូវចាំបាច់នានាដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។

កិច្ចខិតខំប្រឹងប្រែងរយៈពេលវែងដើម្បី **(ក)**-កសាងឡើងវិញនិងស្តារឡើងវិញនូវតំបន់ដែលរងគ្រោះដោយគ្រោះមហន្តរាយឧទា. តាមរយៈការជួសជុល ឬការប្តូរផ្ទះអាជីវកម្មសាធារណការ និងរចនាសម្ព័ន្ធដទៃទៀត **(ខ)**-ធ្វើការដោះស្រាយការរំខានដែលគ្រោះមហន្តរាយបានបង្កឡើងនៅក្នុងជីវិតរបស់សហគមន៍ និងបំពេញតម្រូវការដែលពាក់ព័ន្ធនឹងការស្តារឡើងវិញរបស់ជនរងគ្រោះ និង**(គ)**-បន្ធូរបន្ថយមុខសញ្ញាគ្រោះថ្នាក់ក្នុងពេលអនាគត។

## ១៣-ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ (Disaster Risk Management)

ដំណើរការជាលក្ខណៈប្រព័ន្ធនៃការប្រើសេចក្តីសម្រេចចិត្តបែបរដ្ឋបាលស្ថាប័នជំនាញប្រតិបត្តិ និងសមត្ថភាពដើម្បីអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ សមត្ថភាពដោះស្រាយរបស់សង្គម និងសហគមន៍ ដើម្បីបន្ថយផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិគ្រោះមហន្តរាយនៃបរិស្ថាននិងបច្ចេកវិទ្យាដែលពាក់ព័ន្ធ។ ដំណើរការនេះមានសកម្មភាពគ្រប់ទម្រង់រួមទាំងវិធានការមានរចនាសម្ព័ន្ធ និងគ្មានរចនាសម្ព័ន្ធ ដើម្បីជៀសវាង (ការទប់ស្កាត់) ឬកម្រិត (ការបន្ធូរបន្ថយនិងការត្រៀមជាមុន) ផលប៉ះពាល់អវិជ្ជមាននៃមុខសញ្ញាគ្រោះថ្នាក់។

អភិក្រមជាប្រព័ន្ធ និងការអនុវត្តការគ្រប់គ្រងភាពមិនប្រាកដប្រជា ដើម្បីកាត់បន្ថយជាអប្បបរមានូវគ្រោះថ្នាក់ និងការខូចខាត។

## ១៤-វដ្តនៃការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ (Disaster Risk Management Cycle)

វដ្តគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ពន្យល់ពីទំនាក់ទំនងរវាងដំណាក់កាលទាំងបួននៃការគ្រប់គ្រងហានិភ័យនៃគ្រោះអាសន្ន និងគ្រោះមហន្តរាយ(រូបភាពទី១)។ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ រួមបញ្ចូលទាំងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ តាមរយៈការបង្ការ ការត្រៀមជាមុន និងការបន្ធូរបន្ថយ ក៏ដូចជា "ការឆ្លើយតប និងការស្តារឡើងវិញ" ដែលជាសកម្មភាពគ្រប់គ្រងវិបត្តិនៅក្រោយគ្រោះមហន្តរាយ។ ដូច្នេះ វិស័យសុខាភិបាលត្រូវផ្តោតទៅលើវិធានការផ្សេងៗ ដែលទាក់ទងទៅនឹងការបង្ការ ការបន្ធូរបន្ថយ និងការត្រៀមជាមុន មុនពេលគ្រោះមហន្តរាយកើតឡើងនិងការឆ្លើយតបបន្ទាន់ និងការស្តារឡើងវិញភ្លាមៗ បន្ទាប់ពីគ្រោះមហន្តរាយបានកើតឡើង។

### តារាងទី៥ ទិដ្ឋភាពទូទៅ ដំណាក់កាលទាំង៤វដ្ត ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ




**១៥-សមត្ថភាពបន្សាំ** (Adaptive capacity)

"យុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ការផ្លាស់ប្តូរនៅក្នុងសង្គមមួយ" ភាគច្រើនសម្រាប់មុខសញ្ញាគ្រោះថ្នាក់ក្នុងពេលអនាគត និងការប្រែប្រួលអាកាសធាតុ។

**១៦-សមត្ថភាពដោះស្រាយ** (Coping capacity)

សំដៅលើធនធាន សម្រាប់ការឆ្លើយតបដោយផ្ទាល់ទៅនឹងផលប៉ះពាល់នៃព្រឹត្តិការណ៍មុខសញ្ញាគ្រោះថ្នាក់ណាមួយ។ នេះរួមបញ្ចូលទាំងការត្រៀមទប់ទល់នឹងគ្រោះមហន្តរាយ និងការជូនដំណឹងពីដំបូង។

**១៧-ការប៉ះពាល់** (Exposure)

"មនុស្ស ទ្រព្យសម្បត្តិ ប្រព័ន្ធ ឬធាតុដទៃទៀត ដែលមាននៅក្នុងតំបន់មុខសញ្ញាគ្រោះថ្នាក់ដែលស្ថិតក្នុងស្ថានភាពប្រឈមមុខនឹងបាត់បង់"

ប្រទេស ឬ "អង្គភាព" ដទៃទៀត ដែលរងគ្រោះដោយមុខសញ្ញាគ្រោះថ្នាក់នានា ដូចជាទឹកជំនន់ គ្រោះរញ្ជួយដី គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងកំណើនកំពស់ទឹកសមុទ្រ។

**១៨-ភាពងាយរងផលប៉ះពាល់** (Susceptibility)

"ស្ថានភាពនៃការប្រឈម និងហានិភ័យ ប្រសិនបើប៉ះពាល់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់"

ភាពងាយរងផលប៉ះពាល់ សំដៅទៅលើចរិតលក្ខណៈរចនាសម្ព័ន្ធនៃសង្គមមួយ និងលក្ខខណ្ឌក្របខ័ណ្ឌដែលសហគមន៍ប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ និងបាតុភូតអាកាសធាតុ។

**១៩-ភាពធន់** (Resilience)

សំដៅដល់សមត្ថភាពប្រព័ន្ធសហគមន៍ឬសង្គម ដែលប្រឈមមុខ នឹងមុខសញ្ញាគ្រោះថ្នាក់ ដើម្បីទប់ទល់ សម្របទៅតាម និងស្តារពីផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ឱ្យបានទាន់ពេល និងមានប្រសិទ្ធភាពតាមរយៈសកម្មភាពនានា ដោយសិក្សាពីគ្រោះមហន្តរាយពីអតីតកាលឱ្យមានការប្រុងប្រយ័ត្ននាពេលអនាគត និងចាត់វិធានការឱ្យប្រសើរឡើងនូវការកាត់បន្ថយហានិភ័យ។

## ឧបសម្ព័ន្ធ ៤

## កញ្ចប់សំណុំសេវាសុខភាពអប្បបរមាដំបូង (MISP)

### ១-តើ MISP គឺជាអ្វី ?

សំណុំសេវា អប្បរិមាដំបូង(Minimum Initiate Service Package) សម្រាប់សុខភាពបន្តពូជសុខភាពផ្លូវភេទ(SRH) គឺជាសំណុំសម្របសម្រួលនៃសកម្មភាពជាអាទិភាព ដែលត្រូវបានបង្កើតឡើងដើម្បី ការពារ និងគ្រប់គ្រងផលវិបាកនៃអំពើហិង្សាផ្លូវភេទ ការពារការស្លាប់ និងមរណភាពរបស់មាតា និងទារក កាត់បន្ថយការឆ្លងមេរោគអេដស៍ និងរៀបចំផែនការ សម្រាប់សេវាសុខភាពបន្តពូជគ្រប់ជ្រុងជ្រោយ ដែលចាប់ផ្តើមពីថ្ងៃ និងសប្តាហ៍ដំបូងនៃគ្រោះអាសន្ន។ សំណុំនៃសកម្មភាពនេះ ត្រូវតែអនុវត្តនៅពេលចាប់ផ្តើមនៃគ្រោះអាសន្ន ក្នុងលក្ខណៈសម្របសម្រួលដោយបុគ្គលិកដែលបានបណ្តុះបណ្តាល។ MISP អាចត្រូវបានអនុវត្តដោយមិនចាំបាច់មានការវាយតម្លៃអំពីតម្រូវការសម្រាប់សុខភាពបន្តពូជស៊ីជម្រៅពីព្រោះភស្តុតាងដែលបានចងក្រងជាឯកសារបង្ហាញពីភាពត្រឹមត្រូវនៃការប្រើប្រាស់របស់វា។ MISP គឺជាបទដ្ឋានមួយនៅក្នុងការកែសម្រួលឆ្នាំ ២០១១ នៃបទដ្ឋានអប្បបរមា(Sphere Minimum Standards) ក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយក៏ដូចជានៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍របស់ទីភ្នាក់ងារអន្តរក្រសួង(Inter-agency Standing Committee (IASC)ឧបករណ៍ចង្កោមសុខភាពនិងការណែនាំ(Health Cluster tools and guidance)។ MISP ក៏បំពេញតាមលក្ខណៈវិនិច្ឆ័យនៃការសង្គ្រោះជីវិតសម្រាប់មជ្ឈមណ្ឌលមូលនិធិសង្គ្រោះបន្ទាន់(Central Emergency Response Fund (CERF)។ សមាសធាតុនៃ MISP បានបង្កើតដើម្បីបំពេញតម្រូវការអប្បបរមាហើយគេរំពឹងថាការបង្កើននិងពង្រីកសេវាសុខភាពបន្តពូជគ្រប់ជ្រុងជ្រោយ នឹងកើតឡើងនៅពេលដែលមានស្ថេរភាព។

### ២-គោលបំណងទាំង៥ របស់ MISP គឺ៖

១-ធានាថាអង្គភាពចាត់តាំងត្រូវបានកំណត់អត្តសញ្ញាណដើម្បីដឹកនាំការអនុវត្តMISP

២-ការពារនិងគ្រប់គ្រងផលវិបាកនៃអំពើហិង្សាផ្លូវភេទ

៣-កាត់បន្ថយការចម្លងមេរោគអេដស៍

៤-ការពារការស្លាប់និងជំងឺរបស់មាតានិងទារក។

៥-ផែនការ MISP សម្រាប់ការត្រៀមទុកជាមុននិងការឆ្លើយតបលើការថែទាំសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ។

## Minimum Initial Service Package (MISP) for Reproductive Health




| | CRISIS<br>Crude mortality rate >1 death/10,000/day | POST-CRISIS<br>Mortality returns to level of surrounding populations |
|---|---|---|
| SUBJECT AREA | MINIMUM (MISP) RH SERVICES | COMPREHENSIVE RH SERVICES |
| FAMILY PLANNING | • Provide contraceptives, such as condoms, pills, injectables and IUDs, to meet demand | • Source and procure contraceptive supplies<br>• Provide staff training<br>• Establish comprehensive family planning programs<br>• Provide community education |
| GENDER-BASED VIOLENCE | • Coordinate mechanisms to prevent sexual violence with the health and other sectors/clusters<br>• Provide clinical care for survivors of rape<br>• Inform community about services | • Expand medical, psychological, social and legal care for survivors<br>• Prevent and address other forms of GBV, including domestic violence, forced/early marriage, female genital cutting<br>• Provide community education<br>• Engage men and boys in GBV programming |
| MATERNAL AND NEWBORN CARE | • Ensure availability of emergency obstetric and newborn care services<br>• Establish 24/7 referral system for obstetric and newborn emergencies<br>• Provide clean delivery packages to visibly pregnant women and birth attendants<br>• Inform community about services | • Provide antenatal care<br>• Provide postnatal care<br>• Train skilled attendants (midwives, nurses, doctors) in performing emergency obstetric and newborn care<br>• Increase access to basic and comprehensive emergency obstetric and newborn care |
| STIs, INCLUDING HIV PREVENTION & TREATMENT | • Ensure safe and rational blood transfusion practice<br>• Ensure adherence to standard precautions<br>• Guarantee the availability of free condoms<br>• Provide syndromic treatment as part of routine clinical services for patients presenting for care<br>• Provide ARV treatment for patients already taking ARVs, including for PMTCT, as soon as possible | • Establish comprehensive STI prevention and treatment services, including STI surveillance systems<br>• Collaborate in establishing comprehensive HIV services as appropriate<br>• Provide care, support and treatment for people living with HIV/AIDS<br>• Raise awareness of prevention, care, treatment services of STIs |

The RH Kit is designed for use for a 3-month period for a varying population number and is divided into three "blocks" as follows:

| | | |
|---|---|---|
| Block 1: Six kits to be used at the community and primary health care level for 10,000 persons/3 months. | | |
| KIT NUMBERS | KIT NAME | COLOR CODE |
| Kit 0 | Administration | Orange |
| Kit 1 | Condom (Part A [illegible] male condoms + Part B [illegible] female condoms) | Red |
| Kit 2 | Clean Delivery (Individual) (Part A + B) | Dark blue |
| Kit 3 | Rape Treatment | Pink |
| Kit 4 | Oral and Injectable Contraception | White |
| Kit 5 | STI | Turquoise |
| [illegible] | | |
| Block 2: Five kits to be used at the community and primary health care level for 30,000 persons /3 months. | | |
| KIT NUMBERS | KIT NAME | COLOR CODE |
| Kit 6 | Clinical Delivery Assistance (Part A + B) | Brown |
| Kit 7 | IUD | Black |
| Kit 8 | Management of Complications of Abortion | Yellow |
| Kit 9 | Suture of Tears (Cervical and vaginal) and Vaginal Examination | Purple |
| Kit 10 | Vacuum Extraction for Delivery (Manual) | Grey |
| [illegible] | | |
| Block 3: Two kits to be used at referral hospital level for 150,000 persons /3 months. | | |
| KIT NUMBERS | KIT NAME | COLOR CODE |
| Kit 11 | Referral level for Reproductive Health (Part A + B) | Fluorescent Green |
| Kit 12 | Blood Transfusion | Dark Green |
| [illegible] | | |

*NOTE: Agencies should not depend solely on the Inter-agency RH Kits and should plan to integrate the procurement of MISP/RH supplies in their routine health procurement systems.*

### ៣-ការសម្របសម្រួលត្រូវបានកំណត់ ដើម្បីដឹកនាំការអនុវត្ត MISP

ការសម្របសម្រួលសកម្មភាព MISP ដែលជាផ្នែកមួយនៃវិស័យសុខាភិបាល/ការឆ្លើយតបជារួមគឺចាំបាច់ នៅគ្រប់កម្រិតរួមទាំងនៅក្នុងភ្នាក់ងារសង្គ្រោះនីមួយៗ ដែលឆ្លើយតបទៅនឹងភាពអាសន្នក៏ដូចជានៅថ្នាក់ក្រោម

ជាតិថ្នាក់ជាតិនិងអន្តរជាតិ។ ការសម្របសម្រួលនៅក្នុងផ្នែក និងកម្រិតផ្សេងៗគ្នា និងនៅតាមវិស័យនានាមានសារៈសំខាន់ណាស់ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃការឆ្លើយតបរបស់សេវាសុខភាពបន្តពូជ ព្រោះវាជួយកំណត់ និងបំពេញចន្លោះប្រហោងក្នុងការផ្តល់សេវាការពារកម្មវិធីត្រួតគ្នាពង្រឹងការតស៊ូមតិ និងគាំទ្រគណនេយ្យភាព និងការអនុវត្តជាស្តង់ដារ។

នៅដំណាក់កាលដំបូងនៃការឆ្លើយតបនៅក្នុងផ្នែកមនុស្សធម៌នីមួយៗ ផ្នែកសុខាភិបាលឬក្រុមសុខាភិបាលត្រូវតែកំណត់អត្តសញ្ញាណអង្គការមួយ ដើម្បីដឹកនាំការឆ្លើយតដល់សេវាសុខភាពបន្តពូជដូចជា អង្គការក្រៅរដ្ឋាភិបាលជាតិឬអន្តរជាតិក្រសួងសុខាភិបាលឬទីភ្នាក់ងារអង្គការសហប្រជាជាតិ។ អង្គការដែលត្រូវបានចាត់តាំងគឺជាស្ថាប័នមួយដែលត្រូវបានគេកំណត់ថាមានសមត្ថភាពខ្ពស់បំផុតក្នុងការបំពេញតួនាទីនេះ ហើយតាំងចិត្តធ្វើការជាមន្ត្រីសុខភាពបន្តពូជ ពេញម៉ោងក្នុងរយៈពេលយ៉ាងតិចបីខែ ដើម្បីផ្តល់ការគាំទ្រប្រតិបត្តិការ និងបច្ចេកទេសដល់ដៃគូសុខភាព និងដើម្បីធានានូវអាទិភាពសេវាសុខភាពបន្តពូជ។ល។ និងសម្រេចបាននូវការគ្របដណ្តប់ល្អនៃសេវាកម្ម MISP ។ វាជាការសំខាន់ណាស់ដែលបុគ្គលនេះ មានចំណេះដឹងបច្ចេកទេសគ្រប់គ្រាន់នៃសមាសធាតុ MISP ទាំងអស់ដើម្បីផ្តល់ការគាំទ្រ។

មន្ត្រីសុខភាពបន្តពូជ(RH) ទទួលខុសត្រូវក្នុងការគាំទ្រវិស័យសុខាភិបាល/ក្រុមដៃគូ ដើម្បីអនុវត្ត MISP និងរៀបចំផែនការសម្រាប់ផ្តល់សេវាសុខភាពសុខភាពបន្តពូជ មានតួនាទី៖

- សម្របសម្រួលទំនាក់ទំនង និងសហការជាមួយផ្នែកសុខាភិបាល ឬអ្នកសម្របសម្រួលក្រុមសុខភាព និងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំសម្របសម្រួលសុខភាព(Health Coordination Meetings) ការផ្តល់ព័ត៌មាន ការលើកឡើងពីយុទ្ធសាស្ត្រ បញ្ហាបច្ចេកទេស និងកង្វល់នានា
- គាំទ្រដល់ដំណើរការលទ្ធកម្ម ដល់ការផ្គត់ផ្គង់សម្ភារ និងឯកសារយោង
- រៀបចំការប្រជុំអ្នកពាក់ព័ន្ធមន្ទីរពេទ្យបង្អែក (RH) យ៉ាងទៀងទាត់នៅកម្រិតពាក់ព័ន្ធ (ថ្នាក់ជាតិថ្នាក់ក្រោមជាតិ/តំបន់មូលដ្ឋាន) ដើម្បីដោះស្រាយបញ្ហា និងយុទ្ធវិធីក្នុងការអនុវត្ត MISP និងដើម្បីផ្គត់ផ្គង់សម្ភារធនធានរបស់ MISP
- ធានាឱ្យមានការប្រាស្រ័យទាក់ទងជាប្រចាំក្នុងចំណោមគ្រប់កម្រិត និងរាយការណ៍ត្រឡប់មកវិញអំពីការសន្និដ្ឋានសំខាន់ៗ បញ្ហាប្រឈមនានា ដែលទាមទារឱ្យមានដំណោះស្រាយ (ឧទា.គោលនយោបាយឬឧបសគ្គផ្សេងទៀត ដែលរឹតត្បិតក្នុងការទទួលបានសេវាសុខភាពសុខភាពបន្តពូជ) ចំពោះយន្តការសម្របសម្រួលសុខភាពទូទៅ
- កំណត់ការរួមឱ្យខ្លាំង ចន្លោះប្រហោង ជៀសវាងកិច្ចប្រឹងប្រែងត្រួតគ្នា និងរចនាសម្ព័ន្ធប៉ារ៉ាឡែល (Parallel Structures)
- ផ្តល់ការណែនាំបច្ចេកទេស ប្រតិបត្តិការលើការអនុវត្តMISP វគ្គតម្រង់ទិសជាក់លាក់នៅពេល និងកន្លែងដែលអាចធ្វើទៅបាន (ឧទា.សម្រាប់អ្នកផ្តល់សេវាបុគ្គលិកសុខភាពសហគមន៍បុគ្គលិកកម្មវិធី និងប្រជាជនដែលរងផលប៉ះពាល់រួមទាំងមនុស្សវ័យជំទង់)
- ទំនាក់ទំនងជាមួយផ្នែកផ្សេងៗទៀត (ក្រុមការពារសន្តិសុខទឹកស្អាត និងអនាម័យសេវាកម្មសហគមន៍អ្នកទទួលខុសត្រូវជំរុំ។ ល។ ) ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងសេវាសុខភាពសុខភាពបន្តពូជ
- គាំទ្រដល់ដៃគូសុខភាព ដើម្បីស្វែងរកថវិការតាមរយៈកម្មវិធីដំណើរការមនុស្សធម៌ និងការអំពាវនាវក្នុងការសម្របសម្រួលជាមួយផ្នែកសុខាភិបាល/ក្រុម។

## ៤-ការពារអំពើហិង្សាផ្លូវភេទ

អំពើហិង្សាផ្លូវភេទត្រូវបានគេរាយការណ៍ពីបញ្ហាមនុស្សធម៌ជាច្រើន ដែលរួមមានទាំងគ្រោះមហន្តរាយធម្មជាតិផងដែរ។ តួអង្គទាំងអស់នៅក្នុងផ្នែកមនុស្សធម៌ត្រូវតែដឹងអំពីហានិភ័យនៃអំពើហិង្សាផ្លូវភេទ និងសម្រប

សម្រួលសកម្មភាពពហុវិស័យ ដើម្បីការពារប្រជាជនដែលរងផលប៉ះពាល់ជាពិសេសស្ត្រី និងក្មេងស្រី។ មន្ត្រីមន្ទីរពេទ្យបង្អែក(RH) ត្រូវតែពិភាក្សាអំពីបញ្ហាអំពើហិង្សាផ្លូវភេទនៅក្នុងការប្រជុំសម្របសម្រួលសុខភាព។ ដោយមានកិច្ចសហការជាមួយផ្នែកសុខាភិបាល/យន្តការជាក្រុមទាំងមូលមន្ត្រីរាជការ និងបុគ្គលិកកម្មវិធីរ៉ាក់ត្រូវតែ៖

- ធានាថាស្ត្រីបុរសវ័យជំទង់ និងកុមារទទួលបានសេវាសុខភាពជាមូលដ្ឋានរួមទាំងសេវាផ្លូវភេទ និងសេវាសុខភាពបន្តពូជ
- រៀបចំ និងកំណត់ទីតាំងមូលដ្ឋានសុខាភិបាល ដើម្បីពង្រឹងសន្តិសុខដោយពិគ្រោះយោបល់ជាមួយប្រជាជនជាពិសេសស្ត្រីនិងយុវជនវ័យជំទង់
- ពិគ្រោះយោបល់ជាមួយអ្នកផ្តល់សេវា និងអ្នកជំងឺអំពីសុវត្ថិភាពនៅក្នុងមូលដ្ឋានសុខាភិបាល
- កំណត់ទីតាំងបង្គន់អនាម័យបុរស និងស្ត្រីដាច់ដោយឡែកពីគ្នានៅក្នុងមូលដ្ឋានសុខាភិបាល ក្នុងទីតាំងមានសុវត្ថិភាព និងមានភ្លើងបំភ្លឺផ្លូវគ្រប់គ្រាន់នៅពេលយប់ និងធានាទ្វារចាក់សោពីខាងក្នុង
- ធានាថាភាសាក្រុមជនជាតិភាគតិចទាំងអស់ត្រូវបានរៀបចំ ក្នុងចំណោមអ្នកផ្តល់សេវាឬអ្នកបកប្រែភាសា
- ជួលអ្នកផ្តល់សេវាបុគ្គលិកសុខភាពសហគមន៍បុគ្គលិកកម្មវិធី និងអ្នកបកប្រែភាសាជាស្ត្រី
- ជូនដំណឹងដល់អ្នកផ្តល់សេវាអំពីសារៈសំខាន់នៃការរក្សាការសម្ងាត់ ការចុះហត្ថលេខា និងគោរពតាមក្រមសីលធម៌ប្រឆាំងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ(SEA)
- ធានាថាក្រមសីលធម៌ប្រឆាំងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ(SEA) និងយន្តការរាយការណ៍ដោយបុគ្គលិកសុខាភិបាលត្រូវបានអនុវត្តដូចជា វិធានដាក់ទណ្ឌកម្មពាក់ព័ន្ធ ដើម្បីអនុវត្តច្បាប់ទាំងនេះ។

ដើម្បីបង្ការ និងគ្រប់គ្រងផលវិបាកសុខភាព ដែលអាចកើតមានជនរងគ្រោះពីការរំលោភសេពសន្ថវៈ ត្រូវតែទទួលបានការថែទាំសុខភាព រួមទាំងការប្រឹក្សាយោបល់គាំទ្រឱ្យបានឆាប់បំផុតបន្ទាប់ពីមានហេតុការណ៍កើតឡើង។ ធានាថាសេវាថែទាំសុខភាពអាចផ្តល់នូវការយកចិត្តទុកដាក់នៅពេលការឆ្លើយតបផ្នែកមនុស្សធម៌ចាប់ផ្តើម។ ជនរងគ្រោះក៏អាចត្រូវការការការពារ ការគាំទ្រផ្នែកចិត្តសាស្ត្រ និងផ្លូវច្បាប់ឱ្យបានឆាប់ ដែលអាចធ្វើទៅបាន គាំទ្រដំណើរការដើម្បីកំណត់ការបែងចែកតួនាទី និងទំនួលខុសត្រូវច្បាស់លាស់ក្នុងចំណោមដៃគូសុខាភិបាល និងរវាងផ្នែកនឹងកម្មវិធីផ្សេងៗ ក្នុងការឆ្លើយតបសេចក្តីត្រូវការរបស់ជនរងគ្រោះ (សុខភាព កិច្ចការពារសន្តិសុខ និងសេវាសហគមន៍) ដើម្បីធានាការសម្របសម្រួលផ្តោតលើជនរងគ្រោះ (Survivor Centered) យន្តការបញ្ជូនជនរងគ្រោះដោយលាក់ការសម្ងាត់។ ការព្យាបាលត្រូវចាប់ផ្តើមដោយមិនចាំបាច់ពិនិត្យប្រសិនបើជនរងគ្រោះចង់បាន។ ព្យាបាលផលវិបាកដែលគំរាមកំហែងដល់អាយុជីវិតជាមុន ហើយបញ្ជូនទៅមូលដ្ឋានសុខាភិបាល ដែលមានកម្រិតខ្ពស់សមស្រប។

## ៥-កាត់បន្ថយការចម្លងមេរោគអេដស៍

ដើម្បីកាត់បន្ថយការឆ្លងមេរោគអេដស៍ នៅពេលចាប់ផ្តើមនៃការឆ្លើយតបខាងមនុស្សធម៌ មន្ត្រីសុខភាពបន្តពូជត្រូវតែធ្វើការជាមួយផ្នែកសុខាភិបាល ដៃគូទាំងអស់ដើម្បី៖

- បង្កើតការអនុវត្តការចាក់បញ្ចូលឈាមប្រកបដោយសុវត្ថិភាព
- ធានាឱ្យបាននូវការអនុវត្តការប្រុងប្រយ័ត្នស្តង់ដារ
- ធានាឱ្យមានស្រោមអនាម័យនិងចែកចាយដោយឥតគិតថ្លៃ។

ទោះបីជាមិនមែនជាសមាសធាតុនៃ MISP ក៏ដោយវាជាការសំខាន់ ដើម្បីធ្វើឱ្យមានថ្នាំប្រឆាំងនឹងមេរោគអេដស៍(ARV) អាចបន្តការព្យាបាលសម្រាប់មនុស្សដែលបានចុះឈ្មោះក្នុងកម្មវិធី ART មុនពេលមានអាសន្ន រួមទាំងស្ត្រីដែលបានចុះឈ្មោះក្នុងកម្មវិធី PMTCT ។

## ៦-ធានាឱ្យមានសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើត (EmONC)

យោងទៅតាមសូចនាករនៃអង្គការសហប្រជាជាតិ ប្រមាណ១៥% នៃស្ត្រីនឹងវិវត្តផលវិបាកផ្នែកសម្ភព ដែលអាចគំរាមកំហែងដល់អាយុជីវិតក្នុងពេលមានផ្ទៃពោះឬពេលសម្រាលកូន ហើយ៥ទៅ១៥%នៃការសម្រាលកូនទាំងអស់នឹងត្រូវការការវះកាត់។ អង្គការសុខភាពពិភពលោកប៉ាន់ប្រមាណថាទារកដែលទើបនឹងកើតពី ៩ ទៅ១៥% ត្រូវការការថែរក្សាសង្គ្រោះបន្ទាន់។ ដើម្បីការពារអត្រាមរណភាពមាតា និងទារកទើបនឹងកើតដែលបណ្តាលមកពីផលវិបាកមន្ត្រីមន្ទីរពេទ្យបង្អែក(RH) ត្រូវតែធានាថាសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើតកម្រិតមូលដ្ឋាន និងពេញលេញ (Basic and Comprehensive (EmONC) ត្រូវមាន ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍។

## ៧-EmONC កម្រិតមូលដ្ឋាន

ខណៈពេលដែលឆ្មបជំនាញត្រូវការជួយសម្រាលកូននៅក្នុងមូលដ្ឋានសុខាភិបាល ដើម្បីជួយកាត់បន្ថយអត្រាមរណភាពមាតា និងមរណភាពដែលទាក់ទងនឹងការមានផ្ទៃពោះ ការសម្រាលកូន វាប្រហែលជាមិនអាចធ្វើទៅបានទេនៅពេលចាប់ផ្តើមនៃការឆ្លើយតបផ្នែកមនុស្សធម៌។ ទោះយ៉ាងណាក៏ដោយ ត្រូវធានាថានៅតាមមូលដ្ឋានសុខាភិបាលនីមួយៗ EmOC មូលដ្ឋាននឹមានកិច្ចអន្តរាគមន៍ ក៏ដូចជាមានការបញ្ជូនទៅកាន់មន្ទីរពេទ្យដែលមានសេវា ២៤ ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍។

## ៨-សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើតកម្រិតពេញលេញ (Comprehensive EmONC)

បើអាចធ្វើបានជួយគាំទ្រមន្ទីរពេទ្យប្រទេសដែលមានបុគ្គលិកជំនាញហេដ្ឋារចនាសម្ព័ន្ធ រួមទាំងថ្នាំពេទ្យនិងឧបករណ៍វះកាត់ដែលត្រូវការចាំបាច់ ដើម្បីផ្តល់សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើតកម្រិតពេញលេញ។ ប្រសិនបើរឿងនេះ មិនអាចធ្វើទៅបានទេដោយសារទីតាំងមន្ទីរពេទ្យរបស់ប្រទេសម្ចាស់ផ្ទះឬអសមត្ថភាពក្នុងការឆ្លើយតបនឹងតម្រូវការកើនឡើង មន្ត្រីសុខភាពបន្តពូជគួរតែធ្វើការជាមួយផ្នែកសុខភាព/ក្រុមមនុស្សមួយក្រុម និងភ្នាក់ងារមួយដូចជា ភ្នាក់ងារកាកបាទក្រហមកម្ពុជា (CRC) ឬ IFRC ដើម្បីដោះស្រាយបញ្ហាដូចជាការបង្កើតមន្ទីរពេទ្យបង្អែកដែលនៅជិតប្រជាជនដែលរងផលប៉ះពាល់។

## ៩-បង្កើតប្រព័ន្ធបញ្ជូន ដើម្បីគ្រប់គ្រងសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើត

សម្របសម្រួលជាមួយផ្នែកសុខាភិបាល/ ក្រុមភ្នាក់ងារ និងអាជ្ញាធរមូលដ្ឋាន ដើម្បីធានាបាននូវប្រព័ន្ធបញ្ជូន (រួមទាំងមធ្យោបាយទំនាក់ទំនង និងដឹកជញ្ជូន) ឱ្យបានលឿនដែលអាចធ្វើទៅបានក្នុងជំរុំ។ ប្រព័ន្ធបញ្ជូននេះត្រូវតែគាំទ្រដល់ការគ្រប់គ្រងបញ្ហាសម្ភព និងទារកទើបនឹងកើត ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍។ ធានាថាស្ត្រី ក្មេងស្រី និងទារកទើបនឹងកើត ត្រូវការការថែទាំបន្ទាន់ត្រូវបានបញ្ជូនពីសហគមន៍ទៅមូលដ្ឋានសុខាភិបាល ដែលមានសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើតកម្រិតមូលដ្ឋាន។ អ្នកជំងឺដែលមានផលវិបាកផ្នែកសម្ភព និងទារកទើបនឹងកើតដែលមិនអាចគ្រប់គ្រងបាននៅមណ្ឌលសុខភាព ត្រូវតែថែទាំ សង្គ្រោះឱ្យមានស្ថេរភាព និងបញ្ជូនទៅមន្ទីរពេទ្យដោយមានសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើតកម្រិតពេញលេញ។

## ១០-ឧបករណ៍សម្រាលកូនស្អាត(Clean Delivery Kit)

នៅក្នុងស្ថានភាពមានគ្រោះអាសន្ន(មនុស្សធម៌)ទាំងអស់មានស្ត្រី និងក្មេងស្រីដែលស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការមានផ្ទៃពោះហើយ ដូច្នេះពួកគេនឹងសម្រាលកូនក្នុងពេលមានគ្រោះអាសន្ន។ នៅពេលចាប់ផ្តើមនៃការឆ្លើយតបផ្នែកមនុស្សធម៌ ការសម្រាលកូនជាញឹកញាប់នឹងកើតឡើងនៅខាងក្រៅមូលដ្ឋានសុខាភិបាល

ដោយគ្មានជំនួយពីឆ្មបជំនាញ។ ការរៀបចំកញ្ចប់សម្រាលកូនស្អាតដល់ស្ត្រីមានផ្ទៃពោះជាការចាំបាច់ ដើម្បីលើកកម្ពស់ការសម្រាលកូនស្អាតនៅតាមផ្ទះ នៅពេលមណ្ឌលសុខភាពមិនដំណើរការ។

## ១១-ផែនការMISP សម្រាប់ការត្រៀមនិងឆ្លើយតបលើការថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ

ការត្រៀម និងឆ្លើយតបគឺដើម្បីពង្រីកសេវាសុខភាពបន្តពូជនៅពេលសមាសធាតុទាំងអស់នៃប្រព័ន្ធសេវាសុខភាពបន្តពូជនឹងត្រូវបានអនុវត្ត។ វាជាការសំខាន់ណាស់ ដើម្បីធានាថាការផ្គត់ផ្គង់ឬថ្នាំសម្រាប់សុខភាពបន្តពូជ និងទំនិញ(Commodities) ផ្សេងទៀតអាចរកបាន និងបញ្ជាទិញតាមរបៀបសមស្រប និងមាននិរន្តរភាព ដើម្បីឱ្យប្រជាជនដែលរងផលប៉ះពាល់អាចទទួលបានសេវាសុខភាព សុខភាពបន្តពូជ(RH) គ្រប់ជ្រុងជ្រោយដ៏ទូលំទូលាយឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ គោលបំណង MISP ក្នុងសេវាសុខភាពសុខភាពបន្តពូជនេះ រួមបញ្ចូលទៅក្នុងការថែរក្សាសុខភាពបឋមដូចជា ស្ថានភាពអនុញ្ញាត ការសម្របសម្រួលជាមួយផ្នែកសុខភាព និងភ្នាក់ងារទាំងអស់ដូចរាយខាងក្រោមនេះ៖

- ប្រមូលទិន្នន័យ ព័ត៌មាន ដែលមានស្រាប់អំពីមរណភាពមាតា និងទារក។ ការរីករាលដាលនៃជំងឺកាមរោគ ជំងឺអេដស៍ អត្រាប្រេវ៉ាឡង់ វិធីសាស្ត្រ ចំណេះដឹងពីសុខភាពបន្តពូជ និងឥរិយាបទរបស់ប្រជាជន ដែលរងផលប៉ះពាល់ប្រសិនបើមាន
- ជនបង្គោលសុខាភិបាល និងអាជ្ញាធរមូលដ្ឋានរួមទាំងភ្នាក់ងារទទួលខុសត្រូវនៅថ្នាក់ក្រោមជាតិ និងសហគមន៍
- កំណត់ទីតាំងសមស្របសម្រាប់ការផ្តល់សេវាសុខភាពសុខភាពបន្តពូជពេញលេញ នាពេលអនាគត
- វាយតម្លៃសមត្ថភាពរបស់បុគ្គលិកសុខាភិបាលក្នុងការផ្តល់សេវាសុខភាព សុខភាពបន្តពូជឱ្យបានពេញលេញ និងរៀបចំផែនការបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាល
- ការបញ្ជាទិញឧបករណ៍ សម្ភារ និងការផ្គត់ផ្គង់ តាមរយៈខ្សែផ្គត់ផ្គង់ធម្មតាដោយផ្អែកលើការប្រើប្រាស់ដែលបានប៉ាន់ស្មាន និងសង្កេត។

# ឧបសម្ព័ន្ធទី៥

## ឯកសារយោង


1. *Western Pacific regional framework for action, Health Emergency Risk Management of Natural Hazards, December 2012, WPRO*
2. *Estimation of General Population Census of Cambodia 3-13 Mar 2019, National Institute of Statistics,MoP http://www.nis.gov.kh/index.php/en/*
3. *Poverty in Cambodia, redefining the poverty line, Ministry of Planning, April 2013*
4. *Technology Needs Assessment and Technology Action Plan for Climate Change Adaptation, Ministry of Environment, March 2013*
5. *Post-Flood Early Recovery Need Assessment Report, Cambodia 2013, National Committee for Disaster Management.*
6. *Humanitarian Forum Response (HRF) Contingency Plan, Cambodia, February 2014.*
7. *Post-Flood Early Recovery Need Assessment Report, Cambodia 2013, National Committee for Disaster Management.*
8. *Minimum Initiate Service Package (MISP) Inter-Agency Working Group (IAWG) on Reproductive Health in Crisis situation,https://www.ncbi.nlm.nih.gov/books/NBK305157/*
9. *Minimum Standards for Prevention and Response To Gender-based Violence in Emergencies, https://www.unfpa.org/featured-publication/gbvie-standards*

## ឧបសម្ព័ន្ធទី៦

## ការអភិវឌ្ឍសកល និងតំបន់ឯកសារយោង

### ១-ការអភិវឌ្ឍថ្នាក់អន្តរជាតិ

*International Health Regulations* (2005)[3]

*The Inter Agency Standing Committee Humanitarian Reform* (2005)

*'Hospitals Safe from Disasters' 2008-2009 World Disaster Reduction Campaign* (2008-2009)[4]

*The Inter Agency Standing Committee Transformative Agenda* (2012)[5]

*Health and the Post-2015 Framework for Reducing Risks of Disasters* (2013)[6]

*WHO Emergency Response Framework* (2013)[7]

### ២-ការអភិវឌ្ឍថ្នាក់តំបន់

*Association of Southeast Asian Nations Agreement on Disaster Management and Emergency Response* (2005)[8]

*The WHO Southeast Asia Region Office Benchmarks, Standards and Indicators for Emergency Preparedness and Response* (2005)[9]

*WHO Western Pacific Regional Office Regional Framework for Action on Emergency Risk Management on Health related to Natural Hazards* (2013)

*WHO Western Pacific Regional Office Regional Framework for Action on Emergency Risk Management on Health related to Natural Hazards* (2013)

http://www.who.int/topics/international_health_regulations/en/

4 http://www.unisdr.org/2009/campaign/wdrc-2008-2009.html

5 http://www.humanitarianinfo.org/iasc/pageloader.aspx?page=content-template-default&bd=87

6 http://www.who.int/hac/events/2013/en/

7 http://who.int/hac/about/erf/en/

8 http://www.asean.org/communities/asean-socio-cultural-community/item/the-asean-agreement-on-disaster-management-and-emergency-response

9 *http://www.searo.who.int/entity/emergencies/topics/benchmarkstool/en/*

# ឧបសម្ព័ន្ធទី៧

## គោលការណ៍ណែនាំ

- ចាត់ទុកសន្តិសុខសុខភាពជាផ្នែកសារវ័ន្តមួយនៃសន្តិសុខមនុស្ស និងមិនមែនជាទំនិញសាធារណៈដោយឡែកមួយនោះទេ។
- ការផ្តោតលើគ្រោះមហន្តរាយធម្មជាតិ និងគ្រោះមហន្តរាយ ដែលបង្កដោយមនុស្សគឺជាជំហានសារវ័ន្តទី១ ដើម្បីសម្រេចបានការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយពីមុខសញ្ញាគ្រោះថ្នាក់ទាំងអស់។
- កសាងបន្តពីយន្តការ និងក្របខ័ណ្ឌជាតិ ដែលមានស្រាប់ជាក់លាក់ទៅតាមមុខសញ្ញាគ្រោះថ្នាក់។
- ការសង្កត់ធ្ងន់លើការគ្រប់គ្រងគ្រោះអាសន្នគ្រប់ជ្រុងជ្រោយគឺពាក់ព័ន្ធនឹងការដោះស្រាយមុខសញ្ញាគ្រោះថ្នាក់ និងគ្រោះមហន្តរាយ តាមរយៈតុល្យភាពនៃការបន្ធូរបន្ថយការត្រៀមជាមុន ការឆ្លើយតប និងសកម្មភាពស្តារឡើងវិញ។
- ការអនុម័តទស្សនទាន "សុខភាពទាំងមូល"(10) មិនត្រឹមតែពិចារណាអំពីការស្លាប់ឬរបួសប៉ុណ្ណោះទេ ប៉ុន្តែក៏ដាក់បញ្ចូលផងដែរនូវបញ្ហាសុខភាពដទៃទៀត ដូចជាសុខភាពបរិស្ថាន (រួមមាន ទឹក អនាម័យ និងភាពស្អាត) ការគ្រប់គ្រងជំងឺរ៉ាំរ៉ៃ (រួមទាំងសុខភាពផ្លូវចិត្ត) សុខភាពមាតាទារក និងកុមារ ជំងឺឆ្លងអាហារូបត្ថម្ភ ឱសថ និងសេវាថែទាំសុខភាព និងជីវសាស្ត្រ (រួមទាំងហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល) តាមរយៈអភិក្រមផ្សេងៗ ពោលគឺ(១)ពហុស្ថាប័នៈ សម្របសម្រួលភាពជាដៃគូក្នុងចំណោមស្ថាប័ននានា និងបុគ្គលដែលរួមចំណែកដល់ការកាត់បន្ថយហានិភ័យសុខភាព (២)ពហុវិស័យៈ ឆ្លុះបញ្ចាំងថាសុខាភិបាល និងវិស័យដទៃទៀតធ្វើការរួមគ្នាដើម្បីគ្រប់គ្រងហានិភ័យនៃគ្រោះអាសន្នផ្នែកសុខភាព ដែលបង្កឡើងដោយអន្តរកម្មនៃភាពងាយរងគ្រោះ និងភាពធន់របស់មនុស្ស មុខសញ្ញាគ្រោះថ្នាក់ ឬគ្នាក់ងារ និងបរិស្ថានសង្គម វប្បធម៌ ធម្មជាតិ និងសិប្បនិម្មិតរបស់ពួកគេ និង(៣)ពហុផ្នែកៈ ពិចារណាអំពីការរួមចំណែករបស់ផ្នែកជាច្រើននៅក្នុងវិស័យសុខាភិបាល និងវិស័យដទៃទៀត ដែលត្រូវការដើម្បីគ្រប់គ្រងហានិភ័យចំពោះសុខភាព។

# ឧបសម្ព័ន្ធទី៨

## បញ្ជីផ្ទៀងផ្ទាត់ស្តីពី“ការគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាពទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ”

### ផ្នែកទី១ - អភិបាលកិច្ច គោលនយោបាយ និងសម្របសម្រួល

| សកម្មភាព/ដំណើរការសកម្មភាពជាអាទិភាព | ស្ថានភាពបច្ចុប្បន្ន | | |
|---|---|---|---|
| | បានសម្រេច | បានសម្រេចខ្លះ | មិនបានសម្រេច |
| ១-គោលនយោបាយជាតិលើការគ្រប់គ្រងហានិភ័យសុខភាពពេលមានគ្រោះអាសន្ន | | | |
| ១.១-មានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រសួងសុខាភិបាល និងមានរចនាសម្ព័ន្ធច្បាស់លាស់ | x | | |
| កំណត់សម្គាល់៖<br>- មានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រសួងសុខាភិបាលដែលមានប្រធានស្ថាប័នជាប្រធាន និងរដ្ឋលេខាធិការជាអនុប្រធាន<br>- មានលេខាធិការដ្ឋាននៅនាយកដ្ឋានការពារសុខភាព<br>- ត្រូវពិនិត្យរៀបចំឡើងវិញទៅតាមក្របខណ្ឌប្រតិបត្តិថ្មី | | | |
| ១.២-មានលក្ខខណ្ឌបំពេញការងាររបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រសួងសុខាភិបាលពេលមានគ្រោះអាសន្ន | x | | |
| កំណត់សម្គាល់៖<br>- មានប៉ុន្តែចាំបាច់ត្រូវមានការធ្វើបច្ចុប្បន្នភាពឡើងវិញ<br>- តើគួរឱ្យមានអនុគណកម្មាធិការត្រៀមរៀបចំទុកជាមុន ឆ្លើយតប ការត្រលប់មកល្អប្រសើរឡើងវិញ និងការបង្ការឬទេ? | | | |
| ១.៣-ប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រសួងសុខាភិបាល ជាសមាជិករបស់គណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(គ.ជ.គ.ម.) | x | | |
| កំណត់សម្គាល់៖<br>- រដ្ឋមន្ត្រីនៃក្រសួងសុខាភិបាលឬ តំណាងតែងតែចូលរួមការងារជាមួយគ.ជ.គ.ម. | | | |
| ១.៤-តួនាទី និងការទទួលខុសត្រូវនៃដៃគូរអភិវឌ្ឍន៍គន្លឹះក្នុងគណកម្មការគ្រប់គ្រងគ្រោះមហន្តរាយផ្តល់នូវគំនិតសំខាន់ៗដើម្បីធ្វើឱ្យ | | | x |

| | | | |
|---|---|---|---|
| ប្រសើរឡើងនូវការសម្របសម្រួលអន្តរវិស័យ និងកិច្ចសហប្រតិបត្តិការណ៍នៅថ្នាក់ជាតិ និងអន្តរជាតិ | | | |
| កំណត់សម្គាល់៖<br>- អាចប្រើក្រុមការងារសុខាភិបាលជាវេទិកា ដើម្បីពិភាក្សាលើការគាំទ្រ និងជំនួយអន្តរជាតិបើមានការចាំបាច់<br>- ពុំមានយន្តការផ្លូវការក្នុងការសម្រេចពីការទទួលជំនួយពេលមានគ្រោះអាសន្ន/គ្រោះមហន្តរាយ<br>- មានយន្តការជារួមនៅគជគម | | | |
| ១.៥-ប្រព័ន្ធច្បាប់និងការទទួលស្គាល់ជាផ្លូវការនូវក្រុមគ្រូពេទ្យបរទេស និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិត្រូវបានកំណត់ | | | x |
| កំណត់សម្គាល់៖<br>- ក្រសួងត្រូវគិតពីលក្ខខណ្ឌនៃការទទួលយកក្រុមគ្រូពេទ្យបរទេសមកជួយពេលមានគ្រោះមហន្តរាយ | | | |
| ១.៦-មានគោលនយោបាយជាតិ និងអន្តរជាតិ  ក្របខណ្ឌការងារនិងផែនការ ដែលអនុវត្តន៍តាមច្បាប់សុខាភិបាលអន្តរជាតិនិងគណៈកម្មការអចិន្ត្រៃយ៍អន្តរភ្នាក់ងារ | | x | |
| កំណត់សម្គាល់៖<br>- មានលើផ្នែកគ្រប់គ្រងការរាតត្បាតជាសកលលើជម្ងឺគ្រុនផ្តាសាយបក្សី | | | |
| ១.៧. សកម្មភាពនៃការគ្រប់គ្រងហានិភ័យសុខភាពពេលមានគ្រោះអាសន្នបានរៀបផែនការស្របជាមួយវិស័យផ្សេងទៀត និងនៅកន្លែងដែលអាចធ្វើបានក្នុងយុទ្ធសាស្រ្តកិច្ចសហប្រតិបត្តិការប្រចាំអង្គការសុខភាពពិភពលោក_និងការវាយតម្លៃប្រទេសតាមធម្មតាក្នុងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ | | x | |
| កំណត់សម្គាល់៖<br>- ពុំទាន់មានផែនការដែលស៊ីសង្វាក់គ្នាទូលំទូលាយនឹងវិស័យដ៏ទៃទៀតនៅឡើយ | | | |
| ១.៨-រៀបផ្នែកមួយនៅក្នុងក្រសួងសុខាភិបាលដែលទទួលខុសត្រូវ សម្របសម្រួល តាមដានជាប្រចាំនិងវាយតម្លៃគ្រប់សកម្មភាពលើការគ្រប់គ្រងហានិភ័យសុខភាពទាក់ទងទៅនឹងគ្រោះមហន្តរាយ | x | | |
| កំណត់សម្គាល់៖<br>- ពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធនិងលក្ខខណ្ឌប្រតិបត្តិនៃការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាពដើម្បីឱ្យស្របនឹងក្របខ័ណ្ឌការងារគ្រប់គ្រងហានិភ័យគ្រោះអាសន្ន | | | |

| | | | |
|---|---|---|---|
| ២-ធ្វើឱ្យកាន់តែល្អប្រសើរមុខររបស់ផ្នែកនៅថ្នាក់កណ្តាលនិងថ្នាក់ក្រោមជាតិនៃក្រសួងសុខាភិបាលដែលទទួលខុសត្រូវការគ្រប់គ្រង ហានិភ័យសុខភាពពេលមានគ្រោះអាសន្ននៃមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ | | | |
| ២.១-ផ្នែកនេះនៃក្រសួងសុខាភិបាលត្រូវមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងនិងមានអំណាចគ្រប់គ្រាន់ និងធនធានអនុវត្តន៍ កាតព្វកិច្ច និងការទទួលខុសត្រូវលើគ្រប់តំណាក់កាលនៃវដ្តនៃការគ្រប់គ្រង ហានិភ័យសុខភាពពេលមានគ្រោះអាសន្ន (ការពារ ត្រៀមរួចជាស្រេច ឆ្លើយតប និងវិលមកល្អប្រសើរឡើងវិញ) សហការជាមួយនឹងគណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងដៃគូរផ្សេងទៀត | | x | |
| កំណត់សម្គាល់៖<br>- រចនាសម្ព័ន្ធមានរួចហើយ មានការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយនិងសុខភាពបរិស្ថានប៉ុន្តែការសម្រេចចិត្តត្រូវស្នើរដល់ប្រធានស្ថាប័ន<br>- ធនធានហិរញ្ញវត្ថុនៅមានកំណត់<br>- ត្រូវស្វែងរកការគាំទ្របន្ថែមទៀតពីថ្នាក់ដឹកនាំ | | | |
| ២.២-ផ្នែកឬការិយាល័យនៃក្រសួងសុខាភិបាលត្រូវរក្សាប្រព័ន្ធគ្រប់គ្រងព័ត៌មានសហការ ជាមួយនឹងគណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនិងដៃគូរផ្សេងទៀតដើម្បីប្រមូលចងក្រង ចែករំលែក សមាហរណកម្ម និងរក្សាទុកព័ត៌មានសុខាភិបាលដែលទាក់ទងទៅនឹងការគ្រប់គ្រង ហានិភ័យសុខភាពពេលមានគ្រោះអាសន្ន | | | x |
| កំណត់សម្គាល់៖<br>- ប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រោះមហន្តរាយបានបង្កើតដោយគជគម ដែលមានឈ្មោះថា កាមឌី តែពុំទាន់មានព័តមានជាក់លាក់សម្រាប់ព័ត៌មានគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាពនៅឡើយ<br>- ដូច្នេះត្រូវរៀបចំឱ្យមានប្រព័ន្ធព័ត៌មានគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាព | | | |
| ២.៣-ផ្សព្វផ្សាយគោលការណ៍ណែនាំ និង ស្តង់ដារដើម្បីរៀបចំ លំហាត់លើការគ្រប់គ្រង ហានិភ័យសុខភាពពេលមានគ្រោះអាសន្ននៅថ្នាក់ក្រោមជាតិដែលសុខុដម្យជាមួយផែនការជាតិ | | | x |
| កំណត់សម្គាល់៖<br>- ត្រូវធ្វើផែនការគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាព<br>- អនុវត្តសាកល្បងផែនការជាទៀងទាត់ | | | |
| ២.៤- យកតាម បង្កើត ឬកែសម្រួលនិងផ្សព្វផ្សាយស្តង់ដាជាតិនៃសេវាសុខាភិបាលសារវ័ន តាមផ្នែកសុខភាពនិងតាមកម្រិតនៃ | x | | |

| | | | |
|---|---|---|---|
| ការព្យាបាល | | | |
| កំណត់សម្គាល់៖<br>- ពិនិត្យឡើងវិញនូវស្តង់ដាជាតិនៃសេវាសុខាភិបាលសារវ័ន រៀបចំជាសំណុំតាមផ្នែកនៃការឆ្លើយតបនិងតាមកម្រិតនៃសេវាថែទាំព្យាបាលដើម្បីសម្រួលក្នុងការផ្គត់ផ្គង់ធនធាន | | | |
| ២.៥- ផ្តល់ការគាំទ្រដល់ក្រុមគ្រប់គ្រងហេតុការណ៍មកប្រជុំដើម្បីសម្របសម្រួលការឆ្លើយតប។ផ្តល់ការពង្រឹងបន្ថែមដល់មជ្ឈមណ្ឌលសម្របសម្រួលប្រតិបត្តិការគ្រោះអាសន្នដែលមានស្រាប់ក្នុងក្រសួងសុខាភិបាលនិងប្រើប្រាស់ក្នុងពេលមានហេតុការណ៍ | | x | |
| កំណត់សម្គាល់៖<br>- មជ្ឈមណ្ឌលសម្របសម្រួលប្រតិបត្តិការគ្រោះអាសន្នកំពុងតែបានរៀបចំឡើងក្នុងនាយកដ្ឋានប្រយុទ្ធនឹងជម្ងឺឆ្លង | | | |
| ២.៦-ផ្នែកឬការិយាល័យនៃក្រសួងសុខាភិបាលរៀបចំការប្រជុំសម្ព័ន្ធភាព/ធ្វើផែនការនឹងវិស័យសុខាភិបាល/កំរងដៃគូរអភិវឌ្ឍន៍ និងក្រុមអង្គការសហប្រជាជាតិក្នុងប្រទេស | | | x |
| កំណត់សម្គាល់៖<br>- នឹងរៀបចំនៅពេលរចនាសម្ព័នបច្ចុប្បន្នបានពិនិត្យនិងរៀបចំឡើងវិញ | | | |

## ផ្នែកទី២ - ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង

| សកម្មភាព/ដំណើរការសកម្មភាពជាអាទិភាព | ស្ថានភាពបច្ចុប្បន្ន | | |
|---|---|---|---|
| | បានសម្រេច | បានសម្រេចខ្លះ | មិនបានសម្រេច |
| ៣-រៀបចំផែនទីហានិភ័យពហុវិស័យ និងធ្វើការវាយតម្លៃប៉ាន់ប្រមាណជាទៀងទាត់ ដើម្បីកំណត់នូវផលវិបាកដែលនឹងកើតមានពីមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ | | | |
| ៣.១-កំណត់អ្នកទទួលខុសត្រូវក្នុងក្រសួងសុខាភិបាលដើម្បីដឹកនាំឬសម្របសម្រួលការធ្វើការប៉ាន់ប្រមាណវិស័យសុខាភិបាល | x | | |
| កំណត់សម្គាល់៖<br>- បច្ចុប្បន្នមានមន្ត្រីបង្គោលសម្រាប់សម្របសម្រួលទៅតាមប្រភេទហានិភ័យ។កន្លងមកការធ្វើការប៉ាន់ប្រមាណធ្វើតែលើការខូចខាត ហើយធ្វើជាពហុវិស័យដឹកនាំដោយគ.ជ.គ.ម. | | | |

| | | | |
|---|---|---|---|
| - នៅពេលរៀបចំរចនាសម្ព័ន្ធឡើងវិញត្រូវកំណត់ក្រុមឬនាយកដ្ឋានដែលទទួលខុសត្រូវការប៉ាន់ប្រមាណហានិភ័យគ្រោះអាសន្នសម្រាប់សុខភាព | | | |
| ៣.២-រាល់មុខសញ្ញាគ្រោះថ្នាក់ធម្មជាតិដែលមានសក្តានុពលដូចជារញ្ជួយដីខ្យល់ព្យុះទឹកជំនន់បាក់ដីរាំងស្ងួតត្រូវបានកំណត់រកឃើញ និងគូសជាផែនទីតាមភូមិសាស្ត្រនិងមូលដ្ឋានរដ្ឋបាល | | | x |
| កំណត់សម្គាល់៖<br>- ការកំណត់រកឃើញមុខសញ្ញាគ្រោះថ្នាក់គឺធ្វើដោយគជគមនិងក្រសួងធនធានទឹកនិងឧត្តុនិយម<br>- នាយកដ្ឋានការពារសុខភាពមានតួនាទីផ្តល់ព័ត៌មានដល់ថ្នាក់ដឹកនាំនិងថ្នាក់ក្រោមជាតិ<br>- គ.ជ.គ.ម. ខេត្តក្រុងមានផែនទីមុខសញ្ញាគ្រោះថ្នាក់តាមតំបន់ភូមិសាស្ត្ររបស់ខ្លួន<br>- មន្ទីរសុខាភិបាលខេត្តក្រុងដឹងពីហានិភ័យដែលអាចបណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់តែពុំទាន់បានរៀបចំជាផែនទីនៅឡើយ | | | |
| ៣.៣-ភាពងាយរងគ្រោះនិងសមត្ថភាពនៃក្រុមប្រជាជនដែលប្រឈមទៅនឹងមុខសញ្ញាគ្រោះថ្នាក់បានធ្វើការប៉ាន់ប្រមាណដោយប្រើប្រាស់ទិន្នន័យដែលមានស្រាប់ | | | x |
| កំណត់សម្គាល់៖<br>- ពត៌មានអំពីភាពងាយរងគ្រោះត្រូវបានប្រមូលដោយគណកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្តតាមប្រភេទនៃគ្រោះមហន្តរាយ<br>- ពត៌មានទាក់ទងនឹងសុខភាពប្រមូលដោយមន្ទីរសុខាភិបាលដោយមានការគាំទ្រពីថ្នាក់ក្រសួងនិងមានមន្ត្រីបង្គោលសម្រាប់ទំនាក់ទំនង<br>- មុខសញ្ញាគ្រោះថ្នាក់និងភាពងាយរងគ្រោះក្រៅពីសុខភាពជាភារកិច្ចរបស់គណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនិងក្រសួងធនធានទឹក និងឧតុនិយម<br>- ក្រសួងធនធានទឹកនិចឧតុនិយមចេញសេចក្តីព្រមានបើសិនជាមានមុខសញ្ញាគ្រោះថ្នាក់ណាមួយនឹងកើតឡើង | | | |
| ៣.៤-បានបង្កើតផែនទីហានិភ័យថ្នាក់ជាតិនិងមូលដ្ឋានដែលបង្ហាញពីកន្លែងងាយរងគ្រោះ និងកំណត់រកឃើញកន្លែងដែលរងគ្រោះជាងគេផែនទីត្រូវបង្កើតឡើងដោយបំបែកទិន្នន័យទៅតាមហានិភ័យមុខសញ្ញាគ្រោះថ្នាក់និងភាពងាយរងគ្រោះ | | | x |
| កំណត់សម្គាល់៖<br>- ពិនិត្យឡើងវិញក្នុងការរៀបចំផែនទីហានិភ័យ | | | |
| ៣.៥-មូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជនរួមទាំងសេវាបានរៀបចំចងក្រងជាឯកសារតាមភូមិសាស្ត្រមូលដ្ឋានរដ្ឋបាល ប្រភេទនៃមូលដ្ឋានសុខាភិបាលសេវាសុខភាពដែលមាន និងកម្រិតនៃការព្យាបាល | | x | |

| | | | |
|---|---|---|---|
| កំណត់សម្គាល់៖<br>- ព័ត៌មានទាំងនេះមានគ្រប់គ្រាន់សម្រាប់សេវាសាធារណៈ តែចំពោះសេវាឯកជននៅមានកម្រិតនៅឡើយ<br>- ផែនទីមូលដ្ឋានសុខាភិបាលសាធារណៈតាមប្រព័ន្ធ *GIS* មាននៅនឹងដៃនៅក្រសួងសុខាភិបាលនិងកំពុងតែធ្វើបច្ចុប្បន្នភាព<br>- ផែនទីមូលដ្ឋានសុខាភិបាលសាធារណៈតាមប្រព័ន្ធ *GIS* ចុងក្រោយធ្វើនៅ២០០៤និងកំពុងបច្ចុប្បន្នភាពនៅឆ្នាំ២០១៤ | | | |
| ៤-នីតិវិធីដើម្បីប្រមូលគ្រប់គ្រងសំយោគវិភាគនិងផ្លាស់ប្តូរព័ត៌មានពីការប៉ាន់ប្រមាណដែលរៀបចំរវាងដៃគូរក្នុងវិស័យសុខាភិបាលទៅ | | | |
| ៤.១-បានបង្កើតប្រព័ន្ធព្រមព្រៀងមួយក្នុងការប្រមូលទុកដាក់និងប្រើប្រាស់ព័ត៌មានដើម្បីធ្វើការប៉ាន់ប្រមាណនិងឆ្លើយតបបន្ទាន់តាមតំណាក់កាលនៃគ្រោះអាសន្ន៖ពត៌មានមុនហេតុការណ៍និយមន័យនៃទិដ្ឋភាពបឋមនៃហេតុការណ៍និងការប៉ាន់ប្រមាណដំបូងនិងរហ័សពហុវិស័យ | | | x |
| កំណត់សម្គាល់៖<br>- ពុំទាន់មានប្រព័ន្ធផ្លូវការណាមួយសម្រាប់ព័ត៌មានលើសុខភាពពេលមានគ្រោះអាសន្នដើម្បីចែករំលែកនៅឡើយ<br>- មានតែប្រព័ន្ធព័ត៌មានសុខាភិបាលដែលប្រមូលព័ត៌មានលើបញ្ហាសុខភាពសារវ័នដែលកំណត់ដោយគោលនយោបាយសុខាភិបាល<br>- មានប្រព័ន្ធរបាយការណ៍សូន្យដែលរាយការណ៍ពីជម្ងឺឆ្លងដែលតាមដានចំនួន១០<br>- មានការត្រៀមទុកជាស្រេចនិងការការពារមុនពេលមានគ្រោះមហន្តរាយ តែនៅតែទៀមទារការពិនិត្យឡើងវិញនិងកែរលម្អបន្ថែម<br>- នៅពេលមានគ្រោះមហន្តរាយធ្ងន់ធ្ងរនាយករដ្ឋមន្ត្រីដឹកនាំការឆ្លើយតបរួមនឹងរាល់សមាជិកគជគមពាក់ព័ន្ធ<br>- ការប៉ាន់ប្រមាណដំបូងនិងរហ័សពហុវិស័យបានធ្វើនៅពេលមានទឹកជំនន់ឆ្នាំ២០០០តែបន្តមកទៀតពុំបានអនុវត្តទេ ពេលនោះពុំទាន់មាននិយាយពីពហុវិស័យនៅឡើយ<br>- ត្រូវរៀបចំឱ្យមានឱ្យស្របទៅតាមក្របខណ្ឌការងាររបស់អង្គការសុខភាពពិភពលោក | | | |
| ៤.២-បុគ្គលិកសុខាភិបាលសំខាន់ៗបានទទួលការបណ្តុះបណ្តាលដោយប្រើប្រព័ន្ធជាផែនទីពីធនធានសុខាភិបាលដែលមានស្រាប់ (HeRAMs *)* ជាឧបករណ៍ដើម្បីប្រើក្នុងការគាំទ្រការប៉ាន់ប្រមាណតម្រូវការក្នុងពេលឆ្លើយតប | | | x |
| កំណត់សម្គាល់៖<br>- មានការបណ្តុះបណ្តាលមន្ត្រីនិងបុគ្គលិកសុខាភិបាលដែលទទួលខុសត្រូវការងារគ្រប់គ្រងគ្រោះមហន្តរាយតាមមន្ទីរសុខាភិបាលនិងមន្ទីរពេទ្យ<br>- មានកំណត់ត្រាពីចំនួនដែលបានបណ្តុះបណ្តាល( នាយកដ្ឋានការពារសុខភាព) | | | |
| ៤.៣-វិស័យសុខាភិបាល/កំរងដៃគូរអភិវឌ្ឍន៍បានសម្របតាមកំរងទិន្នន័យប្រតិបត្តិការរួមនិងតាមប្រព័ន្ធទិន្នន័យនេះព្រមព្រៀងក្នុង | | | x |

| | | | |
|---|---|---|---|
| ការផលិតរក្សាទុកនិងចែករំលែកកំរងទិន្នន័យប្រតិបត្តិការផ្នែកសុខភាព | | | |
| កំណត់សម្គាល់៖<br>- ត្រូវគិតពីការរៀបចំឱ្យមានកំរងទិន្ន័យប្រតិបត្តិការពេលមានគ្រោះមហន្តរាយ/គ្រោះអាសន្ន | | | |
| ៤.៤-មានយន្តការដែលវិស័យសុខាភិបាល/កំរងវិភាគព័ត៌មាននិងទិន្នន័យពីការប៉ាន់ប្រមាណនិងតាមដានជាប្រចាំផលិ និងចែករំលែកចំណេះដឹងដែលអ្នកធ្វើការសម្រេចចិត្តអាចយកមកប្រើក្នុងការកំណត់រកនូវអាទិភាពក្នុងតំណាក់កាលនីមួយៗ នៃវដ្តនៃការគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាពនិងចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្រ្តអន្តរវិស័យ | | x | |
| កំណត់សម្គាល់៖<br>- មានយន្តការសម្រាប់ឆ្លើយតប<br>- ព័ត៌មានពីផលប៉ះពាល់ត្រូវបានរាយការទៅរដ្ឋមន្រ្តីដើម្បីសុំការសម្រេចចិត្តឬអាចសម្រេចបាននៅតាមថ្នាក់មូលដ្ឋានអាស្រ័យទំហំនៃបញ្ហា | | | |
| ៤.៥-មានបញ្ជីមន្រ្តីនិងបុគ្គលិកដែលបានបណ្តុះបណ្តាលនិងបានរៀបជាក្រុមដើម្បីធ្វើការប៉ាន់ប្រមាណនិងសេចក្តីណែនាំផ្សេងៗ ដើម្បីអង្កេតនិងធ្វើរបាយការណ៍ | | x | |
| កំណត់សម្គាល់៖<br>- មានមួយចំនួនគឺរក្សាទុកតាមនាយកដ្ឋានទទួលខុសត្រូវព្រោះភាគច្រើនជាការបណ្តុះបណ្តាលបន្តក្នុងការងារ<br>- ការបណ្តុះបណ្តាលពុំបានធ្វើទៀងទាត់ទេដោយបញ្ហាកង្វះថវិកា | | | |
| ៥-បានរៀបចំនីតិវិធីយន្តការនិងគោលនយោបាយសម្រាប់ការប្រាស្រ័យទាក់ទងពីហានិភ័យទៅសាធារណជនប្រព័ន្ធផ្សព្វផ្សាយ និងអ្នកឆ្លើយតប | | | |
| ៥.១-មានប្រព័ន្ធរួចជាស្រេចដើម្បីបង្កើតផ្សព្វផ្សាយនិងវាយតម្លៃសារ (មុខសញ្ញាគ្រោះថ្នាក់សមស្រប) ដោយផ្អែកលើការប៉ាន់ប្រមាណលើផលប៉ះពាល់នៃហេតុការណ៍ | | x | |
| កំណត់សម្គាល់៖<br>- មានប្រព័ន្ធតែមិនទាន់ជាផ្លូវការពេញលេញ<br>- សារបានរៀបចំដោយនាយកដ្ឋានទទួលខុសត្រូវតាមប្រភេទនៃមុខសញ្ញាគ្រោះថ្នាក់<br>- សារទាំងនោះត្រូវបានអនុមតិដោយថ្នាក់ដឹកនាំ | | | |

| | | | |
|---|---|---|---|
| - កាតរវាយតម្លៃការយល់ដឹងពីសារផ្សព្វផ្សាយមានតិចបំផុត | | | |
| ៥.២-ផ្នែកគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាពត្រូវរៀបចំសារដែលចាំបាច់ជាមុនធ្វើការសាកល្បងនិងវាយតម្លៃសារប្រាស្រ័យទាក់ទងហានិភ័យគំរូ ដើម្បីអាចផ្សព្វផ្សាយភ្លាមៗនៅពេលមានហេតុការណ៍កើតឡើង | | | x |
| កំណត់សម្គាល់៖<br>- មានមួយចំនួនតិច<br>- មានការជួយពីអង្គការដូចជាអង្គការយូនីសេហ្វ | | | |
| ៥.៣-នីតិវិធីនិងយន្តការដើម្បីផ្សព្វផ្សាយសារតាមរយៈប្រព័ន្ធផ្សព្វផ្សាយនិងស្ថានីយ៍ផ្សព្វផ្សាយដែលមានត្រូវធ្វើការសាកល្បងនិងឱ្យមានសុពលភាព | | x | |
| កំណត់សម្គាល់៖<br>- សារត្រូវបានអនុមតិនិងចុះហត្ថលេខាដោយរដ្ឋមន្ត្រី<br>- សារខ្លះមិនបានសាកល្បងនិងពិនិត្យលើសពុលភាពនៃសារ<br>- ស្ថានីយ៍មានដូចជាស្ថានីយ៍វិទ្យុ ទូរទស្សន៍  ការសែតនិងគេហទំព័រ | | | |

## ផ្នែកទី៣ - ការផ្តល់សេវាសុខាភិបាល

| សកម្មភាព/ដំណើរការសកម្មភាពជាអាទិភាព | ស្ថានភាពបច្ចុប្បន្ន | | |
|---|---|---|---|
| | បានសម្រេច | បានសម្រេចខ្លះ | មិនបានសម្រេច |
| ៦-បន្ទីគ្នារវាងសេវាសុខភាពដែលមានជាមួយនឹងការប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់និងហានិភ័យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | | |
| ៦.១-កំណត់រកឃើញកន្លែងដែលមានហានិភ័យនៃមុខសញ្ញាគ្រោះថ្នាក់ខ្ពស់ និងការគ្របដណ្តប់ទាបនៃសេវាការពារនិងកម្មវិធីគន្លឹះ | X | | |
| *កំណត់សម្គាល់៖*<br>- សម្រាប់ទឹកជំនន់ កន្លែងមានហានិភ័យខ្ពស់គឺនៅតាមបណ្តោយទន្លេមេគង្គ មន្ទីរសុខាភិបាលដឹងពីកន្លែងដែលមានហានិភ័យខ្ពស់របស់គេ<br>- មន្ទីរសុខាភិបាលក៏ដឹងផងដែរពីកន្លែងដែលសេវាការពារឬកម្មវិធីមានអត្រាគ្របដណ្តប់ទាប | | | |

| | | | |
|---|---|---|---|
| - ការប៉ាន់ប្រមាណលើការខូចខាតនិងតម្រូវការបានធ្វើសឹងតែរៀងរាល់ឆ្នាំ<br>- មណ្ឌលសុខភាពជាមូលដ្ឋានដែលទទួលរងគ្រោះនិងងាយរងគ្រោះជាងគេ<br>- ព័ត៌មានពីសេវាការពារគន្លឹះនិងកម្មវិធីអាចរកបានពីការិយាល័យប្រព័ន្ធព័ត៌មានសុខាភិបាលនៃនាយកដ្ឋានផែនការនិងប្រព័ន្ធព័ត៌មានសុខាភិបាលនៃក្រសួងសុខាភិបាល | | | |
| ៦.២-កំណត់រកឃើញសេវាសុខាភិបាលដែលត្រូវការពង្រឹងបន្ថែម | | X | |
| កំណត់សម្គាល់៖<br>**-មុនទឹកជំនន់**<br>+កម្មវិធីគាំពារមាតានិងកុមារត្រូវពង្រឹងបន្ថែមដូចជាជំនាញឆ្មប<br>+ជំនាញសង្គ្រោះសម្ភពបន្ទាន់ជនាញសង្គ្រោះបឋមលើអ្នកតងគ្រោះពស់ចឹកសេរ៉ូមបន្សាបពិសពស់<br>+លើកកំពស់ចំណេះដឹងលើប្ចាសុខភាពមូលដ្ឋានដូចជាសុវត្ថិភាពទឹក<br>+ឱសថពន្យាពុំមាននៅតាមមណ្ឌលសុខភាព<br>**-ពេលទឹកជំនន់**<br>+ផែនការត្រៀមរួចជាស្រេចរបស់មន្ទីរពេទ្យមានតែនៅថ្នាក់ជាតិនិងខេត្តដូចជាការត្រៀមក្រុមគ្រូពេទ្យចល័តនិងមុខងារពិសេសសម្រាប់ការជួយសង្គ្រោះមុនមកដល់មន្ទីរពេទ្យ<br>+ប្រព័ន្ធបញ្ហាគ្រោះអាសន្នក្នុងមន្ទីរពេទ្យមានតែនៅមន្ទីរពេទ្យថ្នាក់ជាតិនិងខេត្ត<br>+ការថែទាំសុខភាពស្មារតីភាពតានតឹងចប់អារម្មណ៍ក្រោយពេលរងគ្រោះនៃប្រជាជននិងក្រុមពេទ្យចល័តត្រូវតែពង្រឹងបន្ថែម | | | |
| ៦.៣-កត់ត្រាជាឯកសារនូវការត្រៀមទុករួចនូវសេវាសុខភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ តាមកម្រិតនៃការព្យាបាល | | | X |
| កំណត់សម្គាល់៖<br>- មន្ទីរពេទ្យបង្អែកខេត្តនិងស្រុកមានរថនាសម្ព័ន្ធសម្រាប់ការសង្គ្រោះបន្ទាន់<br>- ពុំមានឯកសារណែនាមពីការឆ្លើយតបពេលមានគ្រោះមហន្តរាយទេត្រូវរៀបចំឱ្យមានជាសេចក្តីណែនាំឬនីតិវិធីប្រតិបត្តិការស្តង់ដាសម្រាប់ការឆ្លើយតបពេលមានគ្រោះអាសន្ន/គ្រោះមហន្តរាយ | | | |
| ៧. បង្កើតយុទ្ធសាស្ត្រ "សន្ទុះកើនឡើង " នៃការផ្តល់សេវាសុខភាពដែលចែកជាផែនការគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិការផ្តល់សេវាសុខភាពតាមផ្នែកផ្សេងៗ | | | |

| | | | |
|---|---|---|---|
| ៧.១-រៀបចំផែនការត្រៀមបម្រុងទុកជាមុនតាមសេណារីយ៉ូមូលដ្ឋាននៃវិស័យសុខាភិបាល | | | |
| កំណត់សម្គាល់៖<br>- មិនទាន់មានផែនការត្រៀមបម្រុងទុកជាមុនតែចាំបាច់ត្រូវរៀបចំបង្កើត | | | X |
| ៧.២-បង្កើតយន្តការនិងនីតិវិធីដើម្បីដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធសុខភាពនិងចាត់ក្រុមចល័តឬក្រុមផ្សេងទៀតតាមគោលដៅនៅកន្លែងដែលប្រព័ន្ធសុខាភិបាលមិនទាន់ដំណើរការល្អ | | | X |
| កំណត់សម្គាល់៖<br>- មន្ត្រីបង្គោលផ្នែកគ្រោះមហន្តរាយនៅមន្ទីរសុខាភិបាលនិងមន្ទីរពេទ្យបង្អែកខេត្តបានទទួលការបណ្តុះបណ្តាលពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការត្រៀមរៀបចំរួចជាស្រេចពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយមិនទាន់ជាអាទិភាពនៅតាមខេត្តមួយចំនួន<br>- គ្មានថវិកា<br>- ចាំបាច់រៀបចំយន្តការនិងនីតិវិធីដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្តោះអាសន្នក្នុងការប្រើក្រុមទាំងនោះ | | | |
| ៧.៣-មានយន្តការ "សន្ទុះកើនឡើង ដោយផ្អែកលើការវិភាគហានិភ័យ មានធនធានមនុស្សនិងស្តុកនូវសម្ភារផ្គត់ផ្គង់ដែលបានរៀបទុកជាមុននិងឧបករណ៍ | | | |
| កំណត់សម្គាល់៖<br>- មិនទាន់មានយន្តការ "សន្ទុះកើនឡើង "ដែលត្រូវតែរៀបចំឱ្យមាន។ | | | X |
| ៨- រៀបចំឬបង្កើនកម្មវិធីផ្តួចផ្តើមពីសុវត្ថិភាពមន្ទីរពេទ្យដើម្បីគ្របដណ្តប់មូលដ្ឋានសុខាភិបាលសំខាន់ៗនៅតំបន់ដែលប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ | | | |
| ៨.១-រៀបចំគោលនយោបាយសេចកតីណែនាំស្តង់ដានិងនីតិវិធីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីការផ្តួចផ្តើមសុវត្ថិភាពមន្ទីរពេទ្យ | | X | |
| កំណត់សម្គាល់៖<br>- មន្ត្រីមន្ទីរពេទ្យបង្អែកខេត្តទទួលការបណ្តុះបណ្តាលពីសុវត្ថិភាពមន្ទីរពេទ្យ<br>- មានកម្មវិធីសិក្សាដែលមាន២០ម៉ូឌុលជាភាសាខ្មែរ<br>- ត្រូវរៀបចំសេចក្តីណែនាំនិងត្រូវការថវិកាដើម្បីគាំទ្រការអនុវត្តសុវត្ថិភាពមន្ទីរពេទ្យ | | | |
| ៨.២-កំណត់រកមូលដ្ឋានសុខាភិបាលដែលសំខាន់នៅកន្លែងមានហានិភ័យខ្ពស់តាមការធ្វើការប៉ាន់ប្រមាណនិងរៀបចំជាផែនទីតាមរចនាសម្ព័ន្ធក្រៅរចនាសម្ព័ន្ធនិងមុខងារ | | | |

| | | | |
|---|---|---|---|
| កំណត់សម្គាល់៖<br>- មន្ទីរសុខាភិបាលស្គាល់ពីមូលដ្ឋានសុខាភិបាលនិងកន្លែងដែលមានហានិភ័យខ្ពស់<br>- ចាំបាច់រៀបចំជាផែនទីដាក់បញ្ចូលគ្នា | | | |
| ៨.៣-រៀបចំយន្តការសម្រាប់ការប៉ាន់ប្រមាណរហ័សមូលដ្ឋានសុខាភិបាលដើម្បីជួសជុលមូលដ្ឋានសុខាភិបាលណាដែលសំខាន់ | | | |
| កំណត់សម្គាល់៖<br>- ផ្អែកលើបទពិសោធន៍ក្នុងការដឹកនាំការគ្រប់គ្រងអ្នករងគ្រោះច្រើននៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតមាននីតិវិធីគ្រប់គ្រងសាកសព<br>- រៀបចំយន្តការ និង ឧបករណ៍ដើម្បីធ្វើការប៉ាន់ប្រមាណរហ័សមូលដ្ឋានសុខាភិបាល | | | X |
| ៨.៤-ការសាងសង់មន្ទីរពេទ្យថ្មីត្រូវធ្វើតាមស្តង់ដារសុវត្ថិភាពមន្ទីរពេទ្យ | | | X |
| កំណត់សម្គាល់៖<br>- គ្មានយន្តការ គ្មានស្តង់ដារនៅឡើយ<br>- ត្រូវតែរៀបចំឱ្យមាន | | | |

## ផ្នែកទី៤ - ធនធាន (ជំនាញ មនុស្ស ហិរញ្ញវត្ថុ សម្ភារ និងការផ្គត់ផ្គង់)

| សកម្មភាព/ដំណើរការសកម្មភាពជាអាទិភាព | ស្ថានភាពបច្ចុប្បន្ន | | |
|---|---|---|---|
| | បានសម្រេច | បានសម្រេចខ្លះ | មិនបានសម្រេច |
| ៩-បង្កើតសវនកម្មជំនាញនិងបទពិសាធន៍លើការគ្រប់គ្រងហានិភ័យសុខភាពពេលមានគ្រោះអាសន្នឱ្យមានឬក៏ត្រូវការដោយកន្លែងរដ្ឋបាល | | | |
| ៩.១-មានទិន្នន័យប្រព័ន្ធវិទ្យាពីការបណ្តុះបណ្តាលនិងបុគ្គលិកជំនាញ (រួមមានកាកបាទក្រហមអង្គការក្រៅរដ្ឋាភិបាលសង្គមស៊ីវិលអង្គការអន្តរជាតិយោធាប៉ូលីសនិងអង្គភាពការពារស៊ីវិល។ល។) | | X | |
| កំណត់សម្គាល់៖<br>- បច្ចុប្បន្នមានទិន្នន័យពីការបណ្តុះបណ្តាលលើការគ្រប់គ្រងគ្រោះមហន្តរាយដែលធ្វើឡើងដោយនាយកដ្ឋានការពារសុខភាព<br>- នាយកដ្ឋានធនធានមនុស្សគឺមានទិន្នន័យពីការបណ្តុះបណ្តាលមូលដ្ឋាននិងបន្ត។ | | | |

| | | | |
|---|---|---|---|
| - ត្រូវរៀបចំឱ្យមានទិន្នន័យវិទ្យាពីការបណ្តុះបណ្តាលនិងបុគ្គលិកជំនាញ ( នាយកដ្ឋានទទួលខុសត្រូវ? ថ្នាក់កណ្តាល? ថ្នាក់ខេត្ត?) | | | |
| ៩.២-ធ្វើការវិភាគតម្រូវការបណ្តុះបណ្តាលលើការគ្រប់គ្រងហានិភ័យ សុខភាពពេលមានគ្រោះអាសន្ន។ល។ | | | X |
| កំណត់សម្គាល់៖<br>- ដឹកនាំដោយនាយកដ្ឋានការពារសុខភាពបានធ្វើពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល ( *PHEMAP* ថ្នាក់ជាតិ)<br>- ព័ត៌មានត្រូវបានស្រង់បន្ទាប់ពីទឹកជំនន់តែពុំទាន់បានរៀបចំជាផែនទីហានិភ័យសុខភាពនៅឡើយ<br>- ជាទូទៅគឺមន្ទីរសុខាភិបាលខេត្តមានក្រុមចុះធ្វើការប៉ាន់ស្មានលើការប៉ះពាល់ពីទឹកជំនន់<br>- មានការយល់ដឹងពីហានិភ័យពេលទឹកជំនន់តែមិនទាន់មានផែនទី<br>- សុំធ្វើការជាមួយក្រសួងធនធានទឹក គ.ជ.ម.គ. និងអង្គការពាក់ព័ន្ធពីផែនទីមុខសញ្ញាគ្រោះថ្នាក់និងហានិភ័យ | | | |
| ៩.៣-បង្កើតកម្មវិធីជាតិដើម្បីអប់រំនិងបណ្តុះបណ្តាលលើការគ្រប់គ្រងហានិភ័យសុខភាពពេលមានគ្រោះអាសន្ន | | | X |
| កំណត់សម្គាល់៖<br>- ព័ត៌មានអំពីភាពងាយរងគ្រោះត្រូវបានប្រមូលដោយគណកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្តតាមប្រភេទនៃគ្រោះមហន្តរាយ<br>- ព័ត៌មានទាក់ទងនឹងសុខភាពប្រមូលដោយមន្ទីរសុខាភិបាលដោយមានការគាំទ្រពីថ្នាក់ក្រសួងនិងមានមន្ត្រីបង្គោលសម្រាប់ទំនាក់ ទំនង<br>- មុខសញ្ញាគ្រោះថ្នាក់និងភាពងាយរងគ្រោះក្រៅពីសុខភាពជាភារកិច្ចរបស់គណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនិងក្រសួង ធនធានទឹកនិងឧត្តុនិយម<br>- ក្រសួង ធនធានទឹកនិថឧត្តុនិយមចេញសេចក្តីព្រមានបើសិនជាមានមុខសញ្ញាគ្រោះថ្នាក់ណាមួយនឹងកើតឡើង | | | |
| ៩.៤-ផ្តល់ការបណ្តុះបណ្តាលនិងអប់រំដល់សហគមន៍មូលដ្ឋានលើការប៉ាន់ប្រមាណហានិភ័យ | | | X |
| កំណត់សម្គាល់៖<br>- គណកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយជាតិនិងកាកបាទក្រហមកម្ពុជាបានធ្វើការបណ្តុះបណ្តាលលើការប៉ាន់ប្រមាណហានិភ័យក្រសួងសុខាភិបាលបានធ្វើការងារនេះតាំងពី១០ឆ្នាំមុន | | | |

| | | | |
|---|---|---|---|
| - តម្រូវឱ្យមានការបណ្តុះបណ្តាលនិងអប់រំដល់សហគមន៍មូលដ្ឋានលើការប៉ាន់ប្រមាណហានិភ័យ | | | |
| ៩.៥. មូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជនរួមទាំងសេវាបានរៀបចំចងក្រងជាឯកសារតាមភូមិសាស្ត្រមូលដ្ឋានរដ្ឋបាលប្រភេទនៃមូលដ្ឋានសុខាភិបាលសេវាសុខភាពដែលមាននិងកម្រិតនៃការព្យាបាល | | X | |
| កំណត់សម្គាល់៖<br>- ព័ត៌មានទាំងនេះមានគ្រប់គ្រាន់សម្រាប់សេវាសាធារណៈ តែចំពោះសេវាឯកជននៅមានកម្រិតនៅឡើយ<br>- ផែនទីមូលដ្ឋានសុខាភិបាលសាធារណៈតាមប្រព័ន្ធ *GIS* មាននៅនឹងដៃនៅក្រសួងសុខាភិបាលនិងកំពុងតែធ្វើបច្ចុប្បន្នភាព<br>- ផែនទីមូលដ្ឋានសុខាភិបាលសាធារណៈតាមប្រព័ន្ធ *GIS* ចុងក្រោយធ្វើនៅ២០០៤និងកំពុងបច្ចុប្បន្នភាពនៅឆ្នាំ២០១៤ | | | |
| ១០-បង្កើតផែនការនិងយន្តការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីសម្រេចតម្រូវការបុគ្គលិកដែលទាមទារពេលមាន 'សន្ទុះកើនឡើង" | | | |
| ១០.១-មានយន្តការចលនានិងពង្រាយបុគ្គលិក | | | X |
| កំណត់សម្គាល់៖<br>- មានក្រុមឆ្លើយតបរហ័សនៅគ្រប់ថ្នាក់នៃប្រព័ន្ធសុខាភិបាលសម្រាប់ការរាតត្បាតជាសកល តែក្រុមនេះក៏ប្រតិបត្តិការពេលមានគ្រោះមហន្តរាយដែរពេលដែលមានករណីជំងឺរាតត្បាត<br>- ក្នុងពេលចាំ ការចលនាធនធានមនុស្សចាត់ចែងដោយរដ្ឋមន្ត្រីផ្ទាល់<br>- ត្រូវរៀបចំបង្កើតឱ្យមានយន្តការឬនីតិវិធីផ្លូវការដើម្បីចលនានិងពង្រាយបុគ្គលិកបន្ទាន់ពេលមានគ្រោះអាសន្នឬគ្រោះមហន្តរាយ | | | |
| ១០.២-មានយន្តការដើម្បីទទួលបុគ្គលិកបន្ថែមតាមអាទិភាពសុខភាពនិងមានយន្តការចុះបញ្ជីនិងគ្រប់គ្រងក្រុមគ្រូពេទ្យបរទេស | | | X |
| កំណត់សម្គាល់៖<br>- ពុំទាន់មានយន្តការជាផ្លូវការដើម្បីទទួលនិងចុះបញ្ជីការក្រុមគ្រូពេទ្យបរទេសដែលចូលមកពេលមានគ្រោះអាសន្ននៅឡើយ<br>- គួរពិចារណាលើការរៀបចំឱ្យមានយន្តការនិងនីតិវិធីទទួលយកក្រុមគ្រូពេទ្យបរទេសដែលមកជួយ | | | |
| ១០.៣-អនុវត្តន៍លំហាត់សាកល្បងឱ្យបានទៀងទាត់ដើម្បីផ្ទៀងផ្ទាត់នឹងនីតិវិធីប្រតិបត្តិការស្តង់ដា | | | x |
| កំណត់សម្គាល់៖ | | | |

| | | | |
|---|---|---|---|
| - មន្ទីរពេទ្យបានធ្វើជាមួយអាកាសយានដ្ឋានជាទៀងទាត់មន្ទីរពេទ្យកាល់ម៉ែតនិងមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតបានចាប់ផ្តើមតែមិនទាន់ទៀងទាត់<br>- ត្រូវរៀបចំពេលធ្វើផែនការត្រៀមរៀបចំជាមុនរបស់ក្រសួង | | | |
| ១០.៤-រៀបចំការបណ្តុះបណ្តាលបន្តក្នុងការងារឱ្យបានទៀងទាត់ | | | x |
| កំណត់សម្គាល់៖<br>- អាចធ្វើបានបើមានថវិកាគាំទ្រ<br>- កន្លងមកបានធ្វើមួយចំនួនហើយ | | | |
| ១១-កំណត់រកសម្ភារនិងឧបករណ៍វេជ្ជសាស្ត្រសំខាន់ៗតាមការធ្វើការប៉ាន់ប្រមាណហានិភ័យនិងការវិភាគដើម្បីធានាកម្រិតស្តុកទុកអប្បបរមានៅកន្លែងមួយសមស្រប | | | |
| ១១.១-ស្តុកទុកសម្ភារនិងឧបករណ៍វេជ្ជសាស្ត្រសំខាន់ៗរួមទាំងឃីតសង្គ្រោះបន្ទាន់នៅកន្លែងសមស្របនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | x | | |
| កំណត់សម្គាល់៖<br>- មានស្តុកសម្រាប់ការរាតត្បាតជាសកល<br>- មានស្តុកសម្រាប់ទឹកជំនន់ | | | |
| ១១.២-មានយន្តការតាមដានជាប្រចាំនូវគុណភាពនិងសុវត្ថិភាពនៃការរក្សាទុកសម្ភារនិងឧបករណ៍សំខាន់ៗ | x | | |
| កំណត់សម្គាល់៖<br>- នាយកដ្ឋានឱសថ និង ឃ្លាំងឱសថកណ្តាល ជាអ្នកទទួលខុសត្រូវ<br>- ឃ្លាំងឱសថតាមបណ្តាខេត្ត ក្រុងនិងស្រុកប្រតិបត្តិជាអ្នកទទួលខុសត្រូវ | | | |
| ១១.៣-រៀបចំសំណុំសេវាសុខភាពផ្លូវភេទនិងបន្តពូជអប្បបរិមានិងដំបូង(MISP)និងឃីតសង្គ្រោះបន្ទាន់ហើយរក្សាទុកតាមកម្មវិធីសុខភាពផ្សេងៗ | | x | |
| កំណត់សម្គាល់៖<br>- សេវាសុខភាពផ្លូវភេទនិងបន្តពូជអប្បបរិមានិងដំបូង( MISP) មាននៅតាមមណ្ឌលសុខភាព និង មន្ទីរពេទ្យបង្អែក<br>- នឹងពិភាក្សាដើម្បីរៀបចំជាសំណុំសេវាសម្រាប់ពេលមានគ្រោះមហន្តរាយ<br>- មានឃីតសម្រាលសុវត្ថិភាព | | | |

| | | | |
|---|---|---|---|
| - បានបណ្ដុះបណ្ដាលEmOC និង CmOCនិងរៀបចំមណ្ឌលសុខភាពនិង មន្ទីរពេទ្យបង្អែកឱ្យមានសេវាទាំងនេះ | | | |
| ១២-រៀបចំនីតិវិធីសម្រាប់ធ្វើកិច្ចសន្យាបន្ទាន់ក្នុងការផ្គត់ផ្គង់សម្ភារនិងសេវាសុខភាព | | | |
| ១២.១-មានយន្តការដើម្បីពន្លឿនការធ្វើលទ្ធកម្មនិងប្រគល់ការផ្គត់ផ្គង់សម្ភារសុខភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | x | | |
| កំណត់សម្គាល់៖<br>- មាននីតិវិធីដែលនាយកដ្ឋានហិរញ្ញវត្ថុជាអ្នកទទួលខុសត្រូវដោះស្រាយ | | | |
| ១២.២. យន្តការដែលរួមមានការកំណត់ពីឯកសារលំអិតបច្ចេកទេសនៃទំនិញតម្លៃពេលវេលានៃការប្រគល់និងការទុកចិត្តបាន | x | | |
| កំណត់សម្គាល់៖<br>- មានយន្តការសម្រាប់លទ្ធកម្មធម្មតា | | | |
| ១២.៣-មានការចាត់តាំងច្បាស់លាស់នូវអាជ្ញាធរនិងនីតិវិធីនៃក្រសួងសុខាភិបាលសម្រាប់ការស្នើសុំទទួលឬបដិសេធ ឱសថបុគ្គលិកមន្ទីរពេទ្យបណ្ដោះអាសន្ននិងសេវាដ៏ទៃទៀតដែលផ្ដល់ដោយដៃគូអន្តរជាតិ | | x | |
| កំណត់សម្គាល់៖<br>- មានសម្រាប់ផ្នែកឱសថ<br>- មិនទាន់មានសម្រាប់បុគ្គលិកទេ<br>- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិទទួលខុសត្រូវការងារបរទេស | | | |
| ១២.៤-មានការផ្ដល់ការលើកលែងពន្ធនិងការជួយសម្រួលឱ្យរហ័សនូវការត្រួតពិនិត្យរបស់គយនូវការនាំចូលនៃសម្ភារ ផ្គត់ផ្គង់វេជ្ជសាស្ត្រ | x | | |
| កំណត់សម្គាល់៖<br>- មានការលើកលែងពន្ធ និង ការសម្របសម្រួលមាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិជាអ្នកសម្របសម្រួល។ | | | |
| ១៣-ធានាមានគោលនយោបាយស្ដីពីយន្តការផ្ដល់ថវិកាដើម្បីគាំទ្រគ្រប់ផ្នែកនៃវដ្តនៃការគ្រប់គ្រងហានិភ័យគ្រោះ អាសន្នសម្រាប់សុខភាព( បង្ការត្រៀមរួចជាស្រេចឆ្លើយតបនិងការវិលមកភាពល្អប្រសើរវិញ) | | | |
| ១៣.១-សមាមាត្រនៃថវិកាជាតិសម្រាប់សុខភាពវិភាជន៍លើការគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាព | | | x |

| | | | |
|---|---|---|---|
| កំណត់សម្គាល់៖<br>- ត្រូវរៀបចំផែនការលើគ្រប់ផ្នែកនៃការគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាព | | | |
| ១៣.២-មានថវិកាសម្រាប់ការរៀបចំការប៉ាន់ប្រមាណនិងផែនទីហានិភ័យពហុវិស័យ | | | x |
| កំណត់សម្គាល់៖<br>- នឹងពិភាក្សានៅពេលធ្វើផែនការ | | | |
| ១៣.៣-រាល់ថវិកានៃគម្រោងការគ្រប់គ្រងហានិភ័យគ្រោះអាសន្នសម្រាប់សុខភាពត្រូវមានសម្រាប់ការតាមដានជាប្រចាំនិងវាយតម្លៃ | | | x |
| កំណត់សម្គាល់៖<br>- ថវិកាសម្រាប់តែការឆ្លើយតបប៉ុន្តែសម្រាប់ការគ្រប់គ្រងហានិភ័យមិនទាន់មានដោយច្បាប់នៃការគ្រប់គ្រងគ្រោះមហន្តរាយ មិនទាន់អនុមតិ | | | |
| ១៤-បង្កើតឬធ្វើឱ្យកាន់តែប្រសើរនូវថវិកាត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយ | | | |
| ១៤.១-មាននីតិវិធីដែលឆាប់ទទួលផលក្នុងការទទួលបានថវិកាត្រៀមបម្រុងពេលត្រូវការ | | | x |
| កំណត់សម្គាល់៖<br>- មិនទាន់មាន | | | |
| ១៤.២-មានការចាត់តាំងច្បាស់លាស់អាជ្ញាធរដែលជាអ្នកវិភាជន៍និងចំណាយថវិកាត្រៀមបម្រុង | | | x |
| កំណត់សម្គាល់៖<br>- មិនទាន់មាន | | | |
| ១៤.៣-រៀបចំគោលនយោបាយនីតិវិធីនិងយន្តការដើម្បីទទួលការចំណាយនិងគណនេយ្យសម្រាប់ថវិកាអន្តរជាតិដែលបានជួយ *(e.g. CAP and Flash Appeals)* | | | x |
| កំណត់សម្គាល់៖<br>- នេះជាភារកិច្ចរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | | | |